# ស្រមោលបង

*(ជ័យលាភីលេខ១ ក្នុង“វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ” លើកទី១ ឆ្នាំ២០០៤)*

## សោកនាដកម្មថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

*ចន្លោះពីឆ្នាំ១៩៧០ដល់១៩៧៥ នាងខ្ញុំបានរៀបការជាមួយបុរសម្នាក់ ហើយបានកូនប្រុសម្នាក់អាយុ៣ឆ្នាំនិងកូនស្រីម្នាក់អាយុ២ឆ្នាំ ។ នាងខ្ញុំជាគិលានុបដ្ឋាយិកាយោធានៅមន្ទីរពេទ្យព្រះមុនីវង្ស ។ កាលណោះ ប្រធានពេទ្យគឺលោកវេជ្ជបណ្ឌិត ថោង បូយ៉ាន, លោកវេជ្ជបណ្ឌិត ទា គីមហ៊ី ផ្នែក* Radio, *លោកសាស្ត្រាចារ្យ ទិព្វ ម៉ម ផ្នែកសួត, ហើយចៅហ្វាយរបស់ខ្ញុំគឺលោកវេជ្ជបណ្ឌិត អ៊ឹង ប៉ូឡុង ដែលមានជំនាញផ្នែកជំងឺក្រពះនិងជំងឺទូទៅ ។ នៅមានអស់លោកជាច្រើនទៀត ប៉ុន្តែនាងខ្ញុំ ភ្លេចអស់ទៅហើយ ពុំដឹងជាពេលនេះអស់លោកទាំង នោះទៅដល់ណាហើយទេ ។*

*ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃខ្មៅនៃកម្ពុជា ។ សមមិត្តអាវខ្មៅក្មេងៗ ប្រកបដោយមុខមាំគួរឲ្យខ្លាច បានបញ្ឆោយ៉ាងដាច់ណាត់ឲ្យប្រជាជនទាំងអស់នៅទីក្រុងភ្នំពេញចាកចេញពីលំនៅឋានជាប្រញាប់ ដោយមិនបាច់យកអីវ៉ាន់ទៅច្រើនទេ ព្រោះចេញតែ៣ថ្ងៃប៉ុណ្ណោះនឹងត្រឡប់មកផ្ទះវិញហើយ ។ នាងខ្ញុំ និងប្តី ព្រមទាំងកូនភ័ក្ត្រ និងស្រីស្រស់ កូនពៅខ្ញុំ ក៏ចេញដំណើរដូចគេឯងដែរ ។ យើងទាំងអស់គ្នាយកចានស្រាក់មួយ ឆ្នាំងដាំបាយមួយឆ្នាំង សម្លមួយធុងទឹកកក និងសម្លៀកបំពាក់រៀងៗខ្លួន ម្នាក់បន្តិចបន្តួច ។ ខ្ញុំយកសម្លៀកបំពាក់របស់ម្តាយក្មេកខ្ញុំ៤-៥ បាវដែលគាត់បានយកមកផ្ញើនៅផ្ទះខ្ញុំ ។ លោកឪពុកក្មេកខ្ញុំ ដែលគាត់មកសម្រាន្តលេងនៅផ្ទះខ្ញុំ៨-១០ថ្ងៃហើយ បានទៅចម្ការ របស់គាត់មុននេះបន្តិច ព្រោះគាត់យល់ថាស្រុកសាន្តត្រាណ ហើយលែងខ្វល់អីហើយ ។ ក្រោយមកគាត់ក៏បាត់ស្រមោលរហូត ។ យើងទាំងអស់គ្នារង់ចាំមើលផ្លូវគាត់យ៉ាងយូរទម្រាំដាច់ចិត្តចាកចេញ ។ មុនចេញដំណើរ ប្តីខ្ញុំបានយកកាតកាំភ្លើង និងគ្រឿងប្រាក់ខ្លះៗ ទៅកប់នៅដីក្រោយផ្ទះខ្ញុំដោយមានកូនឈរមើលគាត់ផង ។ គាត់ជីកដីបណ្តើរនិយាយប្រាប់ខ្ញុំបណ្តើរថា “អាបារាំង (គាត់តែងហៅខ្ញុំដូច្នេះ) ជួយចាំគ្នាណា ខ្ញុំវាស់១០ជំហានពីរបងខ្ញុំកប់អីវ៉ាន់” ។ ខ្ញុំឆ្លើយថា “ចាំតែខ្លួនឯងអ្នកកប់ទៅ ៣ថ្ងៃក្រោយគង់តែមកយកខ្លួនឯងវិញទេ” ។ ពុទ្ធោ! ខ្ញុំពុំនឹកស្មានសោះថាគាត់គ្មានវាសនាវិលមកយកអីវ៉ាន់ហ្នឹងវិញទេ ។*

*ខ្ញុំនិងក្រុមគ្រួសារបានចេញដំណើរទៅតាមផ្លូវត្រសក់ផ្អែម ដោយយកឡានម៉ាក់រ៉ូលវ៉ាហ្គែនបីបាំងមួយគ្រឿងទៅជាមួយផង ។ យើងធ្វើដំណើរទៅដល់ស្ពានក្បាលថ្នល់ ហើយនៅកកស្ទះ នៅទីនោះវាល់ល្ងាចដោយពុំអាចឆ្លងរួច ។ នៅទីនោះ អ្នកជម្លៀស ខ្លះក៏ឈឺពោះឆ្លងទន្លេដាប់នៅលើស្ពានក៏មាន ។ ខ្ញុំឈប់នៅវង្វង់ មូលក្បាលថ្នល់ជិតឃ្លាំងអង្ករមួយ មនុស្សម្នាចូលទៅទាញយកបាវអង្ករស្រេចតែចិត្ត ។ ខ្លះក៏ត្រូវបាវអង្ករសង្កត់លើស្លាប់ ខ្លះលោភលន់លើកយកមកគរត្រួតលើគ្នា៤-៥បាវនៅលើផ្លូវ ទីបំផុត យកតែ១បាវមិនចង់រួច ។ ប្តីខ្ញុំក៏ចាំយកបន្តពីគេមកដាក់ក្នុងឡាន ។ ស្អែកឡើងខ្ញុំឆ្លងផុតស្ពានមុនីវង្សដោយលំបាក ព្រោះមនុស្សច្រើនពេក ។ ពេលនោះមនុស្សមិនដឹងមកពីណាទៅណាទេ កូនខ្លះវង្វេងម៉ែឪ បងប្អូន ចាស់ៗខ្លះត្រូវចៅ ឬកូនអៀវ ឬដាក់លើរទេះឈើអូស ឬដាក់លើស៊ីក្លូដែលមិនដឹងជារកបានពីណា ។ ពេញមួយថ្ងៃយើងធ្វើដំណើរមិនបានមួយគីឡូម៉ែត្រផង ។ យប់នេះ គ្រួសារខ្ញុំមកដល់មុខវត្តនិរោធរង្សី ប្តីខ្ញុំប្រាប់ថា យើងត្រូវសម្រាកក្នុងឡាននៅលើចិញ្ចើមថ្នល់នេះហើយ ។ កណ្តាលយប់ ឡានហ្ស៊ីប២-៣គ្រឿងបើកពីទិសខាងកើតមកវិញ បន្លឺស៊ីផ្លេយ៉ាងញាប់រន្ថើន ហាក់ដូចជាមានការបន្ទាន់ណាស់ ។ ពួកយោធាក្មេងៗ ឈរនៅលើឡានអត់ដំបូល ស្រែកគំហកដោយទឹកមុខមាំឲ្យអ្នកធ្វើដំណើរចៀសពីផ្លូវឲ្យឆាប់ ។ អ្នកដំណើរ៤-៥នាក់ដែលនៅពាំងផ្លូវ ត្រូវយោធាក្មេងៗនោះលើកកាំភ្លើងបាញ់រះទាំង កំហឹង ។ យើងទាំងអស់គ្នាញ័ររន្ធត់ដូចកូនសត្វ ព្រោះពុំដែលឃើញទស្សនីយភាពដូច្នេះសោះពីមុនមក ។*

*បីថ្ងៃក្រោយមក យើងបានទៅឈប់សម្រាកនៅចម្ការ ល្ហុតជិតមាត់ទន្លេម្តុំកៀនស្វាយ ។ ខ្ញុំដើរមើលប្រជាជនជម្លៀសទាំងអស់ ខ្លះបោះតង់ ខ្លះក៏ចងក្រណាត់កៅស៊ូក្រោមដើមល្ហុត ខ្លះហាក់ដូចជាឈឺទើបនឹងចេញពីពេទ្យ ។ គ្រួសារខ្លះមានទឹកមុខរីក*

រាយ ហើយអន្ទុយដឹកជំហូបបាយដូចជាទៅដើរកម្សាន្ត ។ ម្នាក់ៗពោរពេញដោយក្ដីសង្ឃឹមយ៉ាងមុតមាំថា បីថ្ងៃទៀត បានត្រឡប់ទៅផ្ទះវិញ ។ ពេលល្ងាច ស្រីៗចោមពុងសារុង បញ្ចេញសាច់ទ្រូងសខ្ចីកាន់ដបសាប៊ូកក់សក់ដើរទៅមាត់ទន្លេងូតទឹកយ៉ាងរំភើយ ។ ក្រមុំកម្លោះខ្លះមានតែខោអាវមួយកំប្លេ ខ្លះមានតែសារុង ឬក្រមា បណ្ដើរគ្នាទៅងូតទឹក តែទឹកមុខគេគ្មាន ព្រួយបារម្ភអ្វីបន្តិចណាសោះ ។ ក្មេងៗអស់នេះប្រហែលជា ទៅដើរលេងហើយពេលខ្មែរក្រហមបណ្ដេញចេញពីទីក្រុងក៏ចេញតែម្ដងទៅ ។ យើងសម្រាកនៅទីនោះបានប្រហែល១០ថ្ងៃ ស្រាប់តែមានយោធាក្មេងៗ ៤-៥ នាក់ដៃកាន់កាំភ្លើងអាកា ស្ពាយសម្ភារសឹក ពាក់មួកកន្ទឹប អាវខ្មៅ ខោខ្មៅ ស្បែកជើង កង់ឡាន ដើរប្រកាសប្រាប់ថា បងប្អូន អ៊ំ ពូ មីង ណាធ្វើការអីអាចទៅចុះឈ្មោះចូលធ្វើការវិញបាន ។ កន្លះខែក្រោយមក កន្លែងដែលខ្ញុំសម្រាកក៏ស្ងាត់មនុស្សនៅសល់តែ៣-៤គ្រួសារ ប៉ុណ្ណោះ ។ មានអ៊ំម្នាក់សម្រាកនៅជិតខ្ញុំប្រាប់ថា គាត់ចាំគ្រួសាររបស់គាត់ ដើម្បីត្រឡប់ទៅស្រុកកំណើតនៅថ្ងៃស្អែកនេះហើយ ព្រោះគេមិនទាន់ឲ្យចូលទីក្រុងភ្នំពេញវិញទេ ខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែក ។

គ្រួសារខ្ញុំក៏សម្រេចចិត្តទៅឃុំតានីទូកមាសដែលជាស្រុក កំណើតរបស់ប្ដីខ្ញុំ ដើម្បីជួបឪពុកក្មេកម្ដាយក្មេកខ្ញុំ និងយកអីវ៉ាន់ដែលគាត់ផ្ញើទៅជូនគាត់វិញ ។ ស្អែកឡើងយើងក៏ធ្វើ ដំណើរបកក្រោយមកមាត់ទន្លេវិញ តែយើងមិនអាចឆ្លងស្ពានព្រះមុនីវង្សវិញបានទេ ។ យើងនាំគ្នាបើកឡានសសៀរតាមមាត់ទន្លេ ហើយឆ្លងទូកដទៅត្រើយម្ខាងដោយនិយាយដោះដូរឡាន ជាមួយនឹងឡាំប្រឺតាបងប្រុសម្នាក់ដែលចង់ឆ្លងមកត្រើយខាងខ្ញុំវិញ ។ ខ្ញុំបានយកអង្ករខ្លះដូរបានត្រីរ៉ស់គ្រាន់ហូបមួយពេលដែរ ។

ឆ្លងទៅដល់ត្រើយម្ខាង យើងក៏ធ្វើដំណើរទៅតាមផ្លូវតូចៗ ដោយគ្មានដឹងទិសតំបន់អ្វីទាំងអស់ ។ យូរៗម្ដង ក្រុមគ្រួសារយើងឈប់សួរប្រជាជនរកផ្លូវទៅតានីទូកមាស ។ នៅតាមផ្លូវ យើងបានជួបនឹងយោធាក្មេងៗចងអង្រឹងយាមក្រោមដើមឈើបានហៅឡាំប្រឺតា ខ្ញុំឈប់ហើយឆែកឆេរអីវ៉ាន់ ។ ពេលរើទៅ ឃើញកំប៉ុងត្រីខដែលមានរាងទ្រវែង សមមិត្តអស់នោះចង់ខ្លាចព្រោះស្មានស្មានថាជាតែគ្រាប់បែក ។ តាមមើលសមមិត្តអស់នោះ ចង់រើរកនាឡិកាដៃតែប៉ុណ្ណោះ ។ ខ្ញុំបានលាក់ថ្នាំពេទ្យនិងសឺរ៉ាំងចាក់ថ្នាំក្នុងបាវអង្ករ ។ យើងបន្តដំណើរទៅមុខទៀតតាម ការចង្អុលបង្ហាញរបស់អ្នកស្រុក ។ ផ្លូវលំក្រហេងក្រហូងដែលតាមស្មាន គឺគ្មានការថែរក្សាដោយមូលហេតុសង្គ្រាម ធ្វើឲ្យឡាំប្រឺតាវារតើមៗទៅមុខដោយលំបាក ។ ថ្ងៃត្រង់ហើយ យើងទាំងអស់គ្នាមកដល់ភូមិមួយឈ្មោះភូមិក្រាំងយ៉ូវ ។ ទីនោះស្ងាត់ ជ្រងំដូចគ្មានមនុស្សរស់នៅ ។ នៅមុខផ្ទះនីមួយៗសុទ្ធតែគូររូបក្បាលខ្មោចនៅរបងផ្ទះ ។ ប្ដីនាងខ្ញុំនិយាយថា "ស្ងាត់យ៉ាងណា ក៏ត្រូវតែឈប់ដាំបាយសិនដែរ ព្រោះហេវខ្លាំងណាស់ ទៅមុខទៀតពុំរួចទេ" ។ មួយរយៈតូចដែលយើងឈប់ដាំបាយពុំទាន់ឆ្អិនស្រួលបួលផង ខ្ញុំឃើញយោធាសែងខ្មោចយកទៅកប់ប្រហែលជា៤-៥នាក់ ហើយអ្នកស្រុកម្នាក់បានខ្សឹបប្រាប់ថា កុំនៅទីនេះយូរពេក កន្លែងនេះមានមនុស្សស្លាប់ដោយជំងឺអាសន្នរោគច្រើនណាស់ ។ យើងក៏រូតរះទៅមុខទៀតដោយពុំហ៊ានទាំងហូបបាយ នៅទីនោះផង ។

ដំណើររបស់យើងពីដំបូងហាក់ដូចសប្បាយណាស់ ។ ខ្ញុំ ស្រម័យថាជាការដើរកម្សាន្តមួយលុះយូរៗទៅ យើងមានការហេវហត់រកកម្លាំងកំហែងគ្មាន ។ កូនប្រុសច្បងខ្ញុំអាយុ៣ឆ្នាំ និងកូនស្រីទីពីរអាយុ២ឆ្នាំមុខក្រៀមជាប់ សាច់ក្ដៅស្ងៀមលែងចង់និយាយស្ដីអ្វីទាំងអស់ ។

ព្រឹកនេះនៅតាមផ្លូវខ្ញុំបានជួបស្រីក្រមុំពីរនាក់បងប្អូននាង បងរាងខ្មៅបន្តិចតែខ្ញុំភ្លេចឈ្មោះទៅហើយ (សុំទោស) នាងប្អូនអាយុប្រហែល១៨ឆ្នាំ សាច់សម៉ដ្ឋខែសម្ដីរួសរាយរាក់ទាក់ជាង នាងបង ។ នាងឈ្មោះ អាដា (ដែលសព្វថ្ងៃនាងជាអ្នកស្រី មា ឆដា ពិធីការិនីប្រចាំទូរទស្សន៍ជាតិកម្ពុជា) ។ បងប្អូនទាំងពីរបានសុំ គ្រួសារនាងខ្ញុំរួមដំណើរជាមួយផង ព្រោះនាងបែកពីឪពុកម្ដាយអស់ហើយ ។ ពួកខ្ញុំក៏យល់ព្រមដោយចិត្តរីករាយ ព្រោះយើងចង់តែបានគ្នាច្រើនប៉ុណ្ណោះ ។

ល្ងាចម៉ោង៥ទៅហើយ ក្រុមគ្រួសារនាងខ្ញុំបានមកដល់មុខ វត្តមួយឈ្មោះវត្តអង្គរសិគ្គដែលពុំដឹងក្នុងភូមិស្រុកអី ដឹងតែថានៅក្នុងខេត្តតាកែវ ។ យោធា៤-៥នាក់ឈរពាំងផ្លូវ ដៃកាន់កាំភ្លើងវែងទឹកមុខមាំកាចគួរឲ្យខ្លាច បានស្ដីឲ្យយើងថា "នៅធ្វើដំណើរដល់ណាទៀត គេរវល់ធ្វើស្រែគ្រប់គ្នា ឯងគិតតែដើរសេរី ។ ឥឡូវឈប់ហ្នឹងនៅសម្រាកក្នុងវត្តនេះហើយ ចាំស្អែកគេនាំ

ទៅនៅក្នុងស្រុកភូមិនឹងគេ ឈប់ឲ្យដើរទៀតហើយ» ។ យប់នេះ កូនប្រុសខ្ញុំក្តៅខ្លួនរវើរវាយស្រែកតែផ្តេសផ្តាស ។ ខ្ញុំលួចយកថ្នាំក្នុងបាវអង្ករឲ្យកូនលេបទម្រាំតែបាន ។ អ្នកជិតខាង ប្រាប់ ឲ្យខ្ញុំបន់ទៅក្រែងខុសបារមីវត្តនេះ ។

ព្រឹកនេះខ្ញុំបើកភ្នែកឡើងឃើញឡានសណ្តោង៣-៤គ្រឿង ចតរង់ចាំយើងទាំងអស់គ្នារួចជាស្រេចនៅមុខសាលាឆាន់ ។ យោធាម្នាក់ស្ពាយកាំភ្លើងវែង ស្រែកប្រាប់ឲ្យយើងរៀបអីវ៉ាន់ឡើងលើឡានថ្មី ។

យោធាក្មេងម្នាក់សម្បុរខ្មៅមុខមាំ និយាយដោយសំឡេងដាច់ខាតថា «មិត្តទាំងអស់គ្នានៅជួយធ្វើស្រែនៅទីនេះមួយឆ្នាំសិនហើយ ចាំឆ្នាំក្រោយសឹមទៅស្រុកកំណើតវិញ» ។

ខ្ញុំត្រេកអរណាស់គ្រាន់តែឮដូច្នេះ ព្រោះនឹកថាបានស្គាល់ស្រុកទេសគេដែរ ។ គិតទៅយើងទាំងអស់គ្នាត្រូវគេកដោយពុំដឹងខ្លួនតាំងពីដំបូងទីមកម្ល៉េះ ។ ឡាំប្រឺតាខ្ញុំចោលនៅទីនេះទុកដាំខ្ទឹមទៅ ។ ម្នាក់ៗស្ពាយតែបង្វេចរៀងៗខ្លួនឡើងលើឡានថ្មី ។ ខ្ញុំជិះលើឡានមែរសឺដែសកង់ដប់ថ្មីសប្បាយចិត្តណាស់ ព្រោះបានស្រូបខ្យល់អាកាសថ្មី ទោះបីរលាក់ចង់ធ្លាក់ថ្លើមប្រមាត់ក៏ដោយ ។ ពេលនោះនាងខ្ញុំហាក់ដូចជាមានក្តីពិភាល់មួយក្នុងចិត្តអំពីអនាគតរបស់យើងទាំងអស់គ្នា ។

## ភូមិព្រៃគាំ

ក្រុមយោធាទគេបានដឹកយើងទាំងអស់គ្នាមកដល់ភូមិមួយឈ្មោះភូមិព្រៃគាំ ។ គេឲ្យផ្ទះឈើមួយខ្នងធំនៅជុំគ្នាប្រាំគ្រួសាររួមទាំងបងប្អូន អាដា ដែរ ហើយខ្ញុំក៏ទើបបានជួបប្អូនប្រុសទីពីរនៅតាមផ្លូវដែលវាបែកពីប៉ាម៉ាក់ខ្ញុំ ព្រោះរវល់នៅរៀនផ្ទះពូកម៉ាក ។ រួមទាំងបងប្អូនខាងប្តីខ្ញុំបីគ្រួសារទៀតក៏នៅជួបជុំគ្នាក្នុងផ្ទះនោះ ។

យើងទាំងអស់គ្នាស្រឡាញ់រាប់អានគ្នាណាស់ ចេះជួយគ្នាទៅវិញទៅមក ជាពិសេសប្អូនស្រីដា ស្រឡាញ់ក្មេងណាស់ ជួយមើលកូនខ្ញុំពេលខ្ញុំរវល់ ។ នេះជាអនុស្សាវរីយ៍មួយនៅជាប់ក្នុងបេះដូងរបស់នាងខ្ញុំ ដែលខ្ញុំមិនអាចបំភ្លេចបានទាល់តែសោះ ។

ក្នុងផ្ទះនោះមានជង្រុកស្រូវធំមួយដាក់នៅជ្រុងផ្ទះ តែគ្មាន អ្នកណាយកចិត្តទុកដាក់ស្រូវនេះទេ ព្រោះយើងសុទ្ធតែនៅមានអង្ករហូបបរិបូណ៌នៅឡើយ ។ ភូមិព្រៃគាំមានប្រជាជនចាស់ ឬអ្នកមូលដ្ឋានប្រហែល៣០គ្រួសារ ហើយយើងជាប្រជាជន១៧មេសាប្រហែល១០គ្រួសារ ។ ប្រជាជនចាស់ៗទាំងនេះ មានសម្លៀកបំពាក់រហែកប៉ះជាច្រើនបំណះ ព្រោះគេថាធ្វើបដិវត្តន៍ មុនប្រជាជន១៧មេសាយូរឆ្នាំមកហើយ ។ ពេលយើងទៅដល់ដំបូង ប្រជាជនមូលដ្ឋានសម្លក់សម្លឹងមើលសម្លៀកបំពាក់របស់យើងដោយក្តីចង់បាន ។ មានអ្នកលួចខ្សឹបសួរនាងខ្ញុំ រកសារុងថ្មី ឬអាវដៃវែង ។ ដូច្នេះមានតែខោអាវម្តាយក្មេកឪពុកក្មេកខ្ញុំទេ ដែលត្រូវប៉ាន់អាចដោះដូរបានជាមាន់ ជាត្រី ឬជួនកាលក៏ដូរយកបន្លែដែលគេដាំក្នុងភូមិ ដូចជា ត្រឡាច ល្ពៅ ជាដើម ។ ជួនកាលថ្នាំគ្រុន ថ្នាំផ្សះរបស់ខ្ញុំ ក៏មានគេត្រូវការដែរ ។

## ឈ្លើងកន្លាស់មិត្តដ៏ស្និទ្ធស្នាលរបស់ខ្ញុំ

យើងទាំងអស់គ្នានៅទីនោះប្រមាណ៣ខែ ពេលព្រឹក យើងត្រូវចេញទៅដកសំណាបនៅឯវាលស្រែដ៏ធំល្វឹងល្វើយ ។ អ្នកណាក៏សើចនឹងនាងខ្ញុំដែរ ព្រោះទម្រាំដើរទៅដល់វាលស្រែ នាងខ្ញុំរអិលដួលប្រផាប់ប្រផិលប្រឡាក់សុទ្ធតែភក់ឲ្យស្រមកទាំងមិនទាន់បានធ្វើការអ៊ីបន្តិចផង ។ អ្នកមូលដ្ឋានទាំងអស់តែងតែសើចចំអកឲ្យខ្ញុំថា នៅភ្នំពេញតើរកស៊ីអីទៅ បើគ្រាន់តែដើរក៏ដួលដែរនោះ មិត្តណាង អើយ ។ នៅពេលចុះស្ទូងខ្ញុំមិនដែលស្ទូង ទាន់គេទេ ជួនកាលគេក៏ស្ទូងបិទមុខខ្ញុំក៏មាន ។ នៅក្នុងទឹកមានសត្វអ្វីតូចៗ នៅជាប់នឹងជើងខ្ញុំ ខ្ញុំបេះចេញធ្វើមិនដឹង ។ អ្នកមូលដ្ឋាន ម្នាក់សួរខ្ញុំថា «មិត្តឯងម៉េចក៏មិនខ្លាចឈ្លើងអីចឹង?» ខ្ញុំឆ្លើយធ្វើព្រងើយថា ព្រោះខ្ញុំនៅតែក្នុងស្រែតាំងពីបាតជើងក្រហមមកម្ល៉េះ ។ ក្នុងពោះខ្ញុំញ័រដែរ អូហ៍អាហ្នឹងទេដែលគេហៅថាឈ្លើង? ហេតុនេះឈ្លើងក៏ក្លាយជាមិត្តសម្លាញ់ខ្ញុំតាំងពីពេលនោះមក ។ ពេលខ្លះមានអ្នកមូលដ្ឋានដែលត្រូវឈ្លើងទាមស្រែកយ៉ៃហើយរត់មករកខ្ញុំឲ្យជួយបេះឲ្យ ខ្ញុំយកសំណាបបូតឈ្លើងចេញ ។ ស្រីអ្នកមូលដ្ឋាននោះប្រាប់ខ្ញុំថា «មិត្តណាងអើយ ខ្ញុំអ្នកស្រែមែន

*តែមិនដែលស្គាល់ស្រែយ៉ាងម៉េចទេ» ។ ប្រជាជននៅទីនោះមិន សួរប្រកាន់ការល្ងិតល្ងង់របស់យើងទេ គេមានតែជួយពន្យល់ប្រាប់យើងថែមទៀត ។*

## មន្ទីរពេទ្យរបស់អង្គការ

*ប៉ុន្មានថ្ងៃនេះកូនស្រីទីពីររបស់ខ្ញុំចេះតែក្អួត បាយក៏មិនហូប ទឹកក៏មិនផឹកដែរ ។ ខ្ញុំសុំច្បាប់គេឈប់សម្រាកនៅផ្ទះមើលកូន គេក៏អនុញ្ញាតឲ្យ ។ ១០ថ្ងៃកន្លងផុតទៅហើយ ជំងឺរបស់កូនស្រីស្រស់ខ្ញុំមិនបានស្រាកស្រាន្តសោះ ។ ប្រធានភូមិបានឲ្យខ្ញុំយកកូនទៅដេកពេទ្យឃុំដែលមានចម្ងាយពីភូមិខ្ញុំប្រហែលពីរគីឡូម៉ែត្រ ។ ពេទ្យនោះគ្មានថ្នាំសង្កូវអ្វីទេ មានតែគ្រែឈើសម្រាប់ដេកតែប៉ុណ្ណោះ បើអ្នកជំងឺល្មមៗមកដេកក៏ស្លាប់ដែរ ដោយសារសង្កើចខាំ ។*

*វេលាយប់នោះកូនស្រីខ្ញុំយំទើសភ្លឺ ។ ក្មេងប្រុសពេទ្យម្នាក់ បានប្រាប់ខ្ញុំឲ្យសុំប្រធានពេទ្យយកកូនទៅសម្រាកនៅពេទ្យស្រុកទៅព្រោះនៅទីនោះសម្បូរថ្នាំ ។ ខ្ញុំក៏ទៅសុំប្រធានពេទ្យនារីដោយ យកសារុងខ្ញុំមួយឲ្យគាត់ជាថ្នូរនូវការដឹងគុណនារីប្រធានពេទ្យនោះទទួលយកដោយភ្នែកក្រឡេកក្រឡាប់មើលឆ្វេងស្តាំ ។ ប្រធានពេទ្យនោះក៏ចិត្តបានដែរ គាត់ប្រាប់ខ្ញុំថា ចាំស្អែកឲ្យសមមិត្តក្មេងម្នាក់បររទេះគោជូនខ្ញុំ និងកូនទៅពេទ្យ ។ ប្តីខ្ញុំក៏សុំទៅជាមួយដែរ ។ ព្រលឹមស្រាងៗ យើងក៏ចេញដំណើរតាមរទេះគោ ។ ដោយរទេះរលាក់ពេក ខ្ញុំនិងប្តីមិនជិះរទេះគោទេ ព្រោះអាណិតកូន សុខចិត្តយកអង្រឹងស្នែងសែងកូន ។ ពេទ្យស្រុកពុំដឹងនៅទីណា ព្រោះខ្ញុំពុំហ៊ានសួរគេ គ្រាន់តែដឹងថាយើងត្រូវដើរកាត់ស្រុកជាច្រើន ។ ទៅដល់ស្រុកមួយនោះ អ្នកបររទេះគោចង្អុលប្រាប់ថា ទីនេះគឺស្រុកសេរ៉ា មានកប់ខ្មោចទាហានពលីច្រើនណាស់ ។ យើងទៅដល់ពេទ្យស្រុក ពេលថ្ងៃជ្រេបន្តិចហើយ ។ ពេទ្យនោះ គឺយកវត្តធ្វើតែម្តង ។ ទាំងអស់គ្នាចង់ទន់ជង្គង់ ព្រោះតែឃ្លានបាយពេក ។ ខាងមន្ទីរពេទ្យអនុញ្ញាតឲ្យប្តីខ្ញុំ និងសមមិត្តបររទេះ ហូបបាយ នៅរោងបាយពិសេសព្រោះទីនោះ មានបាយម្ហូបឆ្ងាញ់ៗសម្រាប់ឲ្យអ្នកជូនអ្នកជំងឺមកពេទ្យហូបគ្រប់ពេលវេលា ។ ចំណែកខ្ញុំគេឲ្យហូបបបររាវ និងអំបិលម្រេច តែទោះយ៉ាងណាក៏ឆ្ងាញ់ដែរ ព្រោះខ្ញុំមិនបានហូបអ្វីតាំងពីព្រឹកមកម្ល៉េះ ។ ក្រោយពេលហូបបាយរួច ប្តីខ្ញុំត្រឡប់ទៅវិញភ្លាម ជាមួយមិត្តបររទេះ ក្រោយពីលួចថើបថ្ពាសកូនស្រីបន្តិច ។ ចំណែកនាងខ្ញុំ និងកូន គេឲ្យចូលសម្រាកកន្លែងរួមជាមួយអ្នកជំងឺ ៦ទៀតដែលមានគ្រែរនាបធំៗអាចសម្រាកបានពីរនាក់ ។ ព្រឹកឡើង មានពេទ្យស្រីក្មេងៗ ២-៣នាក់កាន់ថាសដាក់ប្រអប់ថ្នាំគ្រាប់ដើរចែកថ្នាំ ។ គេសួរខ្ញុំថាកូនឈឺអី ហើយក៏លូកយកថ្នាំគ្រាប់ឲ្យលេបដោយមិនចាំបាច់ពិនិត្យយូរ ។ ពេទ្យក្មេងៗទាំងនោះ ហាក់ដូចជាជំនាញខ្លាំងណាស់ ជួនកាលមានអ្នកជំងឺខ្លះត្រូវចាក់ថ្នាំ គេដណ្តើមគ្នាចាក់ ។ ខ្លះរត់ចេញពីចង្ក្រានបាយដៃសុទ្ធតែខ្លាញ់ ព្រោះទើបតែលាងចានហើយ យកដៃជូតខោខ្មៅកៗ ហើយស្រែកថាទុកឲ្យខ្ញុំចាក់វិញ ។ ៤-៥ថ្ងៃក្រោយមកកូនខ្ញុំបាន ធូរស្រាលបន្តិចទោះជាថ្នាំដែលគេឲ្យលេបមិនដឹងជាថ្នាំអ្វីខ្លះក៏ដោយ ព្រោះសុទ្ធតែអក្សរចិនហើយខ្លះជាថ្នាំសូន្យដូចអាចម៍ទន្សាយ ។ ទីនោះប្រៀបដូចជានៅក្នុងឋាននរក សំឡេងស្រែកថ្ងូរយំញ័ររន្ធត់ស្រែកសម្លុតជេរបញ្ឆោរយ៉ាងម៉េចក៏មានគ្រប់បែបយ៉ាងទាំងអស់ ។*

*ថ្ងៃនេះពេទ្យអនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅភូមិវិញ ។ ខ្ញុំឡេឡឺ ពុំដឹងទៅតាមផ្លូវណាជាមួយអ្នកណា ។ ចៃដន្យថ្ងៃបន្តិចមានរទេះ អ៊ំម្នាក់មកទទួលប្រពន្ធកូនគាត់ទៅផ្ទះវិញ ខ្ញុំក៏សុំដោយសារ ជាមួយបានតែពាក់កណ្តាលផ្លូវ គាត់ក៏បែកផ្លូវទៅទៀត ។ គាត់ប្រាប់ខ្ញុំឲ្យស្រូតដំណើរទៅផ្លូវខាងមុខនេះទៅកុំឲ្យយប់ទាន់ដើរ ប្រហែល១០គីឡូម៉ែត្រទៀតប៉ុណ្ណោះដល់ផ្ទះហើយ ។ ពុទ្ធោអើយ ខ្ញុំត្រូវពកូន និងមានបង្វេចខោអាវទៀត តែសំណាងល្អ ខ្ញុំចេះតែជួបរទេះសុំដោយសារទៅដល់ពេទ្យឃុំក៏យប់ល្មម ។ ពួកពេទ្យឃុំដែលស្គាល់ខ្ញុំគេត្រេកអរណាស់ពេលឃើញខ្ញុំនិងកូន ត្រឡប់មកវិញ ។ គេឃាត់ខ្ញុំឲ្យសម្រាកនៅទីនោះមួយយប់ តែខ្ញុំមិនព្រម ព្រោះខ្លាចបងសង្កើច ។ ខ្ញុំផ្ញើបង្វេចនឹងពេទ្យហើយពកូន ដើរលើទំនប់ដែលគេទើបនឹងលើកហើយថ្មីៗ ។ នៅវាលដុបខាងឆ្វេងដៃខ្ញុំសុទ្ធតែផ្នូរខ្មោចដែលគេកប់ទាំងស្នែងឫស្សី ឃើញឈើស្នែងនោះច្បាស់ ពេលចាំងនឹងពន្លឺព្រះច័ន្ទ ធ្វើឲ្យខ្ញុំព្រឺក្បាល ខ្លាកដូចជាមានគេដេញតាមពីក្រោយ ។ ខ្ញុំដើរកាន់តែលឿនទៅៗ ។ ត្រចៀកខ្ញុំឡើងហ៊ឹង ខ្ញុំទន្ទេញញាប់មាត់ថា «កុំខ្លាចៗ» ហើយស្រែក*

ច្រៀងពុៗ ដើម្បីបន្ធប់ការខ្លាច ។ ខ្ញុំមកដល់ភូមិ ទឹកលិចជុំវិញភូមិ ។ ខ្ញុំដើរស្ទាបៗ ព្រោះដឹងថាម្តុំនេះមានអន្លង់ធំមួយ ។ ម៉ោងប្រមាណ៨-៩យប់ យើងបានជួបជុំគ្នាសប្បាយ រីករាយណាស់ រួមទាំងមិត្តទាំងអស់ដែលនៅផ្ទះជាមួយគ្នា ។ ឥឡូវនេះយើងស្បៀយអង្ករហូប ប្រធានភូមិចែកមិនបានគ្រប់ គ្រាន់ទេ គាត់ប្រាប់យើងថាត្រូវហូបឲ្យសន្សំសំចៃ ត្រូវបបរក៏បបរខ្លះទៅ ។ យើងចាប់ផ្តើមសម្លឹងមើលជង្រុកស្រូវដែលនៅក្នុងផ្ទះយើង ហើយក៏លួចកិនហូបទាល់តែអស់ ។

យើងទទួលបញ្ជាឲ្យរៀបចំខ្លួនដើម្បីចេញដំណើរទៅរស់នៅខេត្តបាត់ដំបង ។ ម្នាក់ៗសប្បាយរីករាយណាស់ ព្រោះឮថាខេត្តនេះសម្បូរស្រូវ ។ ខ្លះលួចនិយាយគ្នាថាគេឲ្យយើងត្រឡប់ទៅភ្នំពេញវិញហើយ តែគេភរយើង ។ ចំណែកអ្នកមូលដ្ឋានគេមិនឲ្យទៅទេ ម្នាក់ៗមានទឹកមុខស្រងូតស្រងាត់ ហាក់មានអាថ៌កំបាំងអ្វីមួយ ។

ព្រឹកនេះយើងលាអ្នកមូលដ្ឋានទាំងអស់ ខ្លះក៏យំព្រោះអាឡោះអាល័យយើងដែរ ។ យើងត្រូវជិះរថភ្លើង ។ ក្នុងទូរថភ្លើងនីមួយៗ គេញាត់យើងឲ្យណែនដូចកាតំ ។ មិត្តភក្តិ និងបងប្អូនខាងប្តីខ្ញុំ ដែលនៅក្នុងផ្ទះជាមួយគ្នា ក៏បែកគ្នាតាំងពីពេលនោះជារៀងរហូត ។ ជិះរថភ្លើងបានមួយស្របក់ ខ្ញុំចាប់ផ្តើមចុកពោះ ។ ពេទ្យអង្គការប្រុសចំណាស់ម្នាក់ស្ពាយកាបូបដើរចុះឡើងៗមើលខ្ញុំ តែគ្មានឲ្យថ្នាំអ្វីមួយគ្រាប់ទេ ។ មួយម៉ោងក្រោយ គ្រូពេទ្យដដែលក៏មកអើតម្តងទៀត ឃើញមុខខ្ញុំឡើងស្លេកមែនទែនទើបបើកកាបូបយកថ្នាំគ្រាប់ហុចខ្ញុំលេប ហើយនិយាយថា “មិត្តនេះឈឺមែនទែនមិនមែនលេងៗទេ” ។ ព្រះអើយ! ខ្ញុំឈឺចង់ងាប់គេនៅចាំតាមដានមើលទៀត ។ លើរថភ្លើង គេចែកនំបុ័ងឲ្យម្នាក់ពីរ ទោះមានកូនតូចធំក៏ឲ្យដូចគ្នា ហើយចែកស្ករស និងទឹកស៊ីអ៊ីវឲ្យជ្រលក់ ។

ខ្ញុំហូបអ្វីក៏មិនបានអង្គុយសង្កត់តែពោះ ។ ប្តីខ្ញុំបានយកដែកកេះមួយដូរជាមួយអ្នកជិតខាងម្នាក់ យកប្រេងកូឡាវូបស្មាមួយ ប្រអប់មកលាបពោះឲ្យខ្ញុំ ។ ម៉ោង៥ល្ងាចរថភ្លើងឈប់ឲ្យបត់ដៃបត់ជើង និងដាំបាយនៅកន្លែងមួយ ។ ខ្ញុំពុំដឹងកន្លែងណាទេតែអ្នកខ្លះថាជិតដល់ភ្នំពេញហើយ ខ្លះចូលទៅភូមិជិតនោះ យកមុងឬ ខោអាវល្អៗ ដូរយកដំឡូង ៤-៥ដុំហូប ព្រោះតែឃ្លានពេក ។ គេនិយាយថាចាំយើងចូលភ្នំពេញវិញចាំទិញថ្មីក៏បាន ។ យប់ងងឹតហើយ រថភ្លើងបន្លឺស៊ីរ៉ែនឲ្យយើងទាំងអស់គ្នាឡើងវិញដើម្បីបន្តដំណើរទៅមុខទៀត ។ រថភ្លើងបរកាត់ទីក្រុងភ្នំពេញដែលមានចង្កៀងអគ្គិសនីមិនសូវភ្លឺប៉ុន្មានទេក្រោមតំណក់ទឹកភ្នែករលីងរលោងរបស់យើងគ្រប់ៗគ្នា ។ ខ្លះក៏ស្រែកទ្រហោយំ លាហើយភ្នំពេញអើយ លាហើយផ្ទះជាទីស្រឡាញ់ លាហើយមិត្តទាំងអស់គ្នា លាអ្វីៗគ្រប់យ៉ាង ហើយគ្មានសង្ឃឹមជួបអ្នកទៀតទេ ។

## ស្វាយស៊ីសុផុន

ពីរថ្ងៃកន្លង រថភ្លើងបាននាំយើងទៅដល់ស្វាយស៊ីសុផុន ។ យើងចុះពីលើរថភ្លើងដោយដៃជើងរឹងក្រញង់ស្ទើរកម្រើកពុំបាន ។ ផ្ទះឈើខ្លះថ្មនៅទំនេរទាំងអស់ពុំដឹងម្ចាស់ទៅណា ។ គេឲ្យយើងសម្រាកនៅផ្ទះណាក៏បានស្រេចតែចិត្ត ។ ក្នុងផ្ទះនីមួយៗមាន ២-៣គ្រួសារនៅជុំគ្នា ។ ពួកយើងអាចយកតុ ទូ កៅអី នៅក្នុងផ្ទះអស់នោះពុះដុតស្រេចចិត្តដើម្បីដាំបាយហូបស្រេចនឹងចិត្ត ។

ក្នុងមួយថ្ងៃគេចែកអង្ករម្នាក់ពីរកំប៉ុង ចំណែកម្ហូបយើង ត្រូវដោះស្រាយដោយខ្លួនឯង ។ ពួកយើងបានយកអង្ករ ឬអំបិលទៅដូរជាមួយប្រហុក ត្រីស្រស់ ឬត្រីងៀត នៅតាមភូមិអ្នកស្រុក ។ សម្រាកបានប្រហែលមួយអាទិត្យ អង្គការបានដើរប្រកាសប្រាប់យើងថា អ្នកណាជាជនជាតិវៀតណាម អង្គការអនុញ្ញាតឲ្យទៅស្រុកយួនវិញបាន តែត្រូវមានប្រវត្តិច្បាស់លាស់ ។ ប្តីខ្ញុំជំនុំគ្នានឹងខ្ញុំថា យើងគិតធ្វើជាវៀតណាមទៅឲ្យ តែស្រុកចាយលុយទៅណាក៏យើងមិនស្លាប់ដែរ ។ ហើយខ្ញុំបានសុំយាយយួនម្នាក់ធ្វើជាម្តាយដោយឲ្យខោអាវ២-៣កំប្លេទៅគាត់ ។

៣-៤ថ្ងៃក្រោយ គេហៅពួកខ្ញុំទៅសួរម្តងទៀត ។ គេសួរម្តាយយួនខ្ញុំថា ហេតុអីនាងខ្ញុំនិយាយខ្មែរច្បាស់ម្ល៉េះ ហើយមុខមិនដូចម្តាយសោះ? (ខ្ញុំត្រូវធ្វើជាកូនស្រីគាត់បង្កើត) ម្តាយខ្ញុំឆ្លើយថា ព្រោះខ្ញុំកើតនៅស្រុកខ្មែរ ហើយមុខមាត់កាត់តាមឪពុក

*តែតាមមើលគេមិនសូវជឿទេ ។ ចំណែកអ្នកដែលមិនបានចុះឈ្មោះជាវៀតណាម គេដឹកយកទៅដាក់តាមភូមិស្រុកអស់ហើយ នៅសល់ក្រុមយួនប្រហែល៣០ទៅ៤០គ្រួសារតែប៉ុណ្ណោះ ។ ពួកយើងនៅទីនោះប្រហែល២ខែហើយ កន្លះខែគេហៅសួរម្តង ហើយរបបអង្ករគេចែកតាមធម្មតាគ្រាន់តែពុំសូវសម្បូរម្ហូប ។ យប់មួយខ្ញុំគេងយល់សប្តិឃើញថា ខ្ញុំដើរទៅភូមិមួយជិតជើងភ្នំ សងខាងមានសុទ្ធតែដើមត្នោតទេសភាពត្រជាក់ល្អមជាទីសប្បាយរីករាយណាស់ ។*

## ភូមិស្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ឬបន្ទាយមានជ័យ

*ព្រឹកឡើងខ្ញុំមិនទាន់ទាំងចេញពីមុងផង ខ្ញុំឮខ្មែរក្រហម ស្រែកមេក្រូខាងមុខផ្ទះថា "បងប្អូនក្រុមយួនទាំងអស់គ្នារៀបចំអីវ៉ាន់ឆាប់ឡើងឡានមកយកហើយ" ។ យើងសប្បាយរីករាយណាស់រៀបចំអីវ៉ាន់លឿនៗ ចោលខ្លះយកខ្លះឲ្យតែបានទៅ ។ ឡានសណ្តោងធំៗ ៣-៤បួនបានដឹកពួកយើងកាត់តាមវាលស្រែពណ៌មាសដាច់កន្ទុយភ្នែក ។ យើងទាំងអស់គ្នានៅលើឡានខ្លះស្រែកច្រៀង ហើយខ្លះជាជនជាតិវៀតណាមពិតប្រាកដ ស្រែកច្រៀងចម្រៀងយួនយ៉ាងសប្បាយរីករាយ ។ រថយន្តដឹកយើងចូលតាមផ្លូវដីក្រហមចូលទៅក្នុងរហូតយើងឃើញភ្នំមួយ ហើយដាក់ចុះតាមភូមិខ្លះៗរហូតដល់ចុងភូមិក្រោយ គឺនៅសល់ប្រមាណតែដប់គ្រួសារប៉ុណ្ណោះរាប់ទាំងគ្រួសារខ្ញុំផង ។ គេឲ្យយើងចុះពីលើឡាន ។ មានសមមិត្ត២-៣នាក់ឈរចាំទទួលពួកយើង ។ សមមិត្តម្នាក់ចាស់ជាងគេ ប្រហែលជាធំជាងគេ បាននិយាយប្រាប់យើងថា "ក្រុមបងប្អូនយួនទាំងអស់នៅជួយធ្វើស្រែនៅទីនេះ មួយឆ្នាំសិនហើយ ចាំឆ្នាំក្រោយសឹមទៅស្រុកកំណើតវិញគង់តែជួបទេបងប្អូននោះ" ។ យើងធ្លាក់ទឹកមុខគ្រប់ៗគ្នា ខ្លះចង់ពេបបន្តិចអីបន្តិច ខ្លះនិយាយមិនចេញ ។*

*ភូមិដែលខ្ញុំនៅនោះឈ្មោះភូមិស្រះខាងជើង មានទេសភាពដូចដែលខ្ញុំយល់សប្តិពីយប់មិញ ។ ភូមិនោះស្ថិតក្នុងស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (សព្វថ្ងៃស្ថិតក្នុងខេត្តបន្ទាយមានជ័យ) ។ ពីសង្គមចាស់ អ្នកស្រុករកស៊ីដាប់ថ្មភ្នំធ្វើត្បាល់កិន ត្បាល់បុក ។ ខ្មែរក្រហមយកពួកយើងទៅដាក់នៅវត្តមួយក្បែរជើងភ្នំ មិនទាន់ឲ្យចូលភូមិភ្លាមទេ ។ គេប្រាប់ថាទ្រាំនៅទីនេះ ៤-១០ថ្ងៃសិនទៅចាំគេរកកន្លែងឲ្យនៅ ។ ពួកយើងលួចទៅមើលព្រះពុទ្ធរូបធំៗ ដែលត្រូវវាយកម្ទេចចោលនៅក្នុងព្រះវិហារ ហើយលួចថ្វាយបង្គំទាំងភ្នែកនៅកញ្ជឹងក ។*

*ព្រឹកនេះមានសមមិត្ត២-៣នាក់ស្លៀកពាក់ខោអាវខ្មៅ បង់កក្រមា ពាក់ស្បែកជើងកង់ឡាន មានស្ពាយថង់យាមម្នាក់មួយ ដើរចូលមកកន្លែងយើងសម្រាក ។ ក្នុងចំណោមនោះ ខ្ញុំស្គាល់លោកម្នាក់ពីសង្គម លន់ ណុល ពាក់សក្តិ២ ។ គាត់ធ្លាប់ទៅសម្រាកពេទ្យនៅកន្លែងខ្ញុំ គាត់ឈ្មោះ លោក លី ។ គ្រាន់តែក្រឡេកឃើញខ្ញុំ គាត់មិចភ្នែកជាសញ្ញាកុំឲ្យខ្ញុំធ្វើស្គាល់គាត់ ។ គាត់ដើរជាមួយអ្នកមូលដ្ឋាន ដែលក្នុងថង់យាមមានថ្នាំឫសឈើជាច្រើន យកទៅចែកក្រុមយួនឲ្យដាំទឹកហូបដើម្បីការពារកុំឲ្យចាញ់ទឹកចាញ់ដីក្នុងព្រៃភ្នំនេះ ។ លោក លី ធ្វើជាដើរមកជិតខ្ញុំ និយាយពន្យល់ពីថ្នាំឫសឈើនេះ ហើយខ្សឹបប្រាប់ខ្ញុំថា "កុំធ្វើស្គាល់ខ្ញុំឲ្យសោះណា៎" ខ្ញុំក៏ងក់ក្បាលអរគុណគាត់ ។ រំលងបានមួយអាទិត្យ អង្គការចែកដីឲ្យយើងធ្វើកូនខ្ទមនៅរៀងៗខ្លួន ។ យើងជួយគ្នាធ្វើផ្ទះទៅវិញទៅមកទាំងលំបាកទម្រាំបានកូនខ្ទមនៅ ។*

## ទៅរៀនសូត្រ ឬ ទៅបរលោក?

*អង្គការមិនទាន់បញ្ជាឲ្យក្រុមយួនយើងទៅធ្វើការអ្វីទេ ប្រហែលជាគេឲ្យសម្រាកយកកម្លាំងសិនក៏មិនដឹង ។ តាមពិត ក្នុងចំណោមក្រុមយួនមានសុទ្ធតែចិន ចំណែកយួនពិតប្រាកដ មានតែ២-៣គ្រួសារប៉ុណ្ណោះ ។*

*ព្រឹកនេះ សមមិត្តស្រីប្រុសក្មេងៗមុខប្លែកៗ ៤-៥នាក់ កាន់សៀវភៅម្នាក់មួយ ដើរកត់ឈ្មោះក្មេងកម្លោះក្រមុំ ដែលនៅរៀននៅឡើយ ហើយចង់រៀនបន្តទៀត អង្គការអនុញ្ញាតឲ្យទៅរៀនសូត្រវិញ ។ ប្អូនស្រីទីពីររបស់ខ្ញុំ ដែលកំពុងកាប់ដីនៅក្រោយផ្ទះ រត់មកដោយអំណរស្ម័គ្រចិត្តទៅភ្លាម ។ ក្រោយកត់ឈ្មោះ ហើយវាក៏រៀបចំខោអាវដែលមានតែ២-៣កំប្លេ ។ ខ្ញុំលួចខ្សឹប*

ប្រាប់វាថា «កុំទៅអីប្អូននៅជាមួយបងឯហ្នឹងហើយ» វាឆ្លើយថា «អត់ទេ ខ្ញុំចង់រៀន បងស្រីឃើញទេ ខ្ញុំថាទោះយ៉ាងណាក៏គេមិនបិទសាលារៀនដែរ» ។ វាហុចសាប៊ូក្រអូបម៉ាកលុច្សមិនទាន់ប្រើ មួយដុំមកឲ្យខ្ញុំហើយប្រាប់ថា «បងទុកឲ្យភ័ក្ត្រ និងស្រីស្រស់ប្រើទៅ ខ្ញុំលាហើយ» ។ រួចហើយវាក៏ឡើងរថយន្តកាំមីញ៉ុងមួយ ដែលចតចាំ និងមានយុវជនជំទង់ស្រីប្រុសប្រហែល១០នាក់រង់ចាំនៅលើនោះជាស្រេច ។ តាំងពីថ្ងៃនោះមកក៏បាត់ដំណឹងវា រហូតទៅពុំដឹងថាទៅរៀននៅមហាវិទ្យាល័យណាទេ ។

ដោយ នៅទំនេរពុំទាន់ទៅធ្វើការអ្វី ប្តីនាងខ្ញុំក៏កាប់ដីនៅក្រោយផ្ទះដាំដំឡូង ជី ស្ពៃក្រែ ដែលយើងដើរសុំពីអ្នកមូលដ្ឋាន ។ នាងខ្ញុំត្រូវប្រធានកងស្រីហៅឲ្យទៅជួយកិនស្រូវ ។ នាងខ្ញុំមានភារកិច្ចអុំអង្ករ ។ ខ្ញុំត្រូវប្រធានកងស្តីបន្ទោសពីមុខស្តីពីក្រោយព្រោះអុំអង្ករកំពប់អស់ជាច្រើន ហើយគេបញ្ជាឲ្យរើសទាល់តែអស់ទើបអាចទៅហូបបាយបាន ។ ទោះគេថាឲ្យយ៉ាងម៉េចក៏ខ្ញុំមិនតបតនឹងគេឡើយ ហេតុនេះថ្ងៃក្រោយទៅពួកគេក៏ អាណិតស្រឡាញ់ខ្ញុំគ្រប់គ្នា ។ ពេលរួចពីការងារពេលព្រលប់ ប្តីប្រពន្ធនាងខ្ញុំនិងកូនតូចៗទាំងពីរ តែងតែនាំគ្នាទៅងូតទឹកនៅស្រះជិតវត្ត ។ ប្តីខ្ញុំបានខ្ចីធុងអ្នកជិតខាងយកទៅរែកទឹកទុកប្រើផង ។ ស្អែកល្ងាចស្រាប់តែមានការប្រជុំ ។ ក្រោយពីសមមិត្តប្រធានភូមិឡើងគោរពអ៊ំ ពូ មីង បងប្អូនក្រុមយួនទាំងអស់គ្នារួចមក គាត់ណែនាំឲ្យយើងខំធ្វើការ ថ្ងៃក្រោយនឹងបានហូបគ្រប់គ្រាន់បរិបូរណ៍ ។ អស់ពីនិយាយរឿងធ្វើការគាត់ចាប់ផ្តើមទិតៀនពីរឿងសីលធម៌វិញម្តង ។ គាត់និយាយថា «អ្នកខ្លះមិនចោលរបៀបរបបចក្រពត្តិអាសអាភាស សូម្បីតែទៅងូតទឹក ក៏បណ្តើរគ្នាឲ្យត្រសងសប្បាយរីករាយណាស់ ក្នុងពេលដែលយុទ្ធជនយើងនៅកំពុងប្រយុទ្ធស៊ីសាច់ហុតឈាមគ្នាជាមួយពួកអាមេរិកនៅឡើយ» ។ និយាយដល់ត្រង់នេះ គ្រប់គ្នាងាកមើលស្រមកប្តីប្រពន្ធខ្ញុំ ។ តាំងពីថ្ងៃនោះមកពួកយើងលែងហ៊ានបណ្តើរគ្នាទៅងូតទឹកទៀត ។

ព្រឹកនេះ ប្រធានក្រុមដើរហៅពួកក្រុមយួនយើងទៅធ្វើការ គឺទៅលើកទំនប់នៅខាងក្រោយភូមិចម្ងាយប្រហែលមួយគីឡូម៉ែត្រ ។ គិតទៅក្រុមយួនខ្ញុំមកក្រោយគេតែពីរខែសោះ ប៉ុន្តែ អ្នកមកដល់មុនគេប្រៀបដូចអ្នកមូលដ្ឋាន ចំណែកពួកខ្ញុំប្រៀបដូចអ្នក ១៧មេសា ។ ពួកគេតែងលួចសើចពួកខ្ញុំដែលពុំសូវចេះធ្វើអ្វី ដូចជារែកទឹក ពុះអុស កាប់ដីជាដើម ព្រោះយើងធ្វើពុំសូវសមដូចអ្នកមូលដ្ឋាន ។ ពេលត្រឡប់មកពីលើទំនប់វិញ ម្នាក់ៗទូលអុសមួយបាច់ធំៗ ចំណែកខ្ញុំទូលសុទ្ធតែស្ពឹកត្នោតសំពីងសំពោងពេញផ្លូវទើសគេទើសឯង មើលទៅដូចជាសម្បើមណាស់ តែដាំទឹកស្ទើរមិនបានមួយកំសៀវផង ។ នៅពេលបាយគេឲ្យយើងទៅហូបនៅរោងបាយជុំគ្នានឹងប្រជាជនចាស់ដែរ ។ ពួកយើងហូបយកមួយឆ្អែត ជួនកាលក៏បបរាវជាមួយទឹកសម្ល ចំណែកអ្នកមូលដ្ឋានវិញ គេហូបតែពីរបីម៉ាត់ក៏កាន់ចានបាយដើរសំដៅទៅផ្ទះរៀងៗខ្លួន ព្រោះគេមានម្ហូបពិសេសនៅផ្ទះ ។

យូរៗខ្ញុំជួប លោកលី ម្តង ។ គាត់និយាយអ្វីនឹងខ្ញុំក៏ខ្សឹបដែរ ហើយភ្នែកក្រឡេកក្រឡាប់មើលឆ្វេងស្តាំជានិច្ច ។ រំលងពីរខែក្រោយមក ព្រឹកមួយខ្ញុំនៅធ្វើចម្ការនៅជើងភ្នំ ខ្ញុំបានឮគេនិយាយខ្សឹបខ្សៀវគ្នាថា លោក លី ត្រូវគេនាំយកទៅបាត់យប់មិញហើយ ។ កាលនោះខ្ញុំពុំដឹងហើយពុំជឿថាគេនាំមនុស្សទៅសម្លាប់ទេ ។ ខ្ញុំនឹកអាណិតប្រពន្ធលោក លី ដែលកំពុងមានផ្ទៃពោះប្រាំខែ ហើយនិងកូនស្រីម្នាក់អាយុប្រហែល៥-៦ឆ្នាំ ។ ប្រពន្ធលោកលីត្រូវគេចាត់ឲ្យទៅធ្វើស្មៅចម្ការជាមួយក្រុមខ្ញុំដែរ តែគ្មានអ្នកណាហ៊ាននិយាយរកគាត់ទេ ។

ប្រមាណមួយខែក្រោយ ខ្ញុំពុំឃើញប្រពន្ធលោកលី ទៅធ្វើការទេ ។ ខ្ញុំឮគេថាគាត់ឈឺនៅផ្ទះ ។ ពេលត្រឡប់មកពីចម្ការវិញនាពេលល្ងាច ខ្ញុំដើរកាត់ខ្ទមរបស់គាត់ ចង់ចូលសួរសុខទុក្ខគាត់ តែពុំហ៊ាន ។ ខ្ញុំឮសំឡេងថ្ងូរអ៊ូយៗចុកពោះណាស់ពីក្នុងខ្ទមកម្សត់របស់គាត់ ។ សម្រែកនោះធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែក តែពុំដឹងធ្វើយ៉ាងម៉េចអាចជួយគាត់បាន ។ ស្អែកឡើងប្រពន្ធលោក លីទទួលមរណភាព ។ ពួកឈ្លបក្មេងៗ ២-៣នាក់ បានសែងគាត់យកទៅកប់ក្នុងព្រៃជ្រៅ ។ គេនិយាយប្រាប់ពួកយើងនៅចម្ការថាមុនកប់សពលោកស្រីលី គេបានវះពោះយកកូនក្នុងផ្ទៃចេញកប់ដោយខ្លួន ព្រោះកុំឲ្យរាគត្បាតក្នុងភូមិ ។ នេះជាទំនៀមទម្លាប់របស់ប្រជាជនក្នុងភូមិនេះ ។ កូនស្រីរបស់លោក លី ត្រូវអ្នកមូលដ្ឋានយកទៅចិញ្ចឹម ហើយតាំងពីថ្ងៃនោះមក គ្រួសារលី ក៏រលាយបាត់ឈ្មោះទៅ ។

នៅក្នុងចម្ការដែលខ្ញុំទៅធ្វើស្មៅ ខ្ញុំបានជួបតាចាស់ម្នាក់ ដែលជាទាហានជំនាន់ លន់ ណុល ដែរ ។ កាលណោះគាត់ពាក់សក្តិ

*ប្រាំ តែឥឡូវគាត់ជាតាចាស់សក់ស្កូវម្នាក់យ៉ាងគគ្រិច ។ ថ្ងៃមួយគាត់លួចខ្សឹបប្រាប់ខ្ញុំថា គាត់មានខ្នុរធំមួយ ល្ងាចនេះឲ្យប្តីខ្ញុំទៅរែកទឹកនៅស្រះជិតចូលទៅយកខ្នុរនោះមកបន្ទុំទុកចែកគ្នាហូប ។ ប្តីខ្ញុំជីកដីក្នុងផ្ទះកប់ខ្នុរទុកឲ្យទុំ ។ ពីរថ្ងៃកន្លងទៅ ព្រឹកនេះ ពេលភ្ញាក់ពីព្រលឹម ក្លិនខ្នុរក្រអូបឈ្ងុយដល់ផ្លូវដើរមុខផ្ទះ ។ ប្តីខ្ញុំរញីរញ៉ៃជីកយកចេញ ហើយពុះជា ៤-៥ចំណែក យកទៅផ្ញើតាចាំចម្ការផង ។ ខ្ញុំពិតជាស្មានពុំដល់សោះថាក្លិនខ្នុរក្រអូបបានឆ្ងាយដូច្នេះ ។*

## ប្តីប្រពន្ធក្លែងក្លាយ

*ក្នុងភូមិស្រែះនេះ ខ្មែរក្រហមកំពុងតាមដានប្តីប្រពន្ធមួយគូ ដែលពុំសូវសមគ្នាជាប្តីប្រពន្ធសោះ ។ អាគា អាយុប្រហែល ១៨ឆ្នាំ ហើយប្តីវាអាយុ២០ឆ្នាំ ។ តាមពិតវាទាំងពីរនាក់នេះ ពុំមែនជាប្តីប្រពន្ធគ្នាពិតប្រាកដទេ ។ វាជាបងប្អូនជីដូនមួយនឹងគ្នា ហើយពេលវាមកនៅក្នុងភូមិនេះក៏ប្រាប់អង្គការថាប្តីប្រពន្ធទៅ ដើម្បីកុំឲ្យអង្គការបញ្ជូនទៅកងចល័ត ។ អាទី ដែលជាប្តីបានលួចខ្សឹបប្រាប់ប្តីខ្ញុំថា យប់ណាក៏វាដេកពុំដែលបានស្គាល់ស្គាល់ដែរ ព្រោះមានឈ្លបនៅចាំលួចស្តាប់យកការណ៍ពីវាទាំងពីរនាក់នោះ ។ ប្តីខ្ញុំដែលមានមាត់របុិលរប៉ូចផងក៏ប្រាប់វាថា "ម៉េចឯងមិនបើកប្រតិបត្តិការសឹកមែនទែនតែម្តងទៅ កុំឲ្យគេសង្ស័យ" អាទីវាស្រែកឡើងថា "អូ មិនបានទេ អាមួយគាកាចណាស់ យប់ណាក៏វាស្លៀកខោ៣-៤ជាន់ដែរ" ។ ប្តីខ្ញុំថា "គំរាមវាទៅណា ប្រាប់អង្គការទៅ" ។ អាទី ថា "បើដូច្នោះខ្ញុំក៏ស្លាប់ដែរ" ។ ដូច្នេះពួកវាទាំងពីរក៏ត្រូវខំលាក់អាថ៌កំបាំងនេះរៀងៗខ្លួន ទោះឈ្លោះគ្នាជេរគ្នាក៏មិនហ៊ានឲ្យអ្នកដទៃឮដែរ ។ នេះគឺចំណេះ ជិះកងឯង ។ បច្ចុប្បន្ននេះ អាមួយគា ជាថៅកែកាណូតភ្នំពេញ-ក្រចេះ ។ វាមានកូនពីរនាក់ហើយ ប៉ុន្តែប្តីវាមិនមែនជា អាទី ទេ ។*

## ស្និតសិតចៃ របស់ដែលមានតម្លៃ

*ក្នុងរបបអាវខ្មៅ ក្រៅពីអង្ករ ត្រីងៀត ប្រហុក ស្និតសិតចៃគឺជារបស់ដែលមានតម្លៃបំផុត ។ ក្នុងសម័យនោះ យើងម្នាក់ៗពុំអាចកម្ចាត់ចៃឲ្យអស់ពីក្បាលបានឡើយ ទោះជាកាត់សក់ខ្លីក៏ដោយ ព្រោះគ្មានសាប៊ូកក់សក់ ។ ម្ល៉ោះហើយ អ្នកដែលមានស្និតសិតចៃ គឺដូចជាមានដងសន្ទូចស្ទូចត្រីដែរ ។ ចែអេង គាត់មានគំនិតចេះយកស្និតសិតចៃមកតាមខ្លួនបាន២-៣ ។ អ្នកណាក៏ខ្ចីរបស់គាត់ដែរ ជួនកាលគាត់ឲ្យដោយទឹកមុខរីករាយ ជួនកាលក៏ឲ្យទាំងទើសទាល់ ។ យូរៗគាត់បែកប្រាជ្ញា បើអ្នកមកខ្ចីទាល់តែមានត្រីងៀត ប្រហុកចំហុយ ឬស្អីផ្សេងទៀតក៏បាន ឲ្យតែជារបស់ញ៉ាំ ទើបអាចខ្ចីបាន ។ បើអ្នកមូលដ្ឋានខ្ចីគាត់ពុំឲ្យទេ ។ ថ្ងៃមួយអង្គការនាំគាត់ទៅរៀនសូត្របាត់ទៅ ។ គេថាខួរក្បាលគាត់នៅជាប់កម្អែលនាយទុនច្រើនណាស់ ។*

## យាយធំដាច់ខាត

*ថ្ងៃមួយ ប្តីខ្ញុំបានប្រាប់ខ្ញុំថាគាត់ខស្សហ៍ទៅសុំទឹកត្នោត ហូបនៅកន្លែងម្ចាស់ស្ករចម្ងាយពីភូមិខ្ញុំប្រហែលមួយគីឡូម៉ែត្រប៉ុណ្ណោះ ។ កន្លែងនោះគឺសុទ្ធតែអ្នកមកពីខាងតាកែវ មកធ្វើស្ករនៅទីនេះ ហើយគេធ្វើផ្ទះស្រាស់របងនៅតែក្រុមរបស់គេប្រហែល២០គ្រួសារប៉ុណ្ណោះ ប្រៀបដូចជាបន្ទាយទាហាន ។ គេហូបតែគ្នាគេគ្មានឡូកឡំជាមួយអ្នកមូលដ្ឋាន ឬអ្នកថ្មីអីទេ គេហៅថាក្រុមដាច់ខាត ។ ប្តីខ្ញុំប្រាប់ថាគេសម្បូរថ្នាំពេទ្យណាស់ គេចង់រកពេទ្យដើម្បីចាក់ថ្នាំឲ្យក្រុមគេ ។*

*ស្អែកឡើងកណ្តាលថ្ងៃត្រង់ចែស ខ្ញុំលួចដើរតាមទំនប់ក្រោយផ្ទះសំដៅទៅក្រុមដាច់ខាត ។ យាយធំដែលជាប្រធានគេមានមុខមាំ សក់ស្កូវពេញក្បាល តែសាច់ឈាមគាត់ល្អណាស់ បង្ហាញថាគាត់ហូបចុកបរិបូរណ៍ ។ យាយធំបានយកថ្នាំ ២-៣ប្រអប់ធំៗមកបង្ហាញខ្ញុំហើយសួរថា នេះថ្នាំអី នេះថ្នាំអីខ្លះ ។ ថ្នាំ មានគ្រប់មុខតាំងពីថ្នាំគ្រុនចាញ់ ថ្នាំកម្លាំង វិតាមីនសេ ថ្នាំផ្សះ ជាដើម ។ កូនចៅយាយធំចូលចិត្តឲ្យខ្ញុំចាក់ថ្នាំណាដែលមានពណ៌ស្រស់ៗ ។ ខ្ញុំមានតែសឺរ៉ាំងកែវមួយនិងម្ជុលចាក់ ៣-៤ ប៉ុណ្ណោះ ចំណែកប្រដាប់ប្រដាពេទ្យដែលខ្ញុំយកទៅពីភ្នំពេញត្រូវអង្គការ ឆែកយកអស់តាំងពីពេលចុះពីរថភ្លើងមកម្ល៉េះ ។ ខ្ញុំដាក់ស្ងោរ*

សឹរុាំងនិងម្ចុលក្នុងថ្ដិលមួយ ហើយទឹកក្ដៅជំនួសអាល់កុល ។ ក្រោយពេលចាក់ថ្នាំរួច យាយធំបញ្ជាឲ្យកូនចៅគាត់រៀបបាយសម្លឲ្យខ្ញុំហូប ។ បាយអង្ករកិនម៉ាស៊ីនឡើងសស្គុសដូចកាកដូង ។ ខ្ញុំឱនមើលបាយចង់ដល់ចាន ព្រោះខានឃើញយូរហើយ ។ សម្លស្ងោរស្ពៃខៀវជាមួយត្រីឆ្អៀតធំៗជាប្រភេទ ត្រីរ៉ស់មកពីបឹងទន្លេសាបឆ្ងាញ់ម៉្លេះទេលោកអើយ ។ ខ្ញុំហូបចង់បែកពោះ ទោះឆ្អែតពីភូមិហើយក៏ដោយ ។ យាយធំហាមមិនឲ្យខ្ញុំយកបាយមកផ្ទះទេ ខ្លាចអង្គការដឹង ។ ទោះជាយាយធំហាមក៏ខ្ញុំនៅតែលួចយកត្រីឆ្អៀតនឹងបាយពូតដុំៗចងជាយក្រមាទុកផ្ញើកូននិងប្ដី ។ មិត្តអ្នកអានពិតជាមិនស៊ើបនឹងខ្ញុំទេមែនទេ? នៅកន្លែងដាច់ខាតនោះ មួយអាទិត្យគេធ្វើបង្អែមម្ដង ជួនកាលចេកខ្ទិះ ជួនកាលនំបាញ់ឆុកធំៗប៉ុនដៃក្រូច ។ ខ្ញុំតែងលួចចងនៅជាយក្រមាយកមកផ្ញើកូននិងប្ដីជានិច្ច ទោះគ្មានទឹកស្ករក៏ហូបឆ្ងាញ់ដែរ ។ យាយធំ ស្រលាញ់ខ្ញុំណាស់ ប៉ុន្តែគាត់ពុំសូវហ៊ានឲ្យអីខ្ញុំទេ ខ្លាចអង្គការផែកមានឃើញ រឿងដល់គាត់ ។

## កណ្ដុរស្រែ ម្ហូបពិសេស

នៅស្រុកនោះ សត្វកណ្ដុរជាម្ហូបយ៉ាងឆ្ងាញ់របស់យើងទាំងអស់ ។ ពេលថ្ងៃត្រង់សម្រាកពីការងារ យើងតែងលីចបមួយម្នាក់ ដើរទៅកណ្ដាលវាលស្រែដែលប្រូតហើយដើម្បីរករន្ធកណ្ដុរ ។ រន្ធកណ្ដុរមានទំហំល្មមតែដៃកូនក្មេងលូកបាន ។ យើងត្រូវឱនមើលសិនរន្ធនោះមានជាប់ពេបសៗឬអត់ ហើយត្រូវរករន្ធហុយរបស់វាមួយទៀតដែលនៅជិតនោះ ។ ពេលកាប់រន្ធកណ្ដុរយើងត្រូវប្រយ័ត្នវារត់ចេញតាមរន្ធហុយ ។ ហើយពេលវារត់ចេញទាល់តែរហ័សណាស់ទើបអាចវាយវាបាន ។ ខ្ញុំពុំដែលចាប់កណ្ដុរបាននឹងគេទេ ព្រោះវារត់លឿនណាស់ ក្មេងៗចេះតែឲ្យខ្ញុំម្នាក់ពីរ-បីៗ ឲ្យតែខ្ញុំដើរតាមវា ។ កណ្ដុរអាំងមានរសជាតិឆ្ងាញ់ណាស់ឆ្ងាញ់ជាងជ្រូកខ្វៃទៅទៀតសម័យនោះ ។ ប្ដីខ្ញុំខស្បាហ៍ត្រូវពិន័យឲ្យលើកដីជាច្រើនដង ព្រោះគាត់គេចទៅរកកណ្ដុរពុំព្រមទៅធ្វើការ ។ កាលនោះក៏មានអ្នកខ្លះត្រូវបាត់ខ្លួនដោយសារ តែរឿងទៅរកម្ហូបកណ្ដុរពិសេសនេះដែរ ។

អ៊ំស្រីសយ ជាអ្នក១៧មេសាដូចពួកខ្ញុំដែរ ។ គាត់ប៉ិនដឹងរឿងច្រើនណាស់ ព្រោះប្ដីគាត់ជាអ្នកបររទេះគោ ខស្បាហ៍ទៅនេះទៅនោះ ។ ព្រឹកនេះពេលបោចស្មៅចម្ការ គាត់ខ្សឹបប្រាប់ខ្ញុំថា «យប់មិញប្ដីគាត់ប្រាប់គាត់ថា ពេលទៅដឹកស្រូវនៅជើងវត្តគាត់ឮគេនិយាយពីមនុស្សម្នាក់ដែលគាត់ធ្លាប់ស្គាល់ដែរ ។ លោកនោះឈ្មោះ សឹង ភឿកថ ជាចាងហ្វាងកាសែតមាតុភូមិ ។ កាលគាត់ទៅដល់ភូមិនោះពីដំបូងគាត់ជាអ្នកមានសិទ្ធិអំណាចណាស់ ហើយមានកង់ជិះទៀត (សម័យនោះអ្នកមានកង់ជិះគឺសម្បើមណាស់) តែក្រោយមកគេដឹកគាត់ និងគ្រួសារតាមឡានយកទៅបាត់ពុំដឹងយកទៅណា ។

## ពេលរាត្រីរព្វកស្នេហ៍ច័យភ្នេខ

ពេលរាត្រីជាឋានសួគ៌របស់ប្ដីប្រពន្ធខ្ញុំ ព្រោះមានតែពេលយប់ទើបយើងនអាចរំឭកពីអនុស្សាវរីយ៍ចាស់ៗបាន ។ ក្រោមពន្លឺដួងច័ន្ទ ក្រោមដំបូលស្លឹកដែលប្រក់ដោយដៃមិនសូវប៉ិនប្រសប់របស់ប្ដីសម្លាញ់ ខ្ញុំផ្អែកកាយលើស្មាគាត់ គាត់នាំខ្ញុំរំឭកពីគ្រាមួយដែលយើងស្គាល់គ្នាគ្រាដំបូង គឺពេលលេងអង្គញ់ក្នុងសាលារៀនក្នុងពេលបញ្ចប់វិស្សមកាល ។ ប្ដីខ្ញុំហ៊ានណាស់ មុខផ្ទះខ្ញុំត្រូវក្រហូងដោយម៉ូតូរបស់គាត់ ។ ទម្រាំយើងបានជួបគ្នាត្រូវចំណាយពេលរហូតបីឆ្នាំឯណោះ ។ ប្ដីខ្ញុំរអ៊ូថា ប៉ាខ្ញុំកាចណាស់ ។ ខ្ញុំនាំប្ដីខ្ញុំនិយាយពីរឿងឆ្ងាញ់ម្ដង ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំឃ្លាននំអាកោខ្ទិះនៅក្រោយវាំង ដែលកាលណោះពេលគាត់មកពីដើរលេងជាមួយពួកម៉ាកវិញ គាត់តែងទិញផ្ញើខ្ញុំ ហើយបើត្រូវចិត្តខ្ញុំក៏ញ៉ាំ បើមិនត្រូវចិត្តខ្ញុំដាក់ចោលទាំងអស់ ។ ខ្ញុំប្រាប់គាត់ថា «ខ្ញុំស្ដាយអាកោដែលចាក់ចោលពីពេលនោះណាស់បង» ។ ប្ដីខ្ញុំអង្អែល ក្បាលខ្ញុំហើយគាត់ថា «ចាំស្អែកបងរើសត្នោតទុំធ្វើអាកោត្នោតឲ្យញ៉ាំ» ។ ប្ដីខ្ញុំនិយាយអ៊ីក៏ធូរដែរ គាត់ធ្វើមើលតែទីនោះមានសព្វគ្រប់អ៊ីចឹង ។ តែប៉ុណ្ណឹងខ្ញុំក៏ឆ្អែតដែរ ។ មានតែពេលយប់ទេដែលយើងអាចនិយាយពាក្យផ្អែមល្ហែមរកគ្នាបាន ។ ប្ដីខ្ញុំតែងតែរើសស្លឹកត្នោតដាក់ជុំវិញខ្ទមនៅពេលយប់ បង្ការក្រែងបើមានអ្នកណាដើរមកលបស្ដាប់យើងនឹងឮ ។

## មរណភាពកូនស្រីខ្ញុំ

កន្លះឆ្នាំកន្លងទៅ កូនស្រីទីពីររបស់ខ្ញុំឈឺជាទម្ងន់ វាញ៉ាំអីក៏ពុំបាន ចេះតែក្អួត ។ នៅយប់មួយនោះជាយប់ដែលខ្ញុំពុំអាចបំភ្លេចបាន ដែលមានផ្គរលាន់ រន្ទះបាញ់ ផ្លេកបន្ទោរឆ្លេចឆ្លាចគួរឲ្យខ្លាច កូនស្រីខ្ញុំក៏ទទួលមរណភាពទៅ ។ ខ្ញុំស្រែកទ្រហោយំប្រណាំងនឹងទឹកភ្លៀង "កូនស្រីមាសម្ដាយ បើនៅផ្ទះយើងវិញ ម្ដាយមិនឲ្យកូនស្លាប់បានទេ" ។ ប្ដីខ្ញុំយកដៃក្ដោបមាត់ខ្ញុំមិនឲ្យនិយាយទៀត ទាំងទឹកមុខភ័យខ្លាចលាយនឹងទឹកភ្នែក ។ គាត់ក៏ឈឺចាប់ណាស់ដែរ ប៉ុន្តែគាត់តាំងស្មារតីបានល្អជាងខ្ញុំ ។ ស្អែកឡើងអ្នកជិតខាងបានមកជួយយកសពកូនស្រីខ្ញុំទៅបញ្ចុះ ហើយពេលត្រឡប់មកវិញយើងក៏ត្រូវរកមាន់មួយមកកាប់ធ្វើបាយឲ្យគេហូប ដើម្បីជាការដឹងគុណ ។ កូនស្រីខ្ញុំស្លាប់បានបីខែ ខ្ញុំដឹងថា ខ្ញុំមានផ្ទៃពោះមួយទៀត ។ ពុទ្ធោកូនម្ដាយខំមកចាប់កំណើតអីនៅក្នុងឋាននរកហ្នឹង ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពោះរបស់ខ្ញុំចេះតែធំទៅៗ ប្រធានកងប្រធានក្រុមចេះតែដេញខ្ញុំមិនឲ្យទៅធ្វើការអស់ ។ គេថាពោះខ្ញុំជិតគ្រប់ខែហើយឈប់នៅផ្ទះចុះ តែខ្ញុំដឹងខ្លួនថា ខ្ញុំទើបតែបានប្រាំបីខែប៉ុណ្ណោះ ។ ដោយនៅទំនេរពេក ពេលគេចេញទៅធ្វើការ ខ្ញុំក៏ចេញទៅរកត្រកួនឈ្លក់ទឹកជាមួយក្មេងៗ ។ ត្រកួនឈ្លក់នៅក្នុងទឹកប្រហែលមួយម៉ែត្រ ចេញចុងតែស្លឹកបន្តិចប៉ុណ្ណោះ នៅលើទឹកទាល់តែយើងជ្រមុជចូលក្នុង ទឹកបន្តិចទើបអាចបេះវាបាន ។ ល្ងាចឡើង ខ្ញុំទូលត្រកួនមួយបាច់ធំមកផ្ទះរាល់ថ្ងៃ តែក៏ត្រូវដើរដោយប្រយ័ត្នប្រយែងដែរ ។ ខ្ញុំតែងតែរអ៊ូដាក់ប្ដីខ្ញុំដែលគាត់ឲ្យត្រកួនគេច្រើនៗពេក ។ ប្ដីខ្ញុំនិយាយថា យើងធ្វើចិត្តល្អទៅ ថ្ងៃក្រោយបើឯងមេម៉ាយវិញ ឯងក៏ប៉ះគេចិត្តល្អដូច្នេះដែរ ។ មិនស្មានថាពាក្យសម្ដីរបស់គាត់ក្លាយជាការពិតសោះ ។

## ឆ្លងទន្លេដោយគ្មានឆ្មប

យប់នេះខ្ញុំចាប់ផ្ដើមឈឺពោះតិចៗពីក្បាលព្រលប់ ដល់កណ្ដាលយប់ខ្ញុំឈឺខ្លាំងមែនទែន ។ ប្ដីខ្ញុំរវៀសរវៃរត់ទៅហៅឆ្មប ។ ថ្ងៃនោះទេសកាលអីមានបងស្រីម្នាក់មកស្ទូងនៅជិតភូមិខ្ញុំ គាត់សុំផ្ទះខ្ញុំសម្រាកពេលយប់ ។ គឺគាត់នេះហើយជាអ្នកជួយអង្អែលពោះខ្ញុំ ។ កូនប្រុសខ្ញុំអង្គុយធ្វើមុខជូរហួញនៅជិតខ្ញុំ ព្រោះថា ពុំដឹងជួយយ៉ាងម៉េច ។ មានម៉ែសយម្នាក់ទៀតដែលនៅជិតផ្ទះខ្ញុំមកជួយបង្កាត់ភ្លើងដាំទឹកឲ្យខ្ញុំ ។ មួយស្របក់ធំ ប្ដីខ្ញុំត្រឡប់មកវិញតែម្នាក់ឯង ។ គាត់និយាយដូចចង់យំ យាយហ្មបគេមិនមកមើលយើងទេ ព្រោះប្រពន្ធប្រធានភូមិហៅគាត់ទៅដែរ ព្រោះចុកពោះ (ចុកពោះធម្មតា) ។ គេទៅមើលខាងណោះហើយ ហើយគេថា ប្ដីខ្ញុំទៅនិមន្តគេដែទទេ ដូច្នេះខុសត្រណមគេ បើគេមកក៏អ្នកឆ្លងទន្លេត្រូវស្លាប់ដែរ ។ ម៉ែសយ លួចជេរដោយកំហឹង ។ គាត់យកកន្ទ្រៃមួយ ដែលយកមកពីផ្ទះរបស់គាត់ដាក់ស្មៅរ ហើយគាត់និយាយលើកទឹកចិត្តខ្ញុំថា "កុំភ័យម៉ែអាភ័ក្ត្រ ចាំខ្ញុំបង្កើតឲ្យ ខ្ញុំក៏ចេះធ្វើឆ្មបដែរ" ។ យប់នោះ ពេលជិតភ្លឺខ្ញុំក៏ឆ្លងទន្លេបានកូនប្រុសមួយ ដោយសុខសប្បាយ ។ កូនខ្ញុំថ្លោសណាស់ ប្រហែលវាត្រូវមាត់រសជាតិត្រកួនក៏មិនដឹង ។ ព្រឹកឡើង ប្ដីខ្ញុំធ្វើបបរមាន់ជប់លៀង ម៉ែសយ និងបងស្រីម្នាក់ទៀតដែលជួយខ្ញុំ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ ម៉ែសយ និងបងស្រីម្នាក់ទៀត ដែលពេលនេះពុំដឹងគាត់ទៅដល់ទីណាហើយទេ ។ ក្នុងផ្ទះខ្ញុំហុយផ្សែងទ្រលោម ព្រោះខ្ញុំអាំងភ្លើង ។ ទាំងកូនទាំងប្ដីខ្ញុំហើមភ្នែកគ្រប់ៗគ្នា ។ ព្រឹកស្អែក ប្ដីខ្ញុំសុំច្បាប់បានបីថ្ងៃ ដើម្បីមើលថែខ្ញុំ ។ ល្ងាចនេះមិនដឹងជាចង្រៃអី ខ្ញុំនឹកឃ្លានកាហ្វេ ដែលខ្ញុំពីដើមមកមិនចេះញ៉ាំផង ។ ខ្ញុំប្រាប់ប្ដីខ្ញុំទាំងអួលដើមកថា៖

– បងអើយ ខ្ញុំឃ្លានកាហ្វេណាស់ ។

ប្ដីខ្ញុំមុខជូរហួញហើយដើរចេញទៅក្រៅបាត់ប្រហែលមួយម៉ោង ។ គាត់ត្រឡប់មកវិញដោយទឹកមុខញញឹមញញែម ។ គាត់ចាប់ផ្ដើមបង្កាត់ភ្លើងហើយយកបាយក្រៀម ដែលមានសល់ប្រហែលពីរក្ដាប់ដាក់លីងចង់ខ្លោចបន្តិច ។ គាត់ចាក់ទឹកចូលដាំឲ្យពុះជាមួយបាយក្រៀមនោះ រួចដាក់ស្ករត្នោតមួយស្លាបព្រាចូល ។ ហើយគាត់ដកបានមើមស្មៅក្រវាញជ្រូកបួនប្រាំមើមលាងឲ្យស្អាតដំដាក់ចូលក្នុងទឹកពុះនោះ ។ ប្ដីខ្ញុំចាក់កាហ្វេដ៏ឆ្ងាញ់នោះចូលក្នុងត្រឡោក ហើយយកមកឲ្យខ្ញុំញ៉ាំ ដោយនិយាយថា÷

– អាបារាំងអើយ នេះហើយកាហ្វេដ៏ឆ្ងាញ់របស់យើង ញ៉ាំទៅប្រពន្ធសម្លាញ់ ។

ខ្ញុំញ៉ាំហើយមានកម្លាំងប្រឹស ។ ពុំដឹងគាត់បានមេតូតពីណាមក ។ កូនប្រុសភ័ក្ត្រខ្ញុំក៏ជណ្ដើមពីខ្ញុំញ៉ាំដែរ ។ យើងហាក់ភ្លេច

ខ្លួនថា នៅក្នុងឋាននរក ។

ស្អែកឡើង ភ្លៀងធ្លាក់ខ្លាំងពេកក៏ហូរចូលរណ្ដៅខ្ញុំអាំងភ្លើង រលត់ភ្លើងខូចរបស់ខ្ញុំអស់រលីង ។ ខ្ញុំអាណោស់ ព្រោះកំពុងតែផ្សាភ្នែកបើកពុំចង់រួចផង ។ ខ្ញុំគ្មានថ្នាំអ្វីហូប គ្មានស្រាសម្រាប់ជីកកម្ដៅសរសៃខ្ទីរបស់ខ្ញុំទេ ។ ប្ដីខ្ញុំដាំទឹកថ្នាំឫសឈើ ដែលមិនដឹងថ្នាំអ្វីខ្លះឲ្យខ្ញុំញ៉ាំ ។

រំលងបានបីខែ កូនប្រុសតូចខ្ញុំក៏ស្លាប់ទៅទៀត ព្រោះខ្ញុំគ្មានទឹកដោះឲ្យវាបៅ ។ ប្ដីខ្ញុំហួសពីគិត គាត់អង្គុយតែឱបកូនភ័ព្វខ្ញុំខ្លាចបាត់បង់វាទៀត ។

## ស៊ុបស្បែកជើងកង់ឡាន

ខ្ញុំត្រូវទៅចម្ការវិញហើយ ។ ខ្ញុំបានស្រឡះចិត្តបន្តិច ព្រោះបានជួបគ្នាឯង និងបានជជែកគ្នាលេង ។ ខ្ញុំបានជួប អ៊ំសយទៀត ហើយ ។ យើងតែងលួចហៅគាត់ថា សេ.អ៊ី.អា ។ ព្រឹកនេះពេលកំពុងបោចស្មៅពោត គាត់លួចប្រាប់ខ្ញុំដោយរីករាយថា ÷

- នែ៎ យប់មិញឪវាគាត់លួចបើកវិទ្យុស្ដាប់ ឮព្រះរាជបន្ទូលសម្ដេចឪថា... ។ រួចអ៊ំសយគាត់ធ្វើភ្នែកស្រីរកនឹក ។

មីង១ពីរ-បីនាក់ទៀតខំខិតមកជិតខ្ញុំដែរដើម្បីស្ដាប់ ។ ចៃដន្យ សមមិត្តនារីម្នាក់ដើរមកជិតខ្ញុំដើម្បីយកចបជីក ហើយក៏ស្ដីឲ្យពួកយើងថា "មីង១ទាំងអស់គ្នាម៉េចមិនធ្វើការ ចង់អត់បាយល្ងាចឬ?" យើងថយចេញពីគ្នារៀងខ្លួន ហើយចាប់បោចស្មៅតទៅទៀត ។

ពេលល្ងាចឈប់ធ្វើការ យើងដណ្ដើមគ្នាដើរជិត អ៊ំសយ ដើម្បីសួរពត៌មានក្នុងវិទ្យុ ។ អ៊ំសយ ឆ្លើយធ្វើព្រងើយថា ÷

- បានអីឮបើអាវិទ្យុចង្រៃយក៍វាដាច់ គ្រាន់តែឮព្រះរាជបន្ទូលថា "កូនចៅជាទីស្នេហា..." ។

ពួកយើងហួសចិត្ត អត់បានការអីសោះ ។ ខ្ញុំចូលក្នុងខ្ទម ឃើញនៅលើចង្ក្រានមានឆ្នាំងដាំទឹកពុះកំពុងហុយផ្សែងទ្រលោម ហើយក្នុងទឹកឃើញមានដុំស្អីខ្មៅ១ខ្ញុំមើលមិនច្បាស់ ។ ក្នុងចិត្តខំអរនឹកថា ប្រហែលប្ដីខ្ញុំបានឆ្អឹងគោ ឬក្របី យកមកស្ងោរស៊ុបហើយ ។ អាណោស់ក៏អង្គុយថែមខុសទៀតឲ្យវាឆាប់ពុះ ។ មួយស្របក់ ប្ដីខ្ញុំមកពីរែកទឹកវិញ ។ ខ្ញុំពុំទាន់សួរគាត់ទេ រង់ចាំគាត់ត្រឡប់មកពីយកធុងទៅសងអ្នកជិតខាងវិញទើបសួរគាត់ថា ÷

- ក្នុងឆ្នាំងស្ងោរអីហ្នឹងបង?

ប្ដីខ្ញុំសើចហើយឆ្លើយថា ៖ ឯងទាយមើលសាច់អី?

ខ្ញុំឆ្លើយថា ៖ សាច់ក្របី ព្រោះវាខ្មៅ ។

ប្ដីខ្ញុំសើចកាច់កកាច់ស្រង់ ហើយនិយាយថា ៖

- គឺស៊ុបកង់ឡានណ៎ា បងយកមកស្ងោរដើម្បីធ្វើស្បែកជើង ឲ្យអូន និងកូនពាក់ ទម្រាំសុំគេបានពិបាកណាស់ណ៎ា ។

អូយ ខ្ញុំខំតែអរស្មានតែបានអីឆ្ងាញ់ ដឹងអីជាកង់ឡានសោះ ។ គាត់បត់វាចេញក្រៅហើយស្ងោរប្រហែលមួយអាទិត្យដើម្បី ឲ្យវារលាបន្តិច ហើយកាត់ធ្វើស្បែកជើងឲ្យខ្ញុំ និងកូនពាក់ ។ ខ្ញុំក៏បានស្រួលជើងបន្តិច ព្រោះវាមិនឈឺជើង ។

## ភូមិបាក់ព្រា

ថ្ងៃមួយ ប្រធានភូមិបានហៅអ្នកភូមិទាំងថ្មីទាំងចាស់ទៅប្រជុំ ។ គេចង់រើសមួយភូមិពីរគ្រួសារឲ្យទៅធ្វើអាជីវកម្មត្រីនៅបាក់ព្រា ។ គេរើសយកអ្នកមានកូនតិចនិងមានមុងទើបគេឲ្យទៅ ព្រោះទីនោះមូសច្រើនណាស់ ។ ប្ដីខ្ញុំលើកដៃខ្វាច់ស្ម័គ្រចិត្តទៅភ្លាម ។ ប្រធានភូមិសួរប្ដីខ្ញុំថា ÷

- មិត្តហួត ឯង ចេះបង់សំណាញ់រកត្រីទេ?

ប្ដីខ្ញុំថាចេះ ។ ខ្ញុំកេះប្រាប់ប្ដីខ្ញុំថាមិនទៅទេ ស្ដាយកូនម្ទេស និងស្លឹកគ្រៃទើបនឹងដាំលាស់ថ្មីល្អណាស់ ។ ប្ដីខ្ញុំខ្សឹបថា កុំស្ដាយអី

របស់ប៉ុណ្ណឹងនោះ ។

យប់នោះ ប្រធានភូមិបើកសិទ្ធិឲ្យគ្រួសារខ្ញុំ និងគ្រួសារបងប្រុសមួយទៀត ដែលត្រូវទៅបាក់ព្រា អាចធ្វើមាន់ដែលជារបស់ខ្លួនឯង ដើម្បីធ្វើម្ហូបទុកហូបតាមផ្លូវ ។ ខ្ញុំមានមាន់តែពីរប៉ុណ្ណោះ តែយើងធ្វើមាន់ដល់ទៅដិតម្ភៃឯណោះ គឺរបស់បងប្អូនជិតខាង ដែលគេយកមកផ្ញើធ្វើដែរ ។ យប់នោះចង់ទើសភ្លឺ យើងហាក់ដូចជាមានពិធីជប់លៀងយ៉ាងសប្បាយរីករាយ ។ ខ្ញុំស្រមៃថាព្រឹកស្អែកនេះ គេឲ្យត្រឡប់ទៅផ្ទះវិញ ។ ស្អែកឡើង ក្រោយពីលាមិត្តភក្តិក្នុងភូមិទាំងអស់រួចមក ពីរគ្រួសារយើងក៏ចេញដំណើរទៅតាមរទេះគោ ដោយមានមិត្តឈ្លបម្នាក់ជាអ្នកជូនទៅ ។ ខ្ញុំពុំដឹងថា ភូមិបាក់ព្រានៅចម្ងាយប៉ុន្មានគីឡូម៉ែត្រទេ ប៉ុន្តែយើងត្រូវឈប់ដាំបាយហូបនៅតាមផ្លូវពេលថ្ងៃត្រង់ ហើយក៏បន្តដំណើរទៅមុខទៀត ។ យើងបត់ចូលតាមផ្លូវដីដែលមានដងស្ទឹងនៅឆ្វេងដៃ ។ ពេលល្ងាចទើបយើងទៅដល់ភូមិបាក់ព្រា ដែលមានខ្ទមវែងៗនៅលើទឹកទុកឲ្យអ្នករកត្រីសម្រាក ។ ខ្ទមអស់នោះ អាចរុះរើស្រេចនឹងចិត្តតាមទឹកឡើង ឬទឹកស្រក ។ ភូមិបាក់ព្រាសប្បាយម្ល៉េះទេ ទេសភាពត្រជាក់ល្ហឹម ពេលគេងខ្ញុំនឹកឃើញបទចម្រៀងរបស់អ្នកស្រី រស់ សេរីសុទ្ធា៖ “ឱភូមិបាក់ព្រានាពេលសូរិយារៀបលិច...” ។

នៅទីនោះ ភារកិច្ចរបស់ប្រុសៗគឺចេញទៅបង់សំណាញ់រកត្រី ។ ទៅម្តង១០-២០ទូកក៏មាន ។ ប្តីខ្ញុំក៏ចេញទៅជាមួយនឹងគេដែរ ពុំដឹងគាត់ធ្វើបាន ឬពុំបានទេ តែនាងខ្ញុំដឹងថា គាត់ឆ្លាត គាត់ពិតជាអាចរៀនសូត្រពីគេបាន ។ ពេលទូកត្រឹមកវិញមានមនុស្សវាយជួងជាសញ្ញា ហើយក្រុមស្រីៗក៏កាន់កាំបិត និងចានគោមធំៗសម្រាប់ដាក់ពងត្រី ដើរសំដៅទៅរោងនៅមាត់ទឹកដើម្បីធ្វើត្រី ។ ទូកមកដល់ពេលណាគឺត្រូវឡើងធ្វើត្រីពេលនោះ ជួនកាលម៉ោងមួយ ឬម៉ោងពីរយប់ក៏មាន ។

ស្រុកនោះសម្បូណ៌មូសណាស់ ។ ប្រជាជនដុតភ្នក់ភ្លើងគ្រប់ទិសទីក៏នៅតែមានមូសដូចឃ្មុំ ។ ខ្ញុំធ្វើត្រីបណ្តើរ ដៃទះមូសបណ្តើរ ទម្រាំតែជិតភ្លឺទើបបានចូលសម្រាកនៅក្នុងខ្ទម មូសខាំក្រហាយពេញខ្លួន ។ ខ្ញុំពុំសូវប្រសប់ធ្វើត្រីទេ អ្នកផ្សេងបានពងត្រីពេញៗចាន ចំណែកខ្ញុំបានតែកន្លះចានប៉ុណ្ណោះ ។ យើងហូបពងត្រីទាល់តែរាកគ្រប់គ្នា ។

## ជំងឺគ្រុនចាញ់

គ្រួសារខ្ញុំនៅភូមិបាក់ព្រាបានប្រមាណកន្លះខែ ។ ថ្ងៃមួយ ខ្ញុំចាប់ផ្តើមឈឺគ្រុនក្តៅយ៉ាងខ្លាំង ។ មួយអាទិត្យកន្លងផុតហើយជំងឺរបស់នាងខ្ញុំមិនបានធូរស្រាលសោះ ។ ខ្ញុំដឹងថាប្រហែលជាគ្រុនចាញ់ហើយ ។ ខ្ញុំញ៉ាំបាយមិនបាន ស្រេកតែទឹក ហើយនឹកឃ្លានម្ជូរជាខ្លាំង ។ ប្តីខ្ញុំដាច់ចិត្តទៅរោងបាយ សុំម្ជូរសណ្តាន់ពីចុងភៅបានពីរ-បីចំណិត និងអំបិលគ្រួសបាន៤-៥គ្រាប់យកមកឲ្យខ្ញុំ ។ ខ្ញុំត្រេកអរណាស់ដូចបានផ្លែឈើទិព្វពីសួគ៌ាមកញ៉ាំ ។ ស្ថានភាពជំងឺរបស់ខ្ញុំគ្មានស្រាកស្រាន្តសោះ ។ ខ្ញុំគ្មានថ្នាំអ្វីញ៉ាំសោះ សូម្បីតែឫសឈើឫសព្រៃក៏គ្មាន ព្រោះទីនោះគ្មានគ្រូឱសថបុរាណ ឬពេទ្យអីទេ ។ ព្រឹកនោះ ប្តីខ្ញុំសម្រេចចិត្តដឹកដៃខ្ញុំទៅសុំប្រធានកងប្រធានក្រុមខាងអាជីវកម្មនេះ ដើម្បីត្រឡប់មកភូមិវិញ ។ ខ្ញុំស្លៀកសំពត់ផាឱបសជ្រលក់ភក់ស្ទើរពុំចង់ជាប់ព្រោះគ្មានជាតិបាយក្នុងខ្លួនសោះ ។ ប្រធានកងប្រធានក្រុម ពីរ-បីនាក់ស្តីឲ្យខ្ញុំ និងប្តីថា គ្មានការតស៊ូអត់ធ្មត់ដូចគេគ្រប់ៗគ្នាសោះ ។ គេអនុញ្ញាតឲ្យគ្រួសារខ្ញុំត្រឡប់មកភូមិវិញ ប៉ុន្តែគេដកយកមុងភួយសម្រាប់ទុកឲ្យអ្នកក្រោយ ។ បងហួត គ្មានគិតអ្វីទាំងអស់ឲ្យតែគេឲ្យទៅវិញ យកអីក៏យកចុះ ។ មេក្រុមចាត់មនុស្សជូនដំណើរយើងតាមទូកមកដល់ផ្លូវកៅស៊ូខាងក្រៅ ហើយទុកឲ្យយើងដោះស្រាយការធ្វើដំណើរបន្តទៀតព្រមទាំងបាយទឹកដោយខ្លួនឯង ទាំងយើងគ្មានអង្ករមួយគ្រាប់ជាប់ខ្លួនផង ។ គេប្រាប់ថាបើយើងទៅដល់ភូមិណា ចូលសុំគេភូមិនោះទៅ គេមិនចិត្តអាក្រក់ទេ ។ តាមពិត គ្មានភូមិណាគេអាណិតអាសូរយើងឡើយ សូម្បីតែបាយក្តាំងក៏មិនឲ្យដែរ ។ គេថាគ្រប់គ្រាន់សម្រាប់តែប្រជាជនភូមិគេប៉ុណ្ណោះ ។ មកដល់ផ្លូវធំ មេឃចាប់ផ្តើមងងឹត ហើយភ្លៀងរលឹមតិចៗ ។ ប្តីប្រពន្ធនាងខ្ញុំនិងកូនប្រុស នាំគ្នាចូលជ្រកក្នុងផ្ទះឈើមួយដែលនៅដាច់តែឯង ។ ប្រុសភ័ក្ត្រ កូនប្រុសជាទីស្រលាញ់របស់នាងខ្ញុំ មុខស្លេកស្លាំងព្រោះតែការស្រេកឃ្លាន តែវាគ្មានថ្ងូរមួយម៉ាត់ ។ គួរអាសូរកូនណាស់ រយៈពេលប្រហែលពីរឆ្នាំធ្វើឲ្យកូនប្រុសខ្ញុំចេះមានការតស៊ូ ។ (នៅវេលាដែលខ្ញុំសរសេរដល់ត្រឹមនេះខ្ញុំទម្លាក់ស្លាបប៉ាកាចុះ ព្រោះទឹកភ្នែកបានហូរ

ជន់ដោរក្នុងរន្ធង់វែនតា កាត់ដែនផ្ទាល់រ័យចំណាស់របស់នាងខ្ញុំ) ។

ផ្ទះដែលខ្ញុំចូលជ្រក គឺជាផ្ទះយោធាស្នាក់នៅ ។ មានមិត្តយោធាក្មេងម្នាក់អាយុប្រហែល២០ទៅ២៥ឆ្នាំ ដើរមកសួរដំណើរដើមទងអំពីពួកយើង ។ សមមិត្តប្អូននោះ ដូចជាមានចិត្តអាណិតអាសូរពួកយើង ក៏ដើរទៅក្រោយហើយដួសបាយមួយចានធំ ព្រមទាំងមានសម្លម្ជូរត្រកួនដាក់ពីលើផង មកហុចឲ្យប្ដីខ្ញុំហើយប្រាប់ថា ÷

- អស់ហើយមានតែប៉ុណ្ណេះទេ ហូបទៅ ។

ប្ដីខ្ញុំគាត់លូកដៃទទួលដោយអំណរហើយបញ្ចុកខ្ញុំមុន តែខ្ញុំគ្រវីក្បាលហូបមិនកើត ព្រោះល្ងឹងមាត់ខ្លាំងពេក ។ យុវយោធាឃើញដូច្នេះក៏សួរថា ÷

- មិត្តនារីឯងកើតអី?

ខ្ញុំឆ្លើយថា ខ្ញុំគ្រុន៨-១០ថ្ងៃហើយមិត្ត ។ ឮដូច្នេះ មិត្តយោធាបានចូលទៅយកថ្នាំគ្រាប់គេត្រារបស់ចិនពណ៌លឿងមួយគ្រាប់ហុចឲ្យខ្ញុំលេប ហើយប្រាប់ថា «យប់នេះនៅសម្រាកទីនេះហើយ ចាំស្អែកព្រែកមានឡានយោធាគេត្រូវទៅផ្លូវនោះ ចាំខ្ញុំសុំឲ្យដោយសារ» ។

ខ្ញុំលេបថ្នាំហើយក៏សម្រាកនៅលើក្ដារឿជិតនោះទៅ ព្រោះអស់កម្លាំងពេក ។ កណ្ដាលយប់ស្ងាត់ ខ្ញុំភ្ញាក់ឡើងព្រោះស្រេកទឹកពេក ។ ខ្ញុំដើរសរសៀរស្ទាបៗទៅរកពាងទឹក ហើយក៏យកទឹកញ៉ាំមួយចម្អែត ។ ខ្ញុំយល់ថា យប់នោះខ្ញុំញ៉ាំទឹកអស់ប្រហែលកន្លះពាងហើយមើលទៅ ។ ទឹកភ្លៀងត្រជាក់ផ្អែមឆ្ងាញ់ម្ល៉េះទេ ។ ក្នុងអារម្មណ៍ខ្ញុំគិតថា ខ្ញុំកំពុងញ៉ាំទឹកក្រូចប៉ិបស៊ីទៅវិញ ។

ព្រឹកឡើង ប្ដីប្រពន្ធខ្ញុំនិងកូនប្រុសភ័ក្ត្របានសុំដោយសារឡានយោធាមួយ ។ អ្នកបើកឡានដាក់យើងនៅភូមិជើងវត្តស្រុកព្រះនេត្រព្រះ ទាល់តែដើរចូលទៅក្នុងជ្រៅ៨-៩គីឡូម៉ែត្រ ទៀតទើបដល់ភូមិស្រែះដែលខ្ញុំធ្លាប់រស់នៅ ។ យោធាទាំងអស់នោះប្រាប់ខ្ញុំថា នៅសម្រាកពេទ្យទីនោះហើយ ចាំធូរស្រួលបួលសឹមវិលទៅភូមិចាស់វិញ ។ ពេទ្យធ្វើការនៅក្នុងវត្តតែម្ដង ហើយភូមិអ្នកស្រុកចាស់-ថ្មីក៏នៅជាប់ៗនឹងពេទ្យនេះដែរ ។ ខ្ញុំចូលសម្រាកពេទ្យបានពីរ-បីថ្ងៃ ។ រីឯថ្នាំសម្រាប់ព្យាបាលជំងឺខ្ញុំគឺគ្រាប់ធំៗខ្មៅៗដូចអាចម៍ទន្សាយ ដែលកម្មាភិបាលពេទ្យចែកឲ្យលេបរាល់ថ្ងៃ ។ ខ្ញុំសង្កេតឃើញថា ឈឺយ៉ាងម៉េចក៏ចែកតែថ្នាំមួយប្រភេទហ្នឹងដែរ ។ អ្នកត្រូវជាក៏ជាអ្នកមិនជាគឺស្លាប់ ។ រំលងបានបី-បួនថ្ងៃក្រោយមកខ្ញុំបានធូរស្រាលបន្តិច ហើយខ្ញុំនឹកឃ្លានចំណីតែផ្អែសតែផ្ដាស ។ ព្រឹកនេះខ្ញុំប្រាប់ប្ដីខ្ញុំថា ខ្ញុំឃ្លានដំឡូងមីជាខ្លាំង ។ បងហួត ក៏ធ្វើដំណើរទៅភូមិស្រែះដែលជាភូមិចាស់ធ្លាប់រស់នៅ ។ ល្ងាចឡើង ប្ដីខ្ញុំត្រឡប់មកវិញជាមួយដំឡូងមីមួយកូនដុំ ដែលឆ្អិនស្រាប់ ។ ខ្ញុំបេះឲ្យកូនខ្ញុំខ្លះ និងឲ្យប្ដីខ្ញុំខ្លះ តែគាត់ថា បានពិសានៅតាមផ្លូវខ្លះហើយ ។ ប្ដីខ្ញុំបានខ្សឹបប្រាប់ខ្ញុំដោយញ័រមាត់ថា ៈ អាបារាំងអើយ ពួកក្រុមយួនដែលនៅភូមិស្រែះ គេយកទៅណាបាត់អស់ហើយ ប្រហែល២០គ្រួសារឡើងស្ងាត់ភូមិ ។ ក្រោយយើងចេញទៅធ្វើអាជីវកម្មត្រីប្រហែលមួយអាទិត្យប៉ុណ្ណោះ ។ គេយកទៅគឺមានរបៀបរបស់គេ ។ ដំបូងគេហៅប្រុសៗដែលទើបមកពីចម្ការឲ្យទៅប្រជុំនៅចុងភូមិ ព្រោះមានការសំខាន់ ។ (ដល់ត្រង់នេះ ប្ដីខ្ញុំដកដង្ហើមដូចជាហត់ណាស់ទើបគាត់បន្ត) ខ្លះនៅតែខោខ្លីប៉ុណ្ណោះ ។ រួចគេក៏ដើរហៅស្រីៗដែលនៅផ្ទះឲ្យរៀបចំអីវ៉ាន់ និងកូនចៅចេញដំណើរទៅតាមរទេះគោ ព្រោះប្រុសៗនៅរង់ចាំឯចុងភូមិជាស្រេច ។ ប្ដីខ្ញុំបន្តថា ៈ អ៊ីគា ដែលគាត់មានផ្ទះនៅជាប់នឹងផ្ទះយើង (ពីសង្គមចាស់គាត់ជាថៅកែសាំង) ប្ដីគាត់ជាអ្នកកប់មាសប្រាក់នៅក្នុងផ្ទះនោះ (ផ្ទះផ្ទាល់ដី) ។ អ៊ីគា គាត់ពុំដឹងនៅត្រង់ណាទេ ដល់គេបង្ខំឲ្យចេញភ្លាមៗដូច្នេះគាត់រកពុំឃើញ ក៏ដាច់ចិត្តប្រាប់ប្រធានភូមិឲ្យជួយរក ។ តែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ខ្ទមអ៊ីគា ក៏រលាយអស់រលីង នៅតែរកមាសពុំឃើញ ។ ទោះជាគេនាំគ្នាកាប់គាស់ដីក្នុងផ្ទះយ៉ាងណាក៏ដោយ ក៏រកពុំឃើញដែរ ។

ខ្ញុំព្រឺក្បាលខ្វាក ។ នេះជាសំណាងមួយក្នុងមួយម៉ឺនមួយលានគ្រោះថ្នាក់ ។ ដូច្នេះវាសនាក្រុមយួនអស់នោះរួមទាំងក្មេងៗក្នុងអង្រឹងផង ពុំដឹងក្លាយទៅជាយ៉ាងណាទេ ។ ថ្ងៃក្រោយមកទៀត ខ្ញុំឮពាក្យចចាមអារ៉ាមថា ក្រុមយួនគេដាក់កាណូតទៅដល់

កណ្តាលទន្លេ គេចាក់មេក្រូពូៗ ហើយពន្លិចកាណូតនោះចោលតែម្តង ។

តាំងពីថ្ងៃនោះមក ខ្ញុំក៏ក្លាយទៅជា នាងណាង វិញ ឬ ម៉ែអាភ័ក្រ្ត ចំណែកប្តីខ្ញុំក៏ជា មិត្តហួត វិញដដែល ។ បី-បួនថ្ងៃក្រោយមកទៀត យើងបានជួបនឹង អ៊ីរី ដែលត្រូវជាបងប្អូនប្តីខ្ញុំដែរ ។ គាត់រស់នៅភូមិដើងវត្តនេះ ។ គាត់ត្រេកអរណាស់ ដែលបានជួបពួកយើង ។ គាត់បានឃាត់យើងឲ្យរស់នៅភូមិនេះ ជាមួយគាត់ ។ យើងក៏បានចូលនៅភូមិដើងវត្តនេះវិញក្រោយពី អ៊ីរី បានទៅសុំប្រធានភូមិនេះបានហើយ ។

## ពុកក្រក ប្រធានសហករណ៍

ភូមិដែលខ្ញុំរស់នៅក្រោយនោះគេច្រើនហៅថា ភូមិបច្ចេក ទេសមេម៉ាយ ព្រោះប្រុសៗដែលសុទ្ធតែជាអ្នកបច្ចេកទេសឬវេជ្ជបណ្ឌិត ត្រូវអង្គការយកទៅអស់ហើយ នៅសល់តែប្រពន្ធប៉ុណ្ណោះ ។ ក្នុងចំណោមនោះ ខ្ញុំជួបមិត្តចាស់ម្នាក់ឈ្មោះ សោភា ដែលធ្វើការនៅក្នុងមន្ទីរពេទ្យព្រះមុនីវង្ស ជាមួយគ្នា ។ សោភា ធ្វើការនៅផ្នែកត្រចៀក ច្រមុះ បំពង់ក ។ ប្តីរបស់ សោភា ក៏ជាវេជ្ជបណ្ឌិតដែរ គឺលោក ទក កាន ដែលអង្គការយកទៅរៀនសូត្របាត់ហើយ ។ សោភា រស់នៅជាមួយកូនប្រុសម្នាក់អាយុ ៥ឆ្នាំ ។ ក្នុងភូមិនោះ ប្រុសៗដែលមានវាសនាត្រឡប់មកជួបជុំប្រពន្ធកូនវិញមានតែបីនាក់ប៉ុណ្ណោះ ។ ទីមួយគឺលោក ឌីណា ដែលគាត់ជាអ្នកបច្ចេកទេសខាងអគ្គិសនី ។ ថ្ងៃនោះគាត់ឈឺជើងមិនរួច ហើយប្រពន្ធគាត់ឈ្មោះ ប្រណី ជាកូនកាត់លាវ ។ អ្នកទីពីរគឺលោកវេជ្ជបណ្ឌិត ជី ដែលមិនដឹងជាគាត់និយាយយ៉ាងម៉េចត្រូវចិត្តអង្គការ ទើបពីរថ្ងៃក្រោយមកគាត់បានត្រឡប់មកវិញទៅ ប្រពន្ធគាត់គឺបងសំឡី ដែលគាត់មានសម្តីផ្អែមល្ហែមគួរឲ្យស្រលាញ់ ។ គាត់គឺជាអ្នកគ្រូពីសង្គមចាស់ ។ ម្នាក់ទៀតគឺ អ៊ំសារ៉េត ពីសង្គមចាស់គាត់ធ្វើការនៅស្ថានីយរថភ្លើង ។ អ៊ំសារ៉េត ត្រូវនាំយកទៅបានពីរថ្ងៃក៏ត្រឡប់មកវិញ ។ គាត់បានលួចប្រាប់កូនគាត់ទាំងបីនាក់ (ស្រីមួយប្រុសពីរ) ថា ៖ «ពួកឯងត្រូវចាំណា៎ បើគេហៅទៅសួរថាចង់មានសំណូមពរអ្វីទេ ពួកឯងត្រូវឆ្លើយដោយគោរពថា គ្មានទេសមមិត្តបង ។ តិចពួកឯងសំណូមពរឲ្យមានសាលារៀន មានទីផ្សារ មានវត្តអារាម គឺពួកឯងគ្មានវាសនាត្រឡប់មកវិញទេពូហើយឬនៅ?» ។

កូនគាត់ទាំងបីក៏ងក់ក្បាលទាំងពុំសូវយល់ពីមូលហេតុ ។ អង្គការតម្រូវឲ្យគ្រួសារខ្ញុំចូលរស់នៅក្នុងផ្ទះឈើធំមួយ ដែលមានបងស្រី ម៉ែអាទូ មេម៉ាយកូនពីរ និងប្អូនស្រី សូដា មេម៉ាយដែរ មានកូនបីនាក់ (ប្រុសពីរស្រីមួយ) ។ បងស្រី ម៉ែអាទូ ចូលចិត្តប្តីប្រពន្ធខ្ញុំណាស់ ហើយ អាទូ កូនច្បងរបស់គាត់ដែលមានអាយុ ៨ឆ្នាំ និងអាពៅ អាយុ៧ឆ្នាំ ក៏ស្រលាញ់ចូលចិត្តកូនភ័ក្រ្តខ្ញុំដែរ ។

បងស្រី ម៉ែអាទូ មានសំឡេងពីរោះណាស់ ។ យប់ណាក៏ គាត់និងខ្ញុំអង្គុយលេងនៅកាំជណ្តើរ ហើយគាត់តែងច្រៀងបទចម្រៀងពីសង្គមចាស់ដូចជា បទសំបុត្រក្រោមខ្នើយ បទបង្អួចរាត្រី ដែលច្រៀងដោយអ្នកស្រី ហ៊ួយ មាស ។ បងស្រីច្រៀងលន្លង់លន្លោចពីរោះណាស់ ។ ខ្ញុំអង្គុយផ្អែកលើស្មាគាត់ហើយ មានអារម្មណ៍ថាដូចជានៅក្នុងភោជនីយដ្ឋានណាមួយ ជួនក៏យំជួនក៏សើច ជាមួយគាត់ តែយើងដឹងថាមានទស្សនិកជនពីរ-បីនាក់ឈរស្ងៀមៗចាំស្តាប់យើង ។ យប់ស្អែកឡើងក៏ចេះតែមានទស្សនិកជនកាន់តែច្រើនឡើងឈរលួចស្តាប់ចម្រៀងគ្មានភ្លេងរបស់យើង ។

ល្ងាចនេះនៅពេលបាយ ស្ត្រីអ្នកមូលដ្ឋានម្នាក់មានអាយុ ប្រហែល៤០ឆ្នាំ ធ្មេញបាក់ជួរខាងមុខអស់ សម្តីគំរោះគំរើយបានដើរប្រកាសថា ៖ បងប្អូនទាំងអស់គ្នាហូបបាយហើយទៅប្រជុំ នៅទីធ្លាវត្ត ។

ក្រោយពីជួបជុំគ្នាហើយ សមមិត្តដែលជាប្រធានក្នុងអង្គ ប្រជុំបានបើកអង្គប្រជុំ ។ ជាដំបូងគេគោរពពុក-ម៉ែ បងប្អូនមាមីង ហើយគេក៏និយាយដាស់សតិអារម្មណ៍យើងឲ្យខំធ្វើការ មួយហិកតាឲ្យបានប្រាំតោន ថ្ងៃក្រោយយើងនឹងសំបូរសប្បាយមិនខ្វះហូប ទឹកភ្លើងអគ្គិសនីប្រើគ្រប់គ្រាន់ សូម្បីតែជណ្តើរបង្គន់ក៏មានភ្លើងដែរ សម្លៀកបំពាក់ក៏មិនខ្វះស្លៀកពាក់ដោយមិនចាំបាច់ចាយលុយ ។ ពួកយើងក៏បង្ហុំចិត្តត្រូវតែទះដៃឲ្យបានខ្លាំងៗ ។ អស់ពីនិយាយរឿងសម្បូរសប្បាយ ចូលដល់រឿងអប់រំរឿងកសាង រឿងសីលធម៌ ។ គេនិយាយរបៀបគំរាមបន្តិច សម្លុតបន្តិច ។ សមមិត្តនិយាយបន្តឹងសំឡេងរាងកាចមិន

*ផ្អែមដូចរគ្គមុនសោះថា ៖ មានមិត្តនារីខ្លះមួយចំនួនប៉ុណ្ណោះ មិនភ្លេចវប្បធម៌សក្តិភូមិ មូលធននិយម ពេលយប់ឡើងនៅលួចច្រៀងលួចនិយាយរឿងកុនល្ខោន ដែលជាប្រពៃណីមិនល្អ (ដល់ត្រង់នេះ បងស្រីម៉ែអាទូ លួចកេះខ្ញុំខ្លាច់) ។ សមមិត្តបន្តទៀតថា មានមិត្តនារីខ្លះទៅហូបបាយនៅរោងបាយស្លៀកពាក់មិនសមរម្យឡើយ ។ ខ្លះពាក់អាវកវាលធំៗ ដើម្បីចង់ពន្ធក់អារម្មណ៍អ្នកដួសបាយឲ្យភ្លេចខ្លួន ប្រទ្បំហើយមិត្តនារីអើយ សមមិត្តប្រុសៗយើងមិនលង់នឹងសម្រស់មិត្តឯងទេ ត្រូវកសាងខ្លួនឲ្យល្អឡើងវិញ ស្លៀកពាក់ឲ្យជិតៗ ។*

*នៅតាមផ្លូវត្រឡប់មកផ្ទះវិញ បងស្រី ម៉ែអាទូ និយាយលេង សើចនឹងខ្ញុំថា ÷*

*– ពួកវាពូកែតែមាត់ទេ តែពួកប្រុសៗមូលដ្ឋានវាតែងលួចមើលយើងគ្រប់ៗគ្នា... ។*

*ខ្ញុំសួរបងស្រីថា អ្នកណាដែលច្រើនពាក់អាវកធំៗទៅញ៉ាំបាយល្ងាច ។ បងស្រីថា គ្មានអ្នកណាក្រៅពី កល្យាណ ទេ វាមេម៉ាយកូនមួយ អ៊ីរី នៅជាមួយវាមើលកូនឲ្យវា ។ កល្យាណ ជាអតីតសិស្សវិទ្យាល័យដេកាត ហើយវាក្រឡុកពួកមូលដ្ឋានឲ្យជ្រួលដោយសារវាច្រើនដងហើយ ។*

*ព្រឹកនេះពីព្រលឹមស្រាងៗ យើងរៀបបាយកញ្ចប់គ្រប់ៗ គ្នាដើម្បីទៅចម្ការគាស់ដំឡូង ។ ចម្ការនៅលើភ្នំមានចម្ងាយប្រហែលពីរគីឡូម៉ែត្រពីភូមិដែលយើងរស់នៅ ។ ចំណែកប្តីខ្ញុំ ទៅលើកទំនប់នៅភូមិខាងជើងជាមួយក្រុមប្រុសៗ ។ នៅតាមផ្លូវទៅចម្ការដែលនៅលើភ្នំ ខ្ញុំបានស្គាល់មិត្តថ្មីជាច្រើនទៀត ហើយនិង កល្យាណ ។ យើងដូចមាននិស្ស័យនឹងគ្នាណាស់ ស្គាល់គ្នាភ្លាមចូលចិត្តគ្នា និយាយរកគ្នាលេងសើច ហើយចូលចិត្ត និយាយរឿងតែពីសង្គមចាស់ល្មមតែគេកសាងមិនខុសមែន ។ នៅលើភ្នំខ្ញុំគាស់ដំឡូងមិនសូវបានល្អនឹងគេទេ តែទោះគេស្តីថា ឲ្យយ៉ាងណាក៏ខ្ញុំមិនត គិតតែធ្វើការ ហើយទន្ទេញពាក្យដែលប្តីខ្ញុំប្រាប់ថា “តស៊ូទើបរស់” ។ ល្ងាចឡើង យើងត្រឡប់មកផ្ទះដោយ មានទូលដំឡូងដែលយើងលួចបន្ទំបានដាក់ក្នុងកញ្ជើគ្របដោយស្លឹកដំឡូងជ្វា ។ យើងដើរបណ្តើរជជែកគ្នាបណ្តើរ ។*

*មកដល់ផ្ទះឈើស្អាតមួយ ខ្ញុំសួរអ្នកដើរជាមួយថា ផ្ទះ អ្នកណាស្អាតម្ល៉េះ? បងស្រីម្នាក់ថា គឺផ្ទះពុកក្រេក មេប្រធានសហករណ៍យើង ។ មួយខែកន្លងផុត ព្រឹកនេះនៅក្នុងចម្ការដំឡូង ក្រោមកម្តៅព្រះអាទិត្យក្តៅហែង មានជនម្នាក់ដើរចូលមកក្នុងចម្ការដោយដំណើរយ៉ាងស្វាហាប់ មានទឹកមុខញញឹមស្រស់ស្រាយ អាយុប្រហែលចន្លោះពី៤៨ទៅ៥០ឆ្នាំ ។ បងស្រី ម៉ែអាទូ ប្រាប់ខ្ញុំថា នោះគឺ ពុកក្រេក ហើយប្អូនណាង ។ ខ្ញុំមើលមុខគាត់ដូចជាស្លូតទេ ។ បងស្រីម្នាក់ដែលនៅក្បែរខ្ញុំពេបមាត់ថា ៖ ចា៎ស ស្លូតល្អណាស់ សម្លាប់មនុស្សដូចសម្លាប់សត្វអ៊ីចឹងនាងអើយ ។ ខ្ញុំបះសក់ប្រួង ។*

## **សោកនាដកម្មស្នេហាមួយ**

*យប់នេះក្រោយពេលបាយរួច បងស្រី ម៉ែអាទូ និងប្អូនស្រីសួថា បានអង្គុយលេងជាមួយខ្ញុំ ។ បងស្រីងាកមើលឆ្វេងស្តាំឱនមើលក្រោមផ្ទះព្រោះខ្លាចជញ្ជាំងមានត្រចៀក ហើយគាត់ និយាយរឿងពុកក្រេក ឲ្យខ្ញុំស្តាប់ ។ បងស្រីនិយាយថា ÷*

*– ឯងកុំឃើញមុខញញឹមៗថាគាត់ស្លូតនោះ សាហាវជាងខ្លាទៅទៀត ។ កាលពីបី–បួនខែមុនមានរឿងស្នេហាមួយយ៉ាងអាណោចអាធ័មបំផុត ។ ប្រុសជាអ្នកមូលដ្ឋាន ហើយស្រីជាអ្នក ១៧មេសា តែទាំងពីរនាក់សុទ្ធតែមានប្តី–ប្រពន្ធរៀងៗខ្លួន ។ ប្រុស–ស្រីពីរនាក់នោះបានលួចស្រលាញ់គ្នា ហើយលួចយកគ្នាដោយលួចលាក់រហូតមានផ្ទៃពោះបី–បួនខែ ។ នៅពេលគេឲ្យទៅដេកលើកទំនប់នៅក្រៅភូមិ យប់មួយនោះអ្នកទាំង២បានលួចជួបគ្នា ហើយត្រូវប្តី–ប្រពន្ធទាំងសងខាងចាប់បាននាំទៅប្តឹងប្រធានភូមិ ។ ស្អែកឡើង គេបានយកអ្នកទាំងពីរមកកាត់ទោសនៅក្នុងទីធ្លាជើងវត្តនេះ ។ (បងស្រីចង្អុលដើមអម្ពិលបារាំងពីរដើមដែលគេចងអ្នកទាំងពីរ) គេចងពីរនាក់នោះទល់មុខគ្នា ហើយគេហៅប្រជុំអ្នកភូមិអ្នកស្រុក ទោះទៅធ្វើការនៅទីឆ្ងាយឯណាក៏ដោយ ក៏គេហៅមកដែរ ។*

*ប្អូនស្រី សូដា និយាយកាត់ថា ÷ កាលណោះពួកយើងខំ តែអរ ស្មានតែគេហៅមកដើម្បីឲ្យរៀបចំខោអាវត្រឡប់ទៅ*

ភ្នំពេញវិញ ។ (ពុទ្ធោ ពីរឆ្នាំថ្លាយហើយយើងនៅតែរស់ក្នុងក្ដី ស្រម័យជានិច្ច) ។ តែតាមពិតគេហៅមកជួយកាត់ទោសជនផិតក្បត់សោះ ។ ពុកក្រុក ឡើងលើវេទិកាមួយខ្ពស់ ហើយស្រែកសួរពួកយើងទាំងអស់គ្នាតើត្រូវកាត់ទោសជនក្បត់ពីរនាក់នេះយ៉ាងម៉េច? ស្ងាត់ច្រៀបគ្មានអ្នកណាឆ្លើយ មានតែប្រុសៗ អ្នកមូលដ្ឋានពីរ-បីនាក់ស្រែកថា កម្ទេចចោលៗ ។ ពុកក្រុក ស្រែកបន្ទរតាមក្រោយ ទឹកមុខកាចសាហាវ ហើយឲ្យពួកយើងលើកដៃ បើអ្នកណាមិនលើកគឺចូលដៃនឹងខ្មាំងដែរ ។ ទាំងអស់គ្នា ក៏បន្ទំលើកដៃទាំងទើសទាល់ ។ ក្រោយពីអង្គប្រជុំសម្រេចហើយ ពុកក្រុក ក៏ចុះពីលើវេទិកា ដៃកាន់ចបជីកមួយ ដើរសំដៅអ្នកទោសប្រុស ហើយសួរថា៖ “មិត្តឯងមានយោបល់អីទេ? “

បុរសមានទោសស្នេហាមុខខ្មៅអែ ដឹងថាថ្ងៃអវសានដល់ហើយ គាត់ងើបមើលមុខប្រពន្ធដើម មើលមុខសង្សារក្រោយ មើលមុខប្រជាជនគ្រប់ៗគ្នា ដូចជាអង្វរឲ្យគេជួយផង តែគ្មាន អ្នកណាម្នាក់ហ៊ានងើបមុខបញ្ចេញយោបល់អ្វីទេ ។ ពុកក្រុក បញ្ជាឲ្យឈ្លបស្រាយបុរសនោះពីដើមអម្ពិលមកលុតជង្គង់ឱនក្បាលចុះហើយឲ្យស្រែកថា ខ្ញុំរាងហើយៗ ។ ពុកក្រុក យារចបជីកសំពងអស់មួយទំហឹងផ្នែកក្បាលខាងក្រោយឮសូរប៉ុក ពុំសមនឹងស្លាប់សោះ ។ បុរសអភ័ព្វដួលផ្កាប់មុខទៅដី ហើយថែមមួយចបទៀត ស្ងាត់មាត់គ្មានកម្រើកខ្លួន ។ ប្រពន្ធដើមបុរសនោះ ក៏ដួលនៅក្នុងចំណោមមនុស្សគ្រប់គ្នា ។ ឥឡូវដល់វេនស្រីសហាយវិញម្ដង ។ នៅពេលឈ្លបស្រាយចំណងនាងក៏ដួលរលំទៅហើយ ។ នាងទឹកភ្នែកហូររហាម ព្រលឹងធំរបស់នាងប្រហែលជារត់ចេញមុនទៅហើយក៏មិនដឹង ។ នាងត្រូវឈ្លបបញ្ជាឲ្យលុតជង្គង់ដែរ ហើយឲ្យស្រែកថា “ខ្ញុំឈប់ធ្វើដូច្នេះហើយ” ។ ពុកក្រុក សំពងក្បាលស្រីនោះពីក្រោយប្រហែលប្រាំពីរ-ប្រាំបីចបទើបនាងលែងកម្រើកខ្លួន ។ ប្រហែលមកពីនាងមានមនុស្សម្នាក់ទៀតនៅក្នុងពោះ ទើបក្រស្លាប់ដូច្នេះ ។ ពួកយើងទាំងអ្នកចាស់ទាំងអ្នក ១៧មេសា សែនតក់ស្លុតរន្ធត់ញាប់ញ័រគ្រប់គ្នា ព្រោះទោសស្នេហាប៉ុណ្ណេះ ពុំសមទទួលទណ្ឌកម្មដល់ថ្នាក់នេះសោះ ។

ខ្ញុំស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ។ បងស្រីបន្តថា គេដឹកសពអ្នកទាំងពីរតាមរទេះគោយកទៅកប់ជាមួយគ្នា ហើយគេនិយាយថា ក្រោយមកកន្លែងនោះលងសម្បើមណាស់ ទោះដើរពេលថ្ងៃក៏ដោយក៏គេឮសំឡេងមនុស្សស្រី-ប្រុសសើចប្រឡែងគ្នាលេង ហើយដើមឫស្សីពីរ-បីដើមនោះតែងយោលយោកជានិច្ច ទោះជាគ្មានខ្យល់ក៏ដោយ ។ ពុកក្រុក បញ្ជាឲ្យពីរនាក់ប្ដី-ប្រពន្ធដែលនៅរស់យកគ្នាទៅកុំឲ្យចាញ់ចិត្តគេយកប្ដីយើង បាន យើងក៏យកប្ដីគេបានវិញដែរ តែពុំដឹងថាអ្នកទាំងពីរយក ឬអត់ ។

នេះជាសោកនាដកម្មស្នេហាមួយដែលអ្នកស្រុកជើងវត្ត និងអ្នកភូមិជិតខាងពុំអាចបំភ្លេចបាន ។ បងប្អូនខ្លះដែលធ្លាប់រស់នៅភូមិនោះពិតជាចងចាំរឿងនេះពុំខានឡើយ ។ តាំងពីថ្ងៃនោះមក ឲ្យតែមានអ្នកណាលួចស្រលាញ់គ្នា គេតែងហៅថា “អាដើមអម្ពិលបារាំង” ដើម្បីជាការក្រើនរំឭកអ្នកទាំងពីរ ។

## ទឹកត្នោតពូបារាំង! Kiss ប្រែថាដែកកេះមួយ

ព្រឹកនេះខ្ញុំដើរទៅចម្ការពីព្រឹកជាមួយ កល្យាណ ។ នៅពេលដើរដល់ដើមត្នោតពីរ-បីដើម កល្យាណ ប្រាប់ខ្ញុំថា “បង! យើងសុំទឹកត្នោតពូបារាំងញ៉ាំ” ។ ពូបារាំង ថ្វីត្បិតតែគាត់ជាអ្នកមូលដ្ឋាន តែគាត់មានសម្បុរសមាឌធំល្អណាស់ ។ គាត់ចូលចិត្តលេងសើចនឹងក្រុមស្រីៗបច្ចេកទេសមេម៉ាយណាស់ ។ ប្រពន្ធចាស់របស់គាត់តែងឃ្លាំមើលគ្រប់ពេលវេលា ។ នៅពេលដើរដល់ដើមត្នោត មានបំពង់ទឹកត្នោតដែលមានទឹកហើយស្រេច ព្យួរតែកគោកនៅគល់ត្នោត ចំណែកពូបារាំងកំពុងតែតោងឡើងដល់ពាក់កណ្ដាលដើម ។ កល្យាណ ស្រែកថា÷

- ពូបារាំងអើយ ខ្ញុំសុំទឹកត្នោតហូបបន្តិច ។

ពូបារាំងឆ្លើយទាំងមិនមើលមកក្រោមថា÷

- អឺ ហូបទៅ ហើយឲ្យអីខ្ញុំវិញ?

កល្យាណ ឆ្លើយថា÷

- ចាំខ្ញុំឲ្យ Kiss មួយ (ប្រែថាថើប)

តែពូបារាំងមិនចេះស្តាប់គាត់ក៏ថា ÷

- អឺ ដែកកេះក៏យកដែរ ។

ពួកយើងហូបឆ្អែតហើយនាំគ្នារត់យ៉ាងលឿនទៅចម្ការ ។ ថ្ងៃក្រោយឲ្យតែជួបមុខ ពូបារាំង តែងទាររកដែកកេះជានិច្ច ។ កល្យាណ ចូលចិត្តនិយាយលេងសើចច្រើន ហើយហ៊ាននិយាយមិនសូវខ្លាចអ្នកណាទេ ។ ពេលល្ងាចនៅពេលត្រឡប់ពីចម្ការវិញ កល្យាណ ងូតទឹកយ៉ាងស្អាតហើយពាក់អាវយឺតវាលកវាលក្លៀក យ៉ាងព្រហើនដើរទៅហូបបាយនៅរោងចុងភៅ ។ នៅរោងបាយ គេធ្វើតុវែងមានកៅអីពីរជួរសម្រាប់អង្គុយហូបបាយ ។ សម្លមួយចានមានគ្នាបួននាក់អង្គុយហូបព័ទ្ធជុំវិញចានសម្ល ដែលគ្មានឃើញសាច់ត្រី ឬសាច់ជ្រូកបន្តិចសោះ មានតែបន្លែស្ងោ ឬត្រកួន និងខ្លាញ់អណ្តែតគ្រាប់ប៉ុណ្ណោះ ។

នៅពេលបាយ ពួកយើងមិនអាចចាំប្តីឬប្រពន្ធបណ្តើរគ្នា ទៅហូបបាយបានទេ ។ អ្នកណាមកដល់មុនទៅហូបមុនទៅ ទោះកូន ប្រុសភ័ក្ត្រខ្ញុំក៏ដោយ វាទៅជាមួយក្មេងៗគ្នាវាទៅ ។ នៅទីនោះមានចុងភៅប្រុសម្នាក់នៅចាំដួសបបរឲ្យ (មិនទាន់ដល់ខែប្រូត យើងហូបបបរជួនរាវជួនខាប់) ។ ចុងភៅនោះតែងតែ សម្លក់សម្លឹងយើងនៅពេលដែលយើងទៅដួសបបរដែលសុទ្ធតែទឹកញយពេក ។ សម្លវិញក៏ដូច្នេះដែរ បើមានស្នេហ៍មុខ ប៉ិនសម្តីបញ្ជោរដូច កល្យាណ ទើបអាចមានវាសនាប្រទះសាច់ត្រីមួយៗ ។

ខ្ញុំអង្គុយហូបជុំគ្នាជាមួយ ចែមុំ ពីរថ្ងៃហើយ ។ គាត់តែងយកវែកបាយទៅហូបបបរ ដួសសម្លតែមួយវែកគាត់គឺអស់សម្លកន្លះចានស្រេច ។ ពួកយើងបីនាក់សម្លឹងមើលគាត់ គាត់ធ្វើអឹមអៀនហើយនិយាយថា ÷

- ខ្ញុំបាក់ស្លាបព្រាអស់ហើយ ទើបយកវែកមកហូបដូច្នេះ ។

ស្អែកឡើងខ្ញុំយកវែកបាយទៅហូបបបរដែរ ដួសសម្លតែ មួយវែកចង់អស់សម្លពីចាន (សម័យនោះទាល់តែឆ្លាតទើបរស់បាន) ។ ពុកក្រក តែងលើកសុភាសិតមួយឃ្លាថា "សុខចិត្តឲ្យស្អុះ តែមិនឲ្យដាច់" ។

ព្រឹកនេះអង្គការដូរកម្មវិធីឲ្យក្រុមស្រីៗយើងទៅជួយលើកទំនប់នៅជិតភូមិម្តង ។ ល្ងាចឡើង នៅពេលជិតឈប់សម្រាកទៅហើយ បងស្រី ម៉ែអាទូ មុតជើងនឹងចបជីកចេញឈាមយ៉ាងច្រើន ។ យើងបោចស្មៅយកមកឃាត់ឈាមយ៉ាងណាក៏មិនបាត់ ។

ខ្ញុំមានភារៈត្រូវជូនបងស្រីមកផ្ទះ ។ នៅតាមផ្លូវ យើងប្រទះឃើញចម្ការស្លឹកខ្ទឹមបី-បួនរង ។ បងស្រី ម៉ែអាទូ ឲ្យខ្ញុំគ្រាហ៍គាត់ទៅសុំគេពីរ-បីសន្លឹកយកមករុំជើងឃាត់ឈាម ។ លោកអ្នកអានទាយទៅមើលតើម្ចាស់ស្លឹកខ្ទឹមឆ្លើយយ៉ាងម៉េច ។ គេថា តាំងពីកើតពោះម៉ែមកមិនដែលមានអ្នកណាយកស្លឹកខ្ទឹមទៅឃាត់ឈាមទេ បើចង់បានយកទៅស៊ីប្រាប់តាមត្រង់ទៅ ។ បងស្រី ម៉ែអាទូ ដើរបណ្តើរ យំបណ្តើរជេរបណ្តើរថា "អាចោរថ្លើមខ្មៅ ចាំមើលពីរបីថ្ងៃទៀតអញលួចដកចោលឲ្យអស់" ។

បានប្រហែល១០ថ្ងៃ ជើងបងស្រីក៏បានគ្រាន់បើបន្តិច ។ យប់នេះរាងស្វាត់បន្តិចទៅហើយ បងស្រី ម៉ែអាទូ បបួលខ្ញុំទៅលួចដកស្លឹកខ្ទឹម ។ ខ្ញុំរួញរាមិនហ៊ានទៅ តែទីបំផុតក៏ព្រមទៅតាម ការអង្វរកររបស់គាត់ ។ យើងទាំងពីរនាក់ដកស្លឹកខ្ទឹមអស់មួយរង ហើយប្រកក្នុងស្បោងក្រណាត់យកមកផ្ទះ ។ មកដល់ផ្ទះ យើងកាត់មើមៗវាលាងឲ្យស្អាតហើយប្រកចូលក្នុងឪទិនទឹកត្រីធ្វើជ្រក់ក្ជាមៗ ស្លឹកវាច្រើនពេកយើងកប់នៅក្នុងដេះមុខចង្ក្រាន ។ យប់នេះយើងនៅក្នុងផ្ទះបីគ្រួសារ រួមទាំងប្អូនស្រី សូដា ផង គេងពុំលក់ទេ ។

ស្អែកឡើងយើងទៅលើកទំនប់ធ្វើដូចមិនដឹងខ្លួន ។ ថ្ងៃត្រង់ ពេលឈប់សម្រាកហូបបាយ អាទូ កូនប្រុសរបស់បងស្រី រត់ត្រហេបត្រហបទៅខ្សឹបប្រាប់ម៉ែវាថា មានឈ្លបពីរ-បីនាក់ ដើរឆែកតាមផ្ទះដើម្បីរកស្លឹកខ្ទឹមដែលបាត់មួយរងពីយប់មិញ ឥឡូវជិតដល់ផ្ទះយើងហើយ ។ បងស្រី ម៉ែអាទូ និងខ្ញុំ រត់យ៉ាងលឿនទៅផ្ទះ ហើយកាយស្លឹកខ្ទឹមដែលនៅក្នុងដេះមុខចង្ក្រានប្រកចូលក្នុងថង់ក្រណាត់ ហើយដាក់ព្យួរនឹងជញ្ជាំងក្រោយផ្ទះដោយលូកតាមបង្អួច ។ ខ្ទឹមមិនបានចោលក្លិនទេ ព្រោះកប់ដេះមួយយប់ហើយ តែយើងភ័យបុកពោះមិនស្មើរទេ ។ រួចរាល់ ហើយ បងស្រីធ្វើជាដេកឲ្យខ្ញុំកោសខ្យល់ឲ្យមិនទាន់ត្រឡប់ទៅធ្វើការវិញទេ ។

*ឈ្លបបានឡើងមកពិនិត្យមើលចង្ក្រានបាយយើង គឺកន្លែងដែលសម្រាប់ឲ្យយើងដាំទឹកហូបតែប៉ុណ្ណោះ ។ សំណាងល្អ ឈ្លបរបស់អង្គការអាវខ្មៅមិនបានអើតមើលជញ្ជាំង ខាងក្រោយផ្ទះ ។ ប្រហែលបារមីដើងវត្តជួយក៏មិនដឹង ។ យើងក៏រួចគ្រោះម្តងទៀតដោយចៃដន្យបំផុត ។*

## ប្អូនអឿន អ្នកវែកដីមនុស្ស

*ក្នុងភូមិនេះ អ្នកវែកដីមនុស្សគឺជាមនុស្សដែលគេខ្ពើមបំផុត ។ បើចូលផ្ទះអ្នកណាសុំទឹកគេហូបក៏គេមិនចង់ឲ្យដែរ ហើយបើទៅហូបបាយនៅរោងបាយក៏គេមិនចង់ឲ្យអង្គុយជិតដែរ ។ តែអ្នកវែកដីមានសុវត្ថិភាពល្អណាស់ ព្រោះគេពុំរវល់ហៅទៅកងចល័តឆ្ងាយពីផ្ទះ ឬធ្វើការអីផ្សេងទៀតទេ ។ ប្អូនអឿន អាយុ១៨ឆ្នាំហើយ មានមុខវែង ច្រមុះស្រួច សក់ស្កូត គឺជាអតីតនិស្សិតពេទ្យឆ្នាំទី១ ហើយត្រូវជាកូនទី១របស់អ៊ំសារ៉េត ។ ប្អូនពុំដែលរវល់ធ្វើចេះដឹងអ្វីទេ ហើយក៏មិនចង់និយាយរកអ្នកមូលដ្ឋានដែរ ។ ប្អូនធ្វើសឹៗឡឺកឺៗ ដូនធ្វើថ្លង់ក៏មាន ។ នៅពេលស្ងាត់កំបាំងពីមុខអ្នកមូលដ្ឋាន ប្អូននិយាយព្រោកប្រាជ្ញមិនចេះខ្ជិល ។ ប្អូនអឿន និយាយថា ÷ «ខ្ញុំមិនឆោតទៅកើបអាចម៍គេទេ គឺខ្ញុំយកដីទៅចាក់ក្នុងបង្គន់ហើយកាយយកដីនោះវែកដាក់បង្គីជាការស្រេច» ។ ដូនកាល ប្អូនដើរត្រឡប់ចុះត្រឡប់ឡើងពេញភូមិ ដើម្បីឲ្យអង្គការមើលឃើញថាប្អូនជាមនុស្សសកម្ម ។ សម័យនោះមានតែអ្នកធ្វើល្ងង់ទេទើបអាចសល់ជីវិតបាន ។ មកដល់សម័យនេះ ប្អូនអឿនក្លាយជាវេជ្ជបណ្ឌិត ។*

## នារីកំពូលល្បិចទាំង១៨នាក់

*យប់នេះ ប្រហែលពាក់កណ្តាលអធ្រាត្រ បងស្រី ម៉ែអាទូ ងើបមកកេះជើងខ្ញុំហើយខ្សឹបថា ÷*

*-ប្អូនណាងឯងចង់ស្តាប់ចម្រៀងទេ?*

*គំនិតព្រើលរបស់ខ្ញុំនៅមិនចេះរាងចាលសោះ ។ ខ្ញុំផ្ទៀងត្រចៀកស្តាប់ឮល្វើយៗពីសាលាឆាន់ ដែលឥឡូវនេះ ទុកសម្រាប់ឲ្យពួកក្រុមឈ្លបយុវជន-យុវតីស្នាក់នៅ ។ ខ្ញុំនិងបងស្រីលួច ចុះជណ្តើរថ្នមៗដើរសំដៅទៅប្រភពសំឡេងដោយចិត្តពុះកញ្ជ្រោល ។ គឺពិតជាពុំមែនបទបដិវត្តន៍ដែលខ្ញុំធ្លាប់ឮរាល់ព្រឹក នោះទេ ។ គឺជាសំឡេងត្អូញត្អែររបស់អ្នកស្រី ម៉ៅ សារ៉េត «មេឃខ្មៅងងឹត សម្លឹងមើលចិត្ត...«*

*ឱ! ពីរោះអ្វីម្ល៉េះទេ! ថ្មើរណេះអ្នកស្រីរសាត់អណ្តែតទៅដល់ណាហើយ ។ ខ្ញុំឈរឱបដៃបងស្រី ម៉ែអាទូ ដាក់នៅទ្រូង ទឹកភ្នែកហូររហាម មិនស្មានថាមានវាសនាបានឮបទចម្រៀងអស់នេះឡើងវិញសោះ រីឯបងស្រីក៏ដូច្នេះដែរ ។ យប់ក្រោយៗមកយើងតែងនាំគ្នាទៅលួចស្តាប់ចម្រៀងរាល់យប់នៅក្រោមសាលាលោកឆាន់នោះ ។ យប់ខ្លះក៏ឮពួកយុវជនស្រី-ប្រុសនោះប្រឡែងគ្នាឲ្យកក្អឹក ។ យប់នោះ ពេលខ្ញុំនិងបងស្រីកំពុងស្ងួងអារម្មណ៍នឹងបទ «ម្ភៃឆ្នាំក្នុងគុកដោយដៃស្រីល្អ» របស់លោក ស៊ីន ស៊ីសាមុត ។ ខ្ញុំឈរផ្អែកលើបាវជាច្រើនដែលដាក់គរជាច្រើនជួរ ។ ខ្ញុំលូកដៃចុចស្ទាបមើលជាបាវអ្វី ។ បងស្រីខ្សឹបប្រាប់ខ្ញុំថាជាបាវស្រូវ ។ ដល់ពេលនោះទើបខ្ញុំនឹកឃើញថា មែនហើយ កន្លែងនេះពេលថ្ងៃគេកិនស្រូវទេតើ ។ ពេលត្រឡប់មកផ្ទះវិញពួកយើងពីរនាក់គិតគ្នាដើម្បីលួចស្រូវក្នុងបាវនោះឲ្យបាន ។*

*គិតអស់ពីរ-បីយប់ទើបខ្ញុំនឹកឃើញរឿងកុនចិនហុងកុងមួយដែលលេងនៅរោងគិរីរម្យ គឺរឿងកំពូលនារី១៨នាក់ ។ កាលនោះ ស្ត្រីៗទាំងអស់នោះមានប្តីជាមេទ័ព ក្រោយមកទៅធ្វើសង្គ្រាមក៏ត្រូវសត្រូវសម្លាប់អស់ទៅ ។ ស្ត្រី១៨នាក់ដែលត្រូវជាប្រពន្ធនោះក៏ស្ម័គ្រចិត្តសុំព្រះរាជាទៅធ្វើសឹកម្តងដើម្បីសងសឹកជូនប្តីខ្លួន ។ ស្តេចក៏យល់ព្រម ហើយស្ត្រីទាំងនោះក៏នាំទ័ពធ្វើដំណើរទៅ ។ ពេលឈប់សម្រាកនៅពេលយប់នៅតាមផ្លូវសត្រូវម្នាងទៀតបានមកលួចដុតស្បៀងអង្ករបស់ទ័ពខាងនារី១៨នាក់ហិនហោចអស់រលីង ។ «ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ» សេនាទាហានខាងនារី១៨នាក់គ្មានកម្លាំងកំហែងនឹងច្បាំង ព្រោះគ្មានអ្វីហូប ។ ពេលនោះមានទាហានស្ម័គ្រចិត្តស៊ូស្លាប់ពីរ-បីនាក់សុខចិត្តទៅលួចអង្ករនៅឃ្លាំងរបស់សត្រូវម្នាងវិញ ។*

ទាហានបីនាក់នោះមានកូនបាវតូចល្មមមួយម្នាក់ និងបំពង់ឫស្សី ដែលគេសម្រួចចុងហើយស្រេច លូនចូលក្នុងឃ្លាំងអង្ករ ។ ទៅដល់គេយកឫស្សីចុងស្រួចចាក់ចូលក្នុងបាវអង្ករ បង្ហូរចូលបាវតូចដែលយកទៅចងនៅចង្កេះរបស់គេ ។ ទាហានដ៏ក្លាហាននោះត្រឡប់មកវិញតែពីរនាក់ប៉ុណ្ណោះ ម្នាក់ទៀតបានពលីជីវិតនៅតាមផ្លូវទៅហើយដោយសត្រូវតាមទាន់ ។ ទោះយ៉ាងណា អង្ករបន្តិចបន្តួចយកមកលាយនឹងស្លឹកឈើព្រៃអាចជួយទ័ពទាំងអស់ឲ្យមានកម្លាំងធ្វើសឹកតទៅទៀតបានដែរ ។

នឹកឃើញដល់ត្រង់នេះខ្ញុំក៏និយាយប្រាប់បងស្រី ម៉ែអាទូ គាត់ក៏យល់ស្របតាមខ្ញុំ ។ យប់នេះយើងក៏បើកប្រតិបត្តិការនៅពេលពាក់កណ្ដាលអធ្រាត្រ ។ ពេលចេញដំណើរទៅ ខ្ញុំមានអារម្មណ៍ថាដូចជាចេញទៅធ្វើសង្គ្រាមដ៏ធំមួយ ។ បេះដូងគ្គុកក្ដាក់ចង់ខុសចង្វាក់ ។ យើងទាំងពីរនាក់ប្រុងប្រយ័ត្នណាស់ ត្រចៀកស្ដាប់ភ្លេងបណ្ដើរ យកបំពង់ឫស្សីតូចមួយប្រវែងមួយម៉ែត្រដែលសម្រួចចុងហើយស្រេច ចាក់ចូលក្នុងបាវស្រូវ ហើយបង្ហូរស្រូវចូលក្នុងស្បោងក្រណាត់ដែលយើងយកអាវមកកាត់ ។ យើងមិនហ៊ានយកច្រើនទេ បានតែមួយកូនស្បោងតូចប្រហែលបី-បួនគីឡូក្រាមប៉ុណ្ណោះ ។ ម្យ៉ាងខ្លាចរហែកស្បោង ព្រោះក្រណាត់វាផុយណាស់ទៅហើយ ។ មកដល់ផ្ទះ យើងស្រាយមើលទាំងរញីរញ៉ៃ ។ គឺស្រូវដែលកិនហើយ ប៉ុន្តែមិនទាន់ស្រិត ។ ចំជារកខុសប្រទះឈើងាប់មែន ។ បងស្រី ម៉ែអាទូ មានកូនល្អីតូចមួយ ។ គាត់អុំយកអង្ករស្អាតហើយក៏ដាំបាយទាំងយប់នោះហូបតែម្ដងទៅកុំឲ្យឃើញដាន ។ គ្មានអ្វីសប្បាយជាងមានបាយហូបទេ ។ ខ្ញុំនៅអង្គុយការំដណ្ដើរមើលផ្លូវ ។ សំណាងល្អគ្មានឃើញស្រមោលឈ្លបណាមកក្បែរសោះយប់នេះ ។ យើងហូបបាយជាមួយខ្ទឹមជ្រក់ដែលលួចបានពីថ្ងៃមុន ។

ព្រឹកនេះ យើងត្រូវទៅចម្ការដកដំឡូងមីម្ដង ។ យើងសប្បាយរីករាយពេលទិសដៅត្រូវទៅចម្ការ ព្រោះទោះយ៉ាងណាក៏យើងបានដំឡូងមកផ្ទះសោរហូបដែរ ជួនកាលក៏យកមកឈូសចំហុយ ។ នៅតាមផ្លូវទៅចម្ការ បានជួបនឹងអ៊ំស្រីម្នាក់ដែលខ្ញុំមើលគាត់មិនចង់ស្គាល់ ព្រោះគាត់ស្គមពេក ។ គាត់កំពុងតែរែកទឹកនៅតាមផ្លូវ ។ អ៊ំស្រីឱបខ្ញុំដោយសេចក្ដីនឹករឭក ។ គាត់ចង្អុលផ្ទះរបស់គាត់ឲ្យខ្ញុំស្គាល់ដើម្បីថ្ងៃក្រោយចូលលេង ។ អ៊ំស្រីខ្សឹបសួរខ្ញុំថា មានថ្នាំជក់ទេ ដូរត្រីដូរស្ករក៏បាន ។ ខ្ញុំថាគ្មានទេ តែនៅចម្ការក្រោយផ្ទះខ្ញុំមានគេដាំថ្នាំជក់ ចាំថ្ងៃណាខ្ញុំចូលយកស្លឹកថ្នាំមកឲ្យ ។ អ៊ំស្រីថាយកមកគាត់ហាលឲ្យ ព្រោះផ្ទះអ៊ំនៅឆ្ងាយពីគេ គ្មានអ្នកណាគេចាប់អារម្មណ៍ទេ ។ រវល់តែជជែកគ្នា ទឹកក្នុងធុងអ៊ំស្រីក៏អស់រលីងព្រោះធុងវាធ្លាយ ។

ល្ងាចឡើងពេលមកពីចម្ការវិញ ពួកអ្នកមូលដ្ឋានទូលកញ្ជើដើរដោយក្រុមៗ ។ គេទូលកញ្ជើដើរដោយមិនយកដៃទប់កញ្ជើដូចពួកយើងទេ ។ ក្រុមយើងបួន-ប្រាំនាក់ដើរខាងក្រោយគេឆ្ងាយបន្តិចស្រួលជជែកគ្នា ។ កល្យាណ និយាយថា «ពួកយើងរៀនទូលកញ្ជើដូចពួកខាងមុខ ហាមមិនឲ្យយកដៃកាន់ទេណា៎ ចាំមើលខ្ញុំធ្វើមុនគេហើយ» ។ កល្យាណ ក៏ដើរកាច់រាងដោយយកដៃច្រត់ចង្កេះ ។ ទើបនឹងបានបួន-ប្រាំជំហានក៏កំពប់កញ្ជើចំមុខផ្ទះ ពុកក្រុក តែម្ដង ចៃដន្យ ពុកក្រុក ជិះកង់មកដល់ល្មម ។ កល្យាណ ស្លាំងមុខ ឱនរើសដំឡូងដែលធ្លាក់រាយប៉ាយយ៉ាងប្រញាប់ប្រញាល់ ។ យើងទាំងអស់គ្នាក៏ស្ទុះទៅជួយរើសដែរ ។ ពុកក្រុក មុខមាំស្ដីឲ្យថា «ពួកឯងប៉ិនលួចណាស់ គ្រាន់តែម្នាក់ប៉ុណ្ណឹងទៅហើយ បានតែយកទៅរំពៃចោលមួយ-ពីរឲ្យដឹងម្ដង» ។

តាមពិត ពុកក្រុក គ្មានបំណងធ្វើបាបយើងទេ បើពុំដូច្នេះ ថ្ងៃនោះប្រហែលគ្មាននរណាម្នាក់រួចខ្លួនឡើយ ។

ពីរ-បីថ្ងៃក្រោយមក ខ្ញុំបបួលបងស្រី ម៉ែអាទូ ទៅលួចបេះស្លឹកថ្នាំជក់ ។ យប់សែនមហាងងឹតរកចាក់ភ្នែកពុំយល់ ផ្ទៃមេឃគ្មានផ្កាយមួយដួងសោះ ។ ខ្ញុំដើរជាមួយបងស្រីស្ទាបៗតាមការចំណាំប៉ុណ្ណោះ ប្រសិនបើមានឈ្លបដើរមកពីមុខបុកគ្នាក៏មើលពុំឃើញដែរ (មកដល់ត្រង់នេះ មិត្តអ្នកអានពិតជាសើចនឹងចោរីខ្ញុំពុំខាន) ។ អស់លោកទាយទៅមើល ខ្ញុំទៅលួចស្លឹកថ្នាំតើខ្ញុំបេះអ្វី? ខ្ញុំគិតថា បើញ៉ាំអន្ទក់គឺគេបេះត្រួយឲ្យវាខ្ចីឆ្ងាញ់ ហើយខ្ញុំក៏កាច់ស្លឹកថ្នាំតែត្រួយខាងលើខ្ចីៗដែរ ។

ព្រឹកនោះខ្ញុំងើបពីព្រលឹមងងឹតតិចៗនៅឡើយ ។ ខ្ញុំដើរទៅចម្ការមុនគេហើយក៏ដើរសំដៅទៅផ្ទះអ៊ំស្រីយកស្លឹកថ្នាំទៅឲ្យគាត់ ហាល ។ អ៊ំស្រីនិយាយថា ស្អែកយកមកត្រីប្រឡាក់ទៅហូប ។ ល្ងាចនេះពេលខ្ញុំទៅហូបបាយល្ងាចនៅរោងបាយ ខ្ញុំឮប្រជាជន ជជែកគ្នាអំពីរឿងចោរលួចបេះត្រួយថ្នាំជក់ ។ គេសើចគ្រប់ៗគ្នាថា «ចោរអីក៏ភ្លើម៉្លេះ» ។ ខ្ញុំហួសចិត្តខ្លួនឯងពុំសមល្ងង់ដល់ថ្នាក់ នេះសោះ ។

## មរណភាព ពេទ្យធី

*ឥឡូវស្រូវទុំហើយ ។ អង្គការតម្រូវឲ្យយើងទៅច្រូតកាត់ម្ដង ។ មុនដំបូងច្រូតនៅក្បែរភូមិ បន្ទាប់មកច្រូតនៅក្រោយភូមិ ។ ថ្ងៃត្រង់ជាក់ ក្រុមអ្នកច្រូតប្រុស-ស្រីដើរចូលភូមិវិញ ដើម្បីហូបបាយ ។ ក្រោយពីហូបបាយរួចភ្លាម យើងត្រូវទៅសម្រាកនៅកន្លែងធ្វើការវិញប្រហែលកន្លះម៉ោងប៉ុណ្ណោះ ។ ក្រោមកម្ដៅថ្ងៃក្ដៅហែង យើងយកកណ្ដាប់ស្រូវរៀបគរលើគ្នាដើម្បីបាំងថ្ងៃ ហើយយើងអង្គុយប្រជ្រៀតគ្នាជជែកលេងតែអំពីរឿងសង្គមចាស់ប៉ុណ្ណោះ ។ កល្យាណ ដែលពូកែវោហារនិយាយថា កាលនៅរៀន មានអ្នកនេះអ្នកនោះតាមគេមិនឈប់នៅក្នុងថ្នាក់ខស្សរាហ៍មានសំបុត្របុប្ផាកុលាបនៅក្នុងថតតុ ។ ប្អូនស្រី សម្ផស្ស មិនសូវចេះនិយាយស្ដីដូចគេឯងទេ ។ ប្អូនស្រី ជាអតីតនិស្សិតពេទ្យឆ្នាំទីមួយ ហើយពេលមកនៅភូមិនេះបានមួយឆ្នាំ ប្អូនស្រីក៏ត្រូវអង្គការបង្ខំឲ្យរៀបការមិនដឹងជាប៉ុន្នាន សិបគូជាមួយយុវជនជាអ្នកស្រុកអរិយក្សត្រ ទាំងប្អូនមិនពេញចិត្ត ។ ប្ដីរបស់ប្អូនស្រី សម្ផស្ស ឈ្មោះ ដែត ជាអ្នកទន្លេ ពូកែរកត្រីណាស់ ។ អង្គការក៏ចាត់តាំងឲ្យយុវជន ដែត រកត្រីផ្គត់ផ្គង់ជីវភាពនៅរោងបាយ ។ រាល់ល្ងាច មិត្តដែត មកពីរកត្រីវិញនៅពេលយប់ងងឹត ហើយច្រើនចូលផ្ទះរបស់ប្អូនស្រីបង្កើតដើម្បីស្ងោរត្រីហូប ឬជួនកាលរើសត្រីធំៗអាំងហូបឆ្អែតទើបយកត្រីតូចៗមកប្រគល់ឲ្យចុងភៅនៅរោងបាយ ។ មិត្តដែតមិនដែលយកត្រីមកផ្ញើ ប្រពន្ធទេ ព្រោះគេធុញក្នុងផ្ទះមានម្ដាយ ឪពុកក្មេក និងបងប្អូនសាច់ថ្លៃច្រើនពេក ។ ប្អូនស្រីសម្ផស្សក៏ដឹងដែរ ប៉ុន្តែប្អូនស្រី ខ្ជិលរវល់ច្រើន ។ ប្អូនស្រីនិយាយទាំងទឹកភ្នែករលីងរលោងថា នៅយប់ខ្លះដែលប្អូនមិនព្រមរួមដំណេកជាមួយប្ដីមិត្តដែត ទៅប្ដឹងប្រធានភូមិ ហើយប្អូនស្រីក៏ត្រូវប្រធានភូមិហៅទៅកសាងទាំងយប់ ជួនកាលត្រូវអង្គុយហាលមូសទល់ភ្លឺក៏មាន ។ ប្អូនស្រីនិយាយថា បើស្រុកយ៉ាងម៉េចៗ ទៅកិច្ចការដំបូងរបស់ប្អូនស្រីគឺលែងប្ដីដែលប្អូនគ្មានចិត្តស្រលាញ់អ៊ីបន្តិចសោះ ហើយកិច្ចការទីពីរគឺចូលរៀនពេទ្យបន្តទៀត ។*

*ចំណែកបងស្រី សំឡី និយាយអំពីអនុស្សាវរីយ៍របស់គាត់ជាមួយនឹងប្ដី គឺគ្រូពេទ្យ ធី ដែលកាលនោះពេលការហើយប្ដីគាត់នៅរៀនពេទ្យមិនទាន់ចប់ ។ គាត់និយាយថា គាត់ទាំងពីរនាក់តស៊ូនឹងគ្នាណាស់ ទោះអត់ឃ្លានយ៉ាងណាក៏ដោយ ។ កាលនៅរៀន ទោះយប់ជ្រៅយ៉ាងណាក៏គាត់អង្គុយចាំប្ដីគាត់រៀនទាល់ចប់ទើបចូលគេងទាំងអស់គ្នា ។ យប់ខ្លះពេលរៀនចប់ពួកគាត់ឃ្លានបាយក៏នាំគ្នាយកអាល់កុលដុតសាច់ក្រកញ៉ាំបាយកក ។ និយាយដល់ត្រង់នេះ បងស្រីម៉ែអាទូ ស្រែកថា «អូយ! ឃ្លានសាច់ក្រកណាស់កុំនិយាយ!» ។*

*ក្រុមយើងខស្សរាហ៍ត្រូវប្រធានកងកសាងណាស់ ព្រោះចេះតែនាំគ្នានិយាយពីរឿងម្ហូបឆ្ងាញ់ រឿងនំឆ្ងាញ់ពីសង្គមចាស់ ។*

*ស្រូវនៅជិតៗភូមិច្រូតអស់ហើយ ។ អង្គការក៏តម្រូវឲ្យ យើងចេញទៅឆ្ងាយម្ដងបន្តិចៗរហូតប្រហែលពីរគីឡូម៉ែត្រពីភូមិ តែគេមិនទៅទាំងប្ដី-ប្រពន្ធទេ ជួនឲ្យប្ដីទៅ ជួនឲ្យប្រពន្ធទៅ ។ អង្គការតម្រូវឲ្យយើងនៅដេកពេលយប់នៅកន្លែងច្រូតតែម្ដង មិនឲ្យមកផ្ទះវិញទេ ដោយមានចុងភៅទៅដាំស្លឲ្យយើងហូបនៅទីនោះ ។*

*ពេទ្យធី ដែលមានមាឌធំមាំ ខ្ពស់ស្រឡះ កាត់សក់ផ្កាថ្កូវ មានចរិតរួសរាយ ត្រូវអង្គការតម្រូវឲ្យគាត់ទៅច្រូតស្រូវដែរ ។ យប់នោះ នៅក្នុងខ្ទមរួមគ្នាកណ្ដាលវាលស្រែល្ហឹងល្ហើយ ខ្ញុំអង្គុយអណ្ដែតអណ្ដូងនឹកកូននិងប្ដីដែលនៅឯផ្ទះពុំដឹងបានអ៊ីហូប ។*

*រដូវច្រូតកាត់ យើងបានហូបបាយស្រួយ មានសម្លយើញត្រីខ្លះៗ ។ ព្រឹកនេះ ថ្ងៃទើបតែរះនៅបាំងចុងព្រៃចោលរស្មីបាចសាចមកលើរោងសហករណ៍របស់យើងទាំងអស់គ្នា ខ្ញុំនៅគេងក្នុងជំរំនៅឡើយ ខ្ញុំបានឮសម្រែកដ៏តក់ស្លុតរបស់អ៊ីម្នាក់ថា ÷*

*- ជួយផង ពេទ្យធីស្លាប់ហើយ!*

*ម្នាក់ៗស្ទុះសឹងបាក់កទៅអើតមើលជំរំដែលគេសើយ ក្រណាត់ឡើងដើម្បីមើលមុខគាត់ ។ ពេទ្យធី មានទឹកមុខស្លេកស្លាំងខ្លួនត្រជាក់ស្រឹបគ្មានកម្រើក ប្រៀបដូចគល់ខសងាប់ ។ អ៊ំប្រុស ដួង ដែលនៅសម្រាន្តជិតគាត់ ក៏មិនបានដឹងថាគាត់ស្លាប់ពីអង្កាល់ដែរ ។ អ៊ំប្រុស ដួង ប្រាប់ថា ពីក្បាលព្រលប់ឮសូរ ពេទ្យធីថ្ងូរថាឈឺក្បាល ។ ឈ្លបក្មេងម្នាក់ដែលមើលការខុសត្រូវកងខ្ញុំបានរត់ទៅភូមិភ្លាមដើម្បីប្រាប់ប្រពន្ធរបស់ពេទ្យធី ហើយ ផ្ដែផ្ដាំឈ្លបពីរ-បីនាក់ដែលនៅចាំកន្លែងថា កុំអាលយកសពពេទ្យធី*

*ទៅកប់អី ចាំប្រពន្ធគាត់មកដល់សិន ។ តាមមើលប្រហែលជា ពេទ្យធី ស្លាប់ដោយសារតែត្រជាក់ពេកក៏មិនដឹង ព្រោះយើងទាំងអស់គ្នាសុទ្ធតែគេងផ្ទាល់លើដី ដោយក្រាលតែ កូនកន្ទេលកក់តូចមួយប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពេលយប់មានសន្សើមច្រើនផង ។ ដោយរង់ចាំយូរពេក ណាមួយក្រុមអ្នកប្រូត មិនព្រមចុះធ្វើការសោះ ព្រោះម្នាក់ៗមិនអស់ចិត្តនឹងការស្លាប់របស់ពេទ្យធី ឈ្លបក៏សម្រេចថាយកសព ពេទ្យធី ទៅកប់នៅទីទួលមួយក្បែរនោះ ។ គ្រាន់តែកប់ហើយភ្លាម បងស្រី សំឡី ប្រពន្ធ ពេទ្យធី រត់មកដល់ភ្លាម ។ គាត់រត់ទៅទម្លាក់ខ្លួននៅលើ ផ្នូរប្ដីសម្លាញ់ដែលទើបកប់ថ្មីៗ ស្រែកទ្រហោយំគ្មានខ្មាសនរណាទាំងអស់ ហើយដៃគាត់ទាំងពីរកាយផ្នូរប្ដីគាត់ ។ យើងទៅចាប់ដៃគាត់កុំឲ្យកាយដី ។ គាត់រៀបរាប់អស់ហើយរឿងប្ដីគាត់ ។ គាត់និយាយខ្មែរផងបារាំងផង អង់គ្លេសផង ស្រេចតែចិត្តនឹកឃើញ គ្មានខ្លាចឈ្លបដែលកំពុងតែឈរមើលគាត់ព្រោងព្រាតឡើយ ។ យើងរលីងរលោងទឹកភ្នែកគ្រប់គ្នា «លាហើយ ពេទ្យធី ជាទីស្រលាញ់ សូមលោកទៅឲ្យបានសុខចុះ» ។*

*កងឈ្លបក៏អាណិតអាសូរ ពេទ្យធី ដែរ ធ្វើមុខស្រងូត ស្រងាត់គ្រប់ៗគ្នា ព្រោះកាលនៅរស់ ពេទ្យធី ធ្លាប់ជួយមើលជំងឺទាំងអ្នកមូលដ្ឋាន ទាំងអ្នក ១៧មេសា ច្រើនណាស់ ។ (សព្វថ្ងៃ បងសំឡី បើកឱសថស្ថាន មុខពេជ្រនៅផ្លូវកម្ពុជាក្រោម) ។*

## តំបន់បី

*ពេលនោះដោយសារអត់ឃ្លានខ្លាំងពេក ប្រជាជន១៧មេសាជាច្រើន ក៏បាននាំគ្នាលួចរត់ទៅតំបន់បី ព្រោះឮថាទីនោះសម្បូរបាយហូបណាស់ (ខ្ញុំនៅតំបន់ប្រាំ) ។ ខ្លះទៅបានបី-បួនថ្ងៃ ក៏លួចមកប្រាប់គ្នាឯងដែលអត់ឃ្លានដូចគ្នាឲ្យរត់ទៅដែរ ។ ប្ដីនាង ខ្ញុំដែលមានគំនិតចង់តែធ្វើទេសចរគ្រប់ទិសទីបានបបួលខ្ញុំរត់ទៅនឹងគេដែរ ព្រោះគាត់មានគំនិតចង់រកឪពុកម្ដាយរបស់គាត់ ។ ខ្ញុំក៏យល់ព្រមតាម ។ យប់នោះក្រោមពន្លឺខែព្រាលៗ យើងអង្គុយជុំគ្នាជាមួយអ្នកនៅក្នុងផ្ទះទាំងអស់គ្នា ។ បងស្រីម៉ែអាទូ និងប្អូនស្រីសូដា បានឲ្យពរជ័យដល់គ្រួសារខ្ញុំជាលើកចុងក្រោយ ។ ប្អូនស្រីសូដា ដែលជាមនុស្សមិនសូវនិយាយស្ដីតែមានចិត្តរឹងដូចថ្ម បាននិយាយថា «បងហួត និង បងណាង ថ្ងៃណាមួយយើងនឹងជួបគ្នានៅភ្នំពេញម្ដងទៀតមែនទេ?» ។ ខ្ញុំងក់ក្បាលទាំងរលីងរលោងទឹកភ្នែក ។ យប់នោះយើងអង្គុយជជែកគ្នាចង់ទល់ភ្លឺ ។ ព្រលឹមស្រាងមេឃមិនទាន់ភ្លឺមែនទែន ប្ដីប្រពន្ធខ្ញុំ និងកូន បានចេញដំណើរ ។ បងស្រី ម៉ែអាទូ បានឱបខ្ញុំនិងកូនភ័ក្ត្រខ្ញុំយំ ហើយនិយាយថា «យើងជួបគ្នាទៀតមែនទេ?» ខ្ញុំឱបអ្នកទាំងអស់គ្នាទាំងមិនអស់ចិត្ត ។ ប្ដីខ្ញុំលីចបដែលគាត់ស្រលាញ់ជាងអ្វីទាំងអស់ ខ្ញុំទូលកញ្ជើដាក់ខោអាវចាស់ៗពីរ-បីកំប្លេ ហើយចេញដំណើរបន្ទំជាមួយគេចេញទៅលើកទំនប់ដែរ ។ (នៅឆ្នាំ១៩៨២ ខ្ញុំបានជួបបងស្រី ម៉ែអាទូ ។ គាត់ធ្វើការនៅក្រសួងជាមួយ ។ កូនប្រុសទាំងពីររបស់គាត់ជិតពេញកម្លោះហើយ ។ វាមានរូបរាងសាច់ឈាមស្រស់ថ្លាល្អណាស់ ពុំដូចកាលនៅក្នុងរបបអាវខ្មៅទេ ។ បងស្រីបាននិយាយដោយសើចផងថា «មានគេចង់បានខ្ញុំច្រើនណាស់ តែអាប្ដីពីរនាក់នេះ (កូនប្រុសទាំងពីររបស់គាត់) វាឃាយាំងខ្ញុំជាប់ ។» គាត់ច្រៀងបទ «សំបុត្រក្រោមខ្នើយ» ឲ្យខ្ញុំស្ដាប់ ។ ឥឡូវខ្ញុំពុំដែលបានជួបគាត់ទេ ប្រហែលជាគាត់ចេញទៅក្រៅបាត់ហើយ ។)*

*គ្រួសារខ្ញុំដើរបានប្រហែលពីរគីឡូម៉ែត្រពីភូមិក៏មកដល់ស្ទឹងមួយ ។ យើងឆ្លងស្ទឹងនោះដែលមានជម្រៅត្រឹមក្បាលជង្គង់ប៉ុណ្ណោះ (ក្នុងខែប្រាំង) ។ មកដល់តំបន់បីហើយ ។ នៅទីនោះ ដើមឈើដើមព្រៃស្រស់ញញឹមល្អណាស់ សូម្បីតែវាលស្មៅក៏ខៀវស្រងាត់ដែរ ។ ខ្ញុំស្ទើរតែពុំហ៊ានដើរជាន់វាលស្មៅអស់នោះ ព្រោះវាមានត្រកួននិងផ្ទីល្អពេក ដែលនៅតំបន់ខ្ញុំពុំសូវមានសោះ ។*

*ថ្ងៃជិតត្រង់ទៅហើយ គ្រួសារខ្ញុំដើរដល់ភូមិមួយ ។ កូនប្រុសខ្ញុំចង់យំព្រោះវាឃ្លានបាយពេក ។ ខ្ញុំដាច់ចិត្តចូលទៅភូមិនោះហើយសំដៅទៅរោងបាយសុំបាយ គេបានមួយចានស្រួបសម្ប្រហើរហើយជាស្រេច ។ យើងក៏ញ៉ាំម្នាក់មួយស្លាបព្រា ហើយសល់ប៉ុន្មានហុចឲ្យកូនប្រុសខ្ញុំ ។*

*គ្រួសារខ្ញុំបានចូលទៅសុំគេជ្រកនៅក្នុងភូមិនោះតែម្ដង តែគេមិនទទួលព្រោះគេថាបួន-ប្រាំថ្ងៃមុនគេទទួលដប់គ្រួសារហើយទៅមុខទៀតទៅ ។ គ្រួសារខ្ញុំក៏បន្តដំណើរទៅមុខទៀត ទៅដល់ភូមិណាក៏គេមិនទទួល ព្រោះគ្រប់ចំនួនហើយ ។ យើងចូលដល់*

ភូមិទីប្រាំពេលល្ងាចជិតយប់ទៅហើយ ។ ប្រធានភូមិ មើលយើងលើក្រោមៗ ហើយក៏ព្រមទទួលឲ្យនៅ ហើយប្រាប់ថា ខំប្រឹងធ្វើការណា៎ ។

ចូលដល់ក្នុងភូមិ គេប្រគល់កូនខ្ទមស្លឹកមួយឲ្យនៅ ហើយស្អែកឡើងយើងក៏ត្រូវចេញទៅលើកទំនប់នៅក្រៅភូមិភ្លាម ។ អ្នកស្រុកភូមិអស់នោះគេមានសាច់ឈាមល្អណាស់ ។ ពួកគេមើលយើងដោយការអាណិតអាសូរ ព្រោះយើងមានក្បាលជន្លង់ធំជាងខ្លួន ហើយមានទឹកមុខស្លេកស្លាំងរកឈាមគ្មាន ។ នាងខ្ញុំ និងអ្នកមកដល់ថ្មីទាំងអស់ខំធ្វើការណាស់ ។ យើងបានហូបឆ្អែតមានកម្លាំង អ្នកមូលដ្ឋានក៏ចិត្តល្អនឹងយើង ។ មានបងស្រីអ្នកមូលដ្ឋានម្នាក់រាងស្គមខ្ពស់ ទឹកមុខរួសរាយ លួចខ្សឹបប្រាប់ខ្ញុំថា នៅទីនេះគេមិនធ្វើបាបប្រជាជនអីទេ គេគ្រាន់តែយកទៅរៀនសូត្រប៉ុណ្ណោះចំពោះអ្នកខិលនិងអ្នកប៉ិនតវ៉ា ។ ទៅទីណាខ្ញុំត្រូវសូរពាក្យ» រៀនសូត្រ«ខ្ញុំព្រឺក្បាលខ្លាក ។

ប្តីសម្លាញ់និងកូនប្រុសខ្ញុំក៏មានសាច់ឈាមស្រស់វិញ ។ កូនប្រុសខ្ញុំអាចរត់លេងប្រឡែងនឹងក្មេងដទៃទៀតសើចក្អាកៗបាន ដែលខ្ញុំមិនដែលបានឃើញសោះតាំងពីមុនមក ។ គ្រួសារខ្ញុំនៅទីនោះ បានមួយខែគត់ពេញដោយសេចក្តីសុខបរិបូណ៌ ។ ថ្ងៃនេះពេលហូបបាយល្ងាចទៅហើយ សមមិត្តនារីម្នាក់អាយុប្រហែល ៣០ឆ្នាំបានប្រាប់ពួកយើងថា «បងប្អូនអ្នកថ្មីទាំងអស់ហូបបាយហើយទៅប្រជុំនៅជិតផ្ទះបងប្រធានភូមិ» ។ បាយរួចនាងខ្ញុំនិងអ្នកថ្មីទាំងអស់ ប្រហែល២០គ្រួសារបានដើរទៅផ្ទះប្រធានភូមិដែលនៅជិតរោងបាយ ។ ចំណែកឯប្តីខ្ញុំគាត់គ្រុនបី-បួនថ្ងៃ ហើយពុំបានមកហូបបាយទេ ។ ខ្ញុំបានសុំបាយគេយកទៅជូនគាត់ ។ ពួកយើងទាំងអស់គ្នាអង្គុយផ្ទាល់ដីមុខផ្ទះប្រធានភូមិ ។ ប្រធានភូមិគឺសមមិត្តកាន ដែលមានសម្បុរខ្មៅឃ្លីក សក់រួញ ភ្នែកធំៗចាប់ផ្តើមបើកអង្គប្រជុំ ។ ជាដំបូងសមមិត្តបានថ្លែងអំណរគុណដល់ពួកយើងអ្នកថ្មីដែលបានមកជួយបង្កបង្កើនផលដល់ភូមិនេះ (ខ្ញុំភ្លេចឈ្មោះភូមិទៅហើយ) ។ ពួកយើងបុកពោះ គ្រប់គ្នាយល់ថាមានហេតុមិនល្អហើយ ។ «សមមិត្តដែលនៅភូមិចាស់របស់បងប្អូនទាំងអស់គ្នា បានមកស្នើសុំយកបងប្អូនទាំងអស់ត្រឡប់ទៅជួយធ្វើស្រែនៅខាងណោះវិញ ព្រោះមិត្តរត់ចោលភូមិឡើងស្ងាត់អស់» ។ ពួកយើងទាំងអស់គ្នាស្ទុះដង្ហើមគ្រប់ៗ គ្នាឡើងបែកញើសជោកខ្លួនទាំងមេឃត្រជាក់ល្ហឹម ។ ប្រធានភូមិបន្តថា «ហេតុនេះបងប្អូនរៀបចំអីវ៉ាន់ឲ្យហើយទៅ ស្អែកឡានគេមកដឹកទៅវិញ ហើយគេមិនឲ្យដើរទៅវិញទេ» ។

ខ្ញុំបានមកខ្ទមវិញហើយនិយាយរឿងនេះប្រាប់ប្តីខ្ញុំ ។ គាត់ថា គេមិនមែនឲ្យយើងទៅនៅកន្លែងដដែលវិញទេ ។ ស្អែកឡើងពួកយើងលាអ្នកភូមិចាស់ទាំងអស់ ហើយខ្ញុំរែកអីវ៉ាន់ដែលមានភួយមុងជារបស់ដែលអ្នកមូលដ្ឋានចាស់ៗ គេឲ្យពេលមកដល់ភ្លាម ។ ចំណែកប្តីខ្ញុំវិញដើរយោងតែអាត្មាពុំចង់រួចផង ព្រោះគាត់គ្រុនប៉ុន្មានថ្ងៃហូបបាយពុំបានគាត់លីតែចបមួយពុំចង់រួច ។ ពួកយើងអ្នកថ្មីទាំងអស់គេប្រមូលឲ្យទៅវិញមានចំនួនច្រើនគួរសមដែរ ។ យើងដើរប្រហែលកន្លះគីឡូម៉ែត្រក៏មកដល់ផ្លូវធំ ហើយមានឡានកាំមីញ៉ុងប្រហែល១០ឡាននៅចាំយើងជាស្រេច ។ ខ្ញុំដើរលឿនៗប្រញាប់មុនគេឆ្អាលនឹងទៅរកកន្លែងល្អអង្គុយ ចំណែកប្តីខ្ញុំដើរញើរញ័រមិនទាន់មកដល់ ។ មិត្តផល ប្រធានក្រុមខ្ញុំដែលស្គាល់ខ្ញុំច្បាស់ បានសួរឲ្យខ្ញុំថា មិត្តណាង ឯងប្រញាប់ទៅណា? មិនឃើញមិត្តហួត (ប្តីខ្ញុំ) កំពុងតែឈឺទេឬ? នៅចាំក្នុងផ្ទះគំរូនេះហើយ ចាំឡានត្រឡប់មកវិញមួយជើងទៀត ទៅ ។ ខ្ញុំក៏ចូលសម្រាកក្នុងផ្ទះគំរូនៅចិញ្ចើមផ្លូវដែលគេធ្វើដូចៗគ្នា ។ ប្តីខ្ញុំទម្លាក់ខ្លួនសម្រាកក្នុងផ្ទះគំរូ ហើយរអ៊ូដាក់ខ្ញុំថា «ដឹងជាប្រញាប់អី ខ្ញុំឈឺក្បាលចង់ងាប់» ។ ខ្ញុំលូកយកថ្នាំឲ្យគាត់លេប គឺគ្មានអ្វីក្រៅពីថ្នាំអាចម៍ទន្សាយទេ ។

យើងទាំងអស់ គ្នានៅចាំរហូតដល់ម៉ោងពីរថ្ងៃ ទើបឡានត្រឡប់មកយកពួកយើងមួយជើងក្រោយទៀត ។ យើងជិះនៅលើឡានឃ្លានបាយគ្រប់ៗគ្នា ។ មិត្តឈ្លបក្មេងៗពីរនាក់ឈរនៅជិតខ្ញុំក្នុងឡានបាននិយាយប្រាប់ពួកយើងថា «មិត្តដឹងទេ ពួកទៅព្រឹកមិញយើងយកទៅទ្រាប់គល់ដញ្ញ្រូងអស់ហើយ» ។ កាលនោះ ខ្ញុំមិនបានចាប់អារម្មណ៍នឹងពាក្យនេះ ស្មានតែភូមិគេឈ្មោះគល់ដញ្ញ្រូង ។ ដឹងអីគឺគេយកទៅវាយចោលសោះ (ក្រោយមកទើបខ្ញុំដឹង) ។ ប្រហែលម៉ោងប្រាំល្ងាច ឡានបានដឹកពួកយើងយកមកដល់សិរីសោភ័ណ ។ ផ្ទះរាប់សិបល្វែងស្ងាត់ឈឹងនៅទំនេរគ្មានមនុស្សនៅ ។ គេប្រាប់ឲ្យពួកយើងចូលសម្រាកផ្ទះណាក៏បាន ចាំបន្តិចទៀតគេហៅទៅហូបបាយ ។ ផ្ទះធំល្វឹងល្វើយគ្មានមនុស្សនៅ គ្មានតុទូអ្វីទាំងអស់មានតែក្រងស្បូវនៅពេញផ្ទះ

ពួកយើងអង្គុយអាណោចអាធ័មដល់ម្ចាស់ផ្ទះ (ទាំងអស់នេះមានវាសនាដូចពួកយើងដែរក៏មិនដឹង) ។ ក្រុមខ្លះជជែកគ្នាថា ពុំដឹងគេយកពួកយើងទៅប្រឡាក់ផ្សៀតអីទៀតដែលនាំគ្នារត់ចោលស្រុកដូច្នេះ ។ ល្ងាចងងឹតបន្តិច ហើយមានសមមិត្តស្រី-ប្រុស ពីរ-បីនាក់បានដើរហៅពួកយើងទៅហូបបាយ ។ ក្នុងរោងបាយឈើប្រក់ស័ង្កសី ក្រោមពន្លឺចង្កៀងម៉ាំងសុងដែលយើងខាន ឃើញជាយូរមកហើយ ។ បាយអង្ករសក្បុសដូចសំឡី សម្លម្ជូរដើមចេកឆ្ងាញ់អើយសែនឆ្ងាញ់ ។ ណាអត់បាយតាំងពីព្រឹកម៉្លេះ ម្នាក់ៗកាយយកៗម៉ាចាស់ដៃ ម៉ាណែនក្រពះបំណាច់ឃ្លានយូរហើយ ។ ក្រោយពេលបាយរួច គេអនុញ្ញាតឲ្យពួកយើងដួសបាយ យកស្រេចតែចិត្តច្រកចូលកូនឆ្នាំង កូនធុងយួរតូចៗ ដើម្បីទុកហូបតាមផ្លូវនៅវេលាព្រឹកស្អែក ។ មកដល់កន្លែងវិញ យើងចេះតែ ពិចារណាថា ប្រហែលបានហូបឆ្ងាញ់ជាចុងក្រោយក៏មិនដឹង ។

## ទឹកជោរ អន្លង់មរណៈប្ដីខ្ញុំ

ព្រឹកព្រលឹមឡើង មេឃភ្លឺព្រាលៗឯចុងស្រែ សន្សើមនៅធ្លាក់នៅឡើយ ។ យើងត្រូវគេបញ្ជាឲ្យឡើងឡានដដែលពី ម្សិលមិញទៀតដោយប្រញាប់ប្រញាល់ ។ ឡានបរទៅហើយ តាមផ្លូវកៅស៊ូ យើងពុំដឹងថាជាផ្លូវណាទៅផ្លូវណាទេ ។ មានតែ បងប្រុសម្នាក់គត់ស្រែកថា ដល់ផ្លូវបត់ចូលភូមិចាស់យើងហើយ តែឡាននៅតែបន្តដំណើរទៅមុខទៀត ។ លាហើយភូមិដើងវត្ត ស្រុកព្រះនេត្រព្រះ ពុំដឹងជាគេយកពួកយើងទៅដល់ណាទេ ។ រហូតដល់ថ្ងៃត្រង់ទើបឡានឈប់ត្រង់ផ្លូវលំតូចមួយ ។ សមមិត្ត ក្មេងៗប្រុស-ស្រីប៉ុន្មាននាក់បញ្ជាឲ្យពួកយើងចុះ ។ ខ្លះរែក ខ្លះទូល ដើរសំដៅទៅភូមិមួយមានចម្ងាយ១០០ម៉ែត្រ ដែលយើង មើលឃើញតាំងពីផ្លូវធំទៅម្ល៉េះ ។ ខ្ញុំត្រូវរែកអីវ៉ាន់បន្តិចបន្តួចជំនួសប្ដីខ្ញុំ ដែលគ្មានកម្លាំងកំហែងបន្តិចសោះក្នុងខ្លួន ។ កូនប្រុសខ្ញុំ ដើរតាមពីក្រោយដោយយួរកូនឆ្នាំងដាក់បាយផង ។ ណាដងរែក វាកប់ស្មាខ្ញុំឈឺពេករែកបណ្ដើរខ្ញុំយំបណ្ដើរ ។ ប្ដីខ្ញុំមួម៉ៅក្នុងចិត្ត ណាស់ពេលឃើញខ្ញុំយំ ។ គាត់រអ៊ូថា «យំស្អីមិនទាន់ព្រាត់ប្រាសគ្នាផង» ខ្ញុំរឹតតែយំខ្លាំងឡើង ហើយដូចជាមានប្រផ្នូលក្នុងចិត្តថា មិនស្រួល ព្រោះរស់នៅកម្សត់កម្រនឹងគ្នាជិតបីឆ្នាំ ហើយគាត់ពុំដែលមានពាក្យទ្រគោះបោះបោកឲ្យខ្ញុំដូចពេលនេះសោះ ។ យើងទាំងអស់គ្នាដើរដល់ភូមិមួយ គេឲ្យយើងចូលសម្រាកក្នុងសាលាសំណាក់មួយ ។ ប្រហែលកន្លះម៉ោងក្រោយមក មាន សមមិត្តប្រុសៗពីរ-បីនាក់ដើរចូលមក ។ សមមិត្តម្នាក់ អាយុប្រហែលហាសិបឆ្នាំ សក់ល្បាយអាចម៍ខ្លា ភ្នែកធំ បៀមបារីស្លឹក សង្កែ ហើយមានមិត្តនារីក្មេងៗបួនប្រាំនាក់ទៀតដើរអមមកជាមួយ ។ យើងអង្គុយតម្រៀបគ្នាដើម្បីស្ដាប់សមមិត្ត អាយុជាង ៥០ឆ្នាំនេះនិយាយ ។

សមមិត្តនិយាយដោយទឹកមុខមាំថា «បងប្អូនទាំងអស់គ្នា ត្រូវមកនៅទីនេះ ទីនេះឈ្មោះភូមិទឹកជោរ ។ បងប្អូនត្រូវកសាង ខ្លួន រៀបចំសតិអារម្មណ៍ឲ្យបានល្អឡើងវិញឲ្យអង្គការឃើញ ព្រោះបងប្អូនមានកំហុសធ្ងន់ណាស់ដែលហ៊ានរត់ចោលស្រុក ។ បើបងប្អូនមិនព្រមកែខ្លួនទេ ហើយហ៊ានរត់ជាលើកទីពីរទៀតនោះ ភ្នំជញ្ជាំងគឺជាកន្លែងចុងក្រោយរបស់បងប្អូនទាំងអស់គ្នា ហើយ» ។ ពួកយើងព្រឺក្បាលខ្នាក ។ សមមិត្តនិយាយដោយលើកដៃចង្អុលទៅភ្នំមួយដែលយើងមើលទៅឃើញនៅមិនឆ្ងាយពី ភូមិនោះដែរ ។ ក្រោយមក ខ្ញុំឮអ្នកមូលដ្ឋានម្នាក់លួចនិយាយប្រាប់ខ្ញុំថា «ភ្នំជញ្ជាំងនេះជាកន្លែងសម្រាប់ដាក់អ្នកទោសធ្ងន់ៗ ។ អ្នកទោស ហូបតែបាយក្រៀមទេ ពេលធ្វើការគឺគេដាក់ច្រវាក់ជើង ព្រោះខ្លាចអ្នកទោសរត់» ។

បន្ទាប់ពីព្រមានយើងហើយមួយស្របក់ សមមិត្តនារីម្នាក់បានដើរមកហៅយើងទៅហូបបបរ ។ ខំគេចពីបបរ ឥឡូវមក ជួបបបរទៀត ។ ប្ដីខ្ញុំឲ្យខ្ញុំទៅហូបជាមួយកូនប្រុសភ័ក្ត្រខ្ញុំចុះគាត់មិនឃ្លានទេ បើសុំគេបានក៏សុំបន្តិចមក ។ ខ្ញុំក៏លូកយកស្លាបព្រាពីរ នៅក្នុងបង្វេចដាក់ខោអាវ ពួកយើងទាំងបីនាក់មានតែស្លាបព្រាប៉ុណ្ណោះគ្មានចានទេ ។ ខ្ញុំដើរសំដៅមាត់ស្ទឹងដែលនៅជិតរោង បាយ ដើម្បីលាងស្លាបព្រាមុនទៅហូបបបរ ។ គ្រាន់តែលូកដៃ ស្លាបព្រាជ្រុះចូលក្នុងទឹកភ្លាមដូចមានដែកឆក់អ៊ីទាញយកស្លាបព្រា ពីក្នុងដៃខ្ញុំទៅបាត់ ។ ខ្ញុំយល់ថាកាន់តែឲ្យហេតុមិនស្រួលហើយ ប្រហែលមានពីរនាក់ត្រូវរបូតក៏មិនដឹង ។ ខ្ញុំបន់ស្រន់លោកតា ព្រៃភ្នំ ម្ចាស់ទឹកម្ចាស់ដី សូមជួយគ្រួសារខ្ញុំនិងបងប្អូន១៧មេសាទាំងអស់បានរួចរស់ជីវិតផង ។

អង្គការឲ្យគ្រួសារខ្ញុំរស់នៅក្នុងផ្ទះល្វែងៗជាប់គ្នាបីបន្ទប់ ។ កន្លែងនោះពីដើមជាជង្រុកស្រូវ តែឥឡូវអស់ស្រូវហើយគេឲ្យមនុស្សនៅម្តង ។ ពួកយើងទៅចំពេលភ្លៀងធ្លាក់ល្មម ហេតុនេះក៏ដល់ពេលធ្វើស្រែដែរហើយ ។ ព្រឹកនេះតាំងពីព្រលឹម សមមិត្តនារីម្នាក់រាងចំណាស់បន្តិចបានដើរមកហៅពួកយើងទៅដកស្ទូង នៅស្រែឆ្ងាយពីភូមិប្រហែលមួយគីឡូម៉ែត្រ ។ គេឲ្យយើងយកចានឆ្នាំងនិងស្លាបព្រាទៅជាមួយផង (គឺចានហូបបាយ តែសម្រាប់យើងអ្នករត់នេះ ចានឆ្នាំង) ។ ខ្ញុំសុំច្បាប់គេឲ្យប្តីខ្ញុំទម្រាំតែបានគេអនុញ្ញាតឲ្យឈប់បី-បួនថ្ងៃ គេស្តីឲ្យដូចសត្វធាតុ ។ សមមិត្តកាន អាយុ៥០ឆ្នាំ ជាប្រធានភូមិដែលពួកយើងជួបពីដំបូង ស្តីឲ្យប្តីខ្ញុំថា "សុទ្ធតែពួកសតិអារម្មណ៍មកដល់មិនទាន់បានធ្វើអ្វីផង ក៏ឈឺទៅហើយ បានតែកុំឲ្យហូប" ។ នៅក្នុងស្រែពួកយើងធ្វើការសឹងតែមិនបាន ព្រោះតែកែវភ្នែកសម្លក់សម្លឹងរបស់ពួកអ្នកមូលដ្ឋានគ្រប់គ្នា ដែលមើលមកយើងដោយគ្មានក្តាញ់សឹងតែចង់ស៊ីសាច់ពួកយើង ។

## សម្ពន្ធមេត្រីក្រគោ

ពេលវេលាកន្លងទៅប្រហែលកន្លះខែហើយ ប្តីសម្លាញ់ខ្ញុំ ក៏បានជាស្រួលបួលពុំដឹងជាដោយសារថ្នាំអាចម៍ទន្សាយ ឬក៏ជាដោយសារអ្វីទេ ។ គាត់ត្រូវគេបញ្ជាឲ្យចេញភ្ជួរជាមួយគេឯង ព្រោះជាកម្លាំងទីមួយ ។ នៅភូមិទឹកជោរនេះមានគ្រួសារចាមប្រហែល ១០គ្រួសារដែរ ។ ពួកបងប្អូនចាមយើងត្រូវគេធ្វើបាបស្ទើរស្លាប់ស្ទើររស់នៅពេលមានសាច់ជ្រូកហូបម្តងៗ ។ ប្អូនស្រីប្រាហ៊ីម អាយុប្រហែល២៤-២៥ឆ្នាំ បានលួចនិយាយប្រាប់ខ្ញុំ ដោយទឹកភ្នែកថា "ពួកនាងក្រុមចាមនេះមកនៅភូមិនេះប្រហែលមួយឆ្នាំហើយ ហូបតែបបរទេខ្ទះប្រាំងខ្ទះវស្សា ។ យូរៗគេមានសម្លសាច់ជ្រូកឲ្យហូបម្តង ប៉ុន្តែពុំដែលឃើញសាច់ទេ ឃើញតែខ្លាញ់អណ្តែតត្រា ។ គេបង្ខំឲ្យម្តាយនាងហូបសម្លហ្នឹង ទោះជាគាត់សុំតែអំបិលគេពីរ-បីគ្រាប់ជំនួសក៏មិនបានដែរ ។ ក្រោយមកពីរ-បីខែ ម្តាយនាងក៏ស្លាប់ទៅពុំដឹងជាឈឺអី ។

នៅជាប់បន្ទប់ដែលខ្ញុំរស់នៅមានគ្រួសារចាមមួយ ។ បន្ទប់ក្រង់ស្រូវខ្ញុំធ្វើពីដីភក់លាយនឹងអាចម៍គោនិងចំបើង (វែងជាមួយ បន្ទះឬស្សី) ។ អ៊ំសាឡេះ គាត់មានប្រពន្ធនិងកូន៥នាក់ តែឥឡូវ នៅសល់តែកូនពីរប៉ុណ្ណោះ ។ គាត់ជាមនុស្សមានអធ្យាស្រ័យល្អណាស់ ។ គាត់អាណិតស្រលាញ់គ្រួសារខ្ញុំណាស់ ហើយគាត់ក៏ភ្ជួររាស់ជាមួយប្តីខ្ញុំដែរ ។ គាត់តែងប្រាប់ប្តីខ្ញុំឲ្យប្រយ័ត្នមាត់ក កុំនិយាយផ្តេសផ្តាស កុំធ្វើឫកពាអ្វីមិនសមរម្យឲ្យសោះ ។ ឈ្លបនៅទីនេះក្មេងៗទេ ប៉ុន្តែសាហាវឃោរឃៅណាស់ ។

នៅស្រុកនោះពុំគ្រាន់តែអត់ទេ គឺខ្វះត់ថែមទៀត ។ សូម្បីតែខសក៏ពិបាករកដុតដែរ គឺមានតែឫស្សីដែលយើងត្រូវចូលទៅទាញយកដោយពិបាក ។ ជួនឃើញទំពាំងក៏ដីកយកតែម្តង តែពេលចេញមកវិញអាវខ្ញុំក៏ត្រូវរហែករយ៉ែអស់អាវមួយទទេ ។ ចំណែកអ្នកមូលដ្ឋានវិញ ទោះហូបបបរតែគេក៏ចេះតែមានអង្ករខ្ទះៗដែលមិនដឹងបានមកពីណាអាចធ្វើនំអំបែងផ្អែមញាំ គឺយកអង្ករកិនឲ្យម៉ដ្ត ហើយលាយទឹកនិងស្ករត្នោតចាក់លើខ្ទះជាបន្ទះស្តើងៗក៏គ្រាន់ហូបដែរ ។ ឬជួនកាលគេចាក់ជាបាញ់ឆែវដាក់ស្នូលសាច់ត្រី ហើយផ្ទាប់ជាមួយស្លឹកឈើព្រៃឬត្រយលៀង ដែលអាចហូបបានជ្រលក់ទឹកអំបិលជូរអែមក៏គ្រាន់ហូបដែរ ។ នៅពេលដែលគេកំពុងតែហូប ប្រសិនបើយើងដើរទៅឃើញ គេក៏ហៅយើងហូបដែរ តែកុំច្រឡំគឺហៅក្នុងការគួរសមប៉ុណ្ណោះ តែក្នុងពោះវិញគឺភ័យអ៊ូចៗខ្លាចយើងហូបមែន គេនឹកក្នុងពោះថា ស៊ីឲ្យអស់ឲ្យខានអញទៅ ។

នៅក្នុងភូមិនេះទៀតសោតគ្មានស្លឹកឈើស្លឹកព្រៃដូចជា ស្លឹកបាស ត្រកួនជ្វីអ្វី ដើម្បីយកស្ងោរហុតក៏គ្មានដែរ ។ ប្រសិនបើដើមត្របែកវិញមានតែមែកនិងស្លឹកចាស់ៗប៉ុណ្ណោះ ។ គេហាម មិនឲ្យជនភៀសខ្លួនមានកម្មសិទ្ធិសួនតួអ្វីទេ ហាមដាំបាយ ធ្វើម្ហូបនៅផ្ទះ គឺអាចដាំតែទឹកប៉ុណ្ណោះ ។ អ្នកមូលដ្ឋានទាំងថ្មីទាំងចាស់ តែងនាំគ្នាដំណាលថា ចម្លែកណាស់ ឃើញមានអាចម៍នៅតាមគុម្ពឈើដូចអាចម៍ជ្រូក តែដានជើងគឺដានជើងមនុស្សទៅវិញ ។ មិនប្លែកទេ ព្រោះចំណីអាហារមិនដល់ ម្ល៉ោះហើយអាចម៍មនុស្សដូចអាចម៍ជ្រូក ។ ហ្នឹងហើយរបបបងពតមហាលោតផ្លោះ មហាអស្ចារ្យ ។

ល្ងាចនេះ ក្រោយពីហូបបបរហើយ អ៊ំសាឡេះ បានស្រែក សួរខ្ញុំថា "មិត្តណាងៗ មានអំបិលទេ ឲ្យខ្ញុំមួយស្លាបព្រាមក ខ្ញុំ

កំពុងតែស្ងូរសាច់គោវាខុះអំបិល ហើយចាំមួយស្របក់ទៀត វាផុយចាំខ្ញុំដួសឲ្យមួយចាន» ។ ខ្ញុំឮដូច្នេះអរណាស់ ក៏យកអំបិលឲ្យគាត់ហើយនឹកក្នុងចិត្តថា ច្បាស់ជាបានឆ្ងាញ់មាត់ហើយ ។ ប្រហែលជាពាក់កណ្ដាលយប់ទៅហើយ គ្រួសារខ្ញុំអង្គុយចាំសម្ល ម្ងូរសាច់គោទាល់តែគេងលក់ទាំងអស់គ្នា ។ ខ្ញុំក៏ភ្ញាក់ឡើងដោយឮសំឡេងខ្សឹបៗ ហៅនៅមាត់ទ្វារថា «មិត្តណាងៗ យកសម្អិនហើយ» ។ ផ្ទះក្នុងរបបនោះគ្មានសន្លឹកទ្វារ គឺបើកចំហ ដើម្បីឲ្យអង្គការមើលឃើញតើយើងកំពុងធ្វើអ្វីខ្លះ ។

ខ្ញុំដាស់ប្ដីហើយនិងកូនប្រុសខ្ញុំឲ្យភ្ញាក់ឡើងដើម្បីហូបសម្លសាច់គោ ។ ខ្ញុំហុតមួយម៉ាត់ទៅជូរជ្រះរបស់គេគ្រាន់បើ គឺស្លឹកអំពិលចាស់ៗដាក់ធ្វើម្ជូរ ។ ខ្ញុំដួសសាច់គោមួយដុំមកទំពារ ពុទ្ធោចង់បាក់ធ្មេញ សាច់ស្អីគេក៏ដូចថ្មដូច្នេះ? ខ្ញុំអើតទៅសួរ អ៊ំសាឡេះតិចៗថា «អ៊ំៗ សាច់គោអីក៏រឹងម្ល៉េះ សាច់ក្របីទេឬ?» អ៊ំសាឡេះ ឆ្លើយមកវិញថា «ហូបទៅ គឺព្រ័ត្រគោហ្នឹងណា៎ អ៊ំលួចពីរទេះគោផង កុំមាត់ប្រយ័ត្នគេដឹងរឿងធំហើយ» ។ ហេតុនេះ ទើបខ្ញុំស្គាល់ព្រ័ត្រគោតាំងពីពេលនោះមក ។ អ្នកបររទេះទាំងអស់ត្រូវប្រយ័ត្នរឿងព្រ័ត្រគោ បើបាត់ព្រ័ត្រគោគឺអ្នកមើលគោត្រូវទទួលខុសត្រូវ ។ ជួនបាត់ខ្លួនរហូតក៏មាន ។ ក្នុងគ្រាដ៏សែនលំបាកវេទនានោះ ជីវិតពួកយើងប្រៀបបានដូចទឹកមួយតំណក់ នៅលើស្លឹកឈូកប៉ែលប៉ោលកណ្ដាលព្យុះសង្ឃរា រេរាចុះឡើងដោយកម្លាំងព្យុះបក់បោករង់ចាំតែថ្ងៃមរណាប៉ុណ្ណោះ ។ ម្នាក់ៗ បើដើរទៅធ្វើការសឹងតែរកកម្លាំងកំហែងគ្មាន ខ្លះគ្រាន់តែត្រឡប់មកពីដកស្ទូងវិញដើរតាមភ្លឺស្រែក្រោមតំណក់ទឹកភ្លៀងតិចៗ គ្រាន់តែដួលក៏ស្លាប់នៅក្នុងស្រែតែម្ដងទៅ ព្រោះតែដាច់ជាតិបាយយូរពេកក៏មិនដឹង ។

ពីមួយថ្ងៃទៅមួយថ្ងៃ ពួកយើងកាន់តែរលស់បាត់ទៅៗ ។ ជួនកាលគ្រួសារខ្លះក្រោយពីមកហូបបបរល្ងាចហើយរៀបចូលសម្រាក ក៏មានឈ្លបក្មេងៗពីរ-បីនាក់ហៅទៅជួយធ្វើការនៅរោងបាយមួយភ្លែត តែក៏បាត់សូន្យរហូតទៅក៏មានដែរ ។

## គ្រូបង្រៀន សាយ ត្រូវគេតាមចាប់ខ្លួន

នៅក្នុងស្រែកន្ទែងភ្លួររាស់ ប្ដីខ្ញុំគាត់ស្គាល់មិត្តភក្ដិជាច្រើន ដែលជាអ្នក១៧មេសាដូចគ្នា ហើយនៅភូមិជិតនេះដែរ តែមកភ្លួរនៅជិតគ្នា ។ ពេលសម្រាកពីការងារ ពួកគាត់តែងអង្គុយជជែកគ្នាលេង ហើយចែកថ្នាំគ្នាជក់មូរស្លឹកសង្កែម្នាក់បន្តិចៗ ។ ក្នុងចំណោមនោះ ប្ដីខ្ញុំស្គាល់មិត្តម្នាក់ឈ្មោះ សាយ ជាអតីតគ្រូបង្រៀន ។ បងសាយ មានអាយុប្រហែល៣០ឆ្នាំប៉ុណ្ណោះ ។ មុខគាត់ឆ្អឹងគម្រាំង ស្បែកមុខជ្រីវជ្រួញ ថ្ពាល់ផត ក្រហូង ភ្នែកល្អក់ស្រអាប់ សក់កន្ទ្រើងដូចមិនដែលស្គាល់កន្ត្រៃ សាច់ខ្មៅឡើងជ្រួញដូចតាចាស់អាយុ៥០ឆ្នាំ ។ បងសាយ ខ្សឹបរ៉ាប់លួចថ្ងូរប្រាប់ប្ដីខ្ញុំថា គាត់ប្រហែលជារស់មិនបានយូរទេ ព្រោះគេចេះតែសង្ស័យគាត់ថាជាអ្នកធ្វើការ ។ យប់ដែលគាត់បារម្ភក៏មកដល់ ។ យប់នោះម៉ោងប្រហែល៨-៩ យប់ទៅហើយ គ្រូសាយ ក៏មកដល់ផ្ទះខ្ញុំទាំងទឹកមុខភ័យព្រួយពាក់អាវខ្មៅរហែកខ្នងផង មានបង់កក្រមាកញ្ចាស់មួយផង ។ គ្រាន់តែមកដល់ផ្ទះខ្ញុំភ្លាម គ្រូសាយ ក៏ទៅអង្គុយនៅកន្ទៀតជញ្ជាំង ហើយខ្សឹបសួរប្ដីខ្ញុំថា «ប្អូនហ្លួត រត់ទៅជាមួយគ្នាឬទេ?» គាត់បន្ថែមដោយដង្ហក់ថា «ខ្ញុំត្រូវគេតាមរកចាប់ខ្លួនហើយ យប់មិញបាត់អស់គ្នាខ្ញុំពីរនាក់ ហើយយប់នេះប្រហែលជាដល់វេនខ្ញុំក៏មិនដឹង» ។ ប្ដីខ្ញុំឡិងឡង់ងាកមើលមុខខ្ញុំ និងកូនប្រុសខ្ញុំទាំងមិនដឹងឆ្លើយយ៉ាងម៉េច ។ ប្ដីសម្លាញ់ខ្ញុំឆ្លើយថា គាត់មិនដាច់ចិត្តចោលប្រពន្ធកូនទេ ។ ពួកយើងអាណិតបងសាយ ណាស់ ហើយមិនដាច់ចិត្តឲ្យគាត់ទៅដោយគ្មានអ្វីទ្រាប់ពោះមួយគ្រាប់ដូចនេះសោះ ។ ជាសំណាងល្អ ប៉ុន្មានថ្ងៃមុនប្ដីខ្ញុំបានអង្ករពីរកំប៉ុងដែរ ។ ខ្ញុំបានដាក់ដាំបបរក្នុងកំសៀវទឹកជូន បងសាយ ហូបទាំងភ័យព្រួយ ។ បបរដាក់ទឹករាវកក្លក យើងចែកគ្នាហុតទាំងអស់គ្នា តែយើងឲ្យ បងសាយ ហូបច្រើនជាងគេ ។ ខ្ញុំបានយកអង្ករកន្លះកំប៉ុងទៀតលីងឲ្យឆ្អិនដើម្បីទុកឲ្យគាត់ហូបតាមផ្លូវ ។ ពួកយើងសម្រាកលើគ្រែរនឿមួយជាមួយគ្នា ។ ប្ដីខ្ញុំ និងបងសាយ និយាយខ្សឹបខ្សៀវគ្នាចង់ទល់ភ្លឺ ។ មាន់រងាវម្ដង បងសាយ វេចអង្ករលីងនៅជាយក្រមា ហើយលាពួកយើង ដោយសំឡេងអួលអាក់ថា «ប្អូនប្រុសប្អូនស្រីទាំងពីរ អង្ករលីងកន្លះកំប៉ុងនេះ បងគ្មានថ្ងៃភ្លេចបានទេ បើថ្ងៃក្រោយបងមានវាសនាល្អបានជួបគ្នាទៀត បងនឹងសងគុណប្អូនទាំងពីរឲ្យអស់ពីចិត្តពីថ្លើម» ។ ប្ដីប្រពន្ធខ្ញុំរលីងរលោងទឹកភ្នែក ហើយជូនពរ បងសាយ បានសេចក្ដីសុខជារៀងរហូត ។ បងសាយ លាយើង

ទៅហើយ គាត់មានវាសនាយ៉ាងម៉េចក៏យើងមិនដឹង ។

## ក្លាយខ្លួនជាចាប៉ីទីពីរដោយមិនដឹងខ្លួន

យើងហើមជើងដាបណ្ដើរៗ ទាំងកូនប្រុសភ័ក្ត្រខ្ញុំក៏ដូច្នេះ ដែរ ។ នេះគឺទណ្ឌកម្ម គឺគុកគ្មានជញ្ជាំងដែលយើងមើលមិនឃើញ ដែលគេដាក់ទោសពួកយើង ។ ដែលហៅថាភូមិទឹកដោរ គឺសួងថ្ងៃនេះស្អែកឡើងដោរលិចស្រូវសន្ទូងអស់ ។ ធ្វើហើយធ្វើទៀត ធ្វើមិនចេះរួច ។ ព្រឹកនេះខ្ញុំរៀបចេញទៅស្រែ ប្ដីខ្ញុំក៏រៀបទៅភ្ជួរដែរ សមមិត្តកាន ជាប្រធានភូមិ មានឈ្លបក្មេងៗ ពីរ-បីនាក់ដើរមកជាមួយ ។ សមមិត្តកាន និយាយជាមួយប្ដីខ្ញុំដោយទឹកមុខមាំថា «ស្នើមិត្តហួត ទៅជួយភ្ជួរស្រែនៅភូមិខាងជើងបានពីរ-បីថ្ងៃ នៅសម្រាកទីនោះតែម្ដង» ។ ប្ដីខ្ញុំក៏ប្រញាប់ប្រញាល់ទាញក្រមាមកបង់ក ហើយដើរទៅជាមួយមិត្តកាន ។ ដើរបានពីរជំហានមិនដឹងគាត់នឹកឃើញយ៉ាងម៉េចក៏ងាកមកខ្ញុំ ហើយលូកហោប៉ៅអាវយកដែកកេះដែលប្រើគហុចមកឲ្យខ្ញុំ ក្រែងត្រូវការបង្កាត់ភ្លើងយប់ព្រលប់ ។ ខ្ញុំមិនទទួលហើយប្រាប់ថា «យកទុកប្រើទៅក្រែងនៅកណ្ដាលវាលស្រែពិបាករកភ្លើងជក់បារី» ។ ដែកកេះនោះរុញទៅរុញមកទម្រាំតែប្ដីខ្ញុំដាច់ចិត្តដាក់ហោប៉ៅយកទៅ ហាក់ដូចជាការលាគ្នាជាចុងក្រោយដូច្នេះ ។ ព្រឹកនោះដដែល នៅក្នុងស្រែ ខ្ញុំកំពុងតែស្ទូង មានឈ្លបក្មេងម្នាក់ បានដើរមកស្ទួងជិតខ្ញុំ ហើយសួរខ្ញុំថា «មិត្តឯងអាយុប៉ុន្មានហើយ?» ខ្ញុំឆ្លើយថា «ខ្ញុំអាយុ២៧ឆ្នាំហើយមិត្ត» ។ ឈ្លបនោះ សើចហើយនិយាយថា «អាណិតណាស់មេម៉ាយនៅក្មេងពេក» ។ ខ្ញុំប្រញាប់ឆ្លើយភ្លាមថា «មិត្តប្អូនឯងប្រឡំទេដឹង គ្រួសារខ្ញុំនៅរស់ទេតើ» ។ ឈ្លបនោះសើចហើយដើរចេញទៅ ។ យប់នោះខ្ញុំមិនដឹងថាជាថ្ងៃអី ខែអី ឆ្នាំអីទេតែខ្ញុំចាំថាជាយប់ខែរះពេញបូរមី ។ ខ្ញុំរសាប់រសល់គេងមិនលក់សោះ ខ្ញុំអង្គុយមើលលោកខែនៅមាត់ទ្វារ ហើយក៏លង់លក់ទាំងអង្គុយនោះទៅ ។ យប់នោះ ខ្ញុំយល់សប្តិឃើញបាក់កូនកាំបិតនៅសល់តែមួយដែលខ្ញុំខំរក្សាទុកតាំងពីចេញពីភ្នំពេញទៅម្ល៉េះ ។ ខ្ញុំភ្ញាក់ឡើងញ័រខ្លួនដូចកូនសត្វ ។ នឹកដល់ប្ដីសម្លាញ់ នឹកដល់សំណួរដែលឈ្លបក្មេងសួរខ្ញុំ ពីថ្ងៃ ខ្ញុំស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ។ ខ្ញុំលើកដៃសំពះទេវតាម្ចាស់ទឹកម្ចាស់ដី សូមលោកជួយថែរក្សាប្ដីសម្លាញ់របស់ខ្ញុំកុំឲ្យគាត់មានគ្រោះថ្នាក់អ្វីឲ្យសោះ ។ នាគ្រានោះ ខ្ញុំតម្អូញទួញថ្ងូរដោយមិនដឹងខ្លួន÷

- បងសម្លាញ់ បងកុំកើតអីឲ្យសោះ បងកុំទៅចោលប្រពន្ធ និងកូនឲ្យនៅកណ្ដាលសមុទ្រឈាមនេះអី ។

- សំឡេងយំសោករបស់ខ្ញុំបានឮដល់ អ៊ំសាឡេះ ដែលនៅជាប់ជញ្ជាំងផ្ទះខ្ញុំ ។ អ៊ំសាឡេះ អើតមកបន្ទប់ខ្ញុំហើយនិយាយខ្សឹបៗ ថា÷

- មិត្តណាងអើយ កុំយំឮពេកប្រយ័ត្នគេឮ ។

នាងខ្ញុំសរសេរដល់ត្រង់ណេះខ្ញុំអួលដើមក នឹកដល់គ្រាដ៏សែនមហាកម្សត់នេះណាស់ ។ ជីវិតពួកយើងទាំងអស់គ្នាហាក់ដុយស្រួយរកទីបំផុតគ្មាន ។ ពោលៈ ក្នុងគ្រាកម្សត់ពួកយើងមិនដែលក្បត់គ្នាសោះឡើយ ទោះបីមានអ្វីញាំមួយម៉ាត់មួយកក៏នឹកភ្នករកគ្នាគ្រប់ដង្ហើម ។ ទៅលួចវេចខ្ចប់យ៉ាងណាស្រវាឲ្យតែបានដល់ផ្ទះនឹងអាលស្រាយចែកគ្នាញ៉ាំភ្លាម ។ នឹកឃើញកាលគ្រាមួយនោះណា៎ រូបប្រុសរៀមរ៉ាចេញរកម្ហូបត្រឡប់មកវិញបានជួបក្រុមឈ្លបត្រូវគេពិន័យឲ្យលើកដី ។ រូបស្រីល្ងិតល្ងង់មិនចេះអីសូម្បីតែត្រីក៏មិនចេះរក សូម្បីតែស្លឹកឈើព្រៃក៏មិនស្គាល់បុកស្រូវរែកទឹកក៏មិនចេះ ។ មានតែទឹកភ្នែកហូរជ្រែកភ័ក្ត្រស្រីដែលធ្លាប់ប្រដូរ រៀបរាប់រឿងចុកណែនពេញឱរ៉ា ។

## ភ្ញៀវច្រមុះស្រួច

មួយថ្ងៃ ពីរថ្ងៃ បីថ្ងៃកន្លងផុតទៅ ។ នៅព្រឹកនេះ ខ្ញុំរៀបចេញទៅធ្វើការហើយ ខ្ញុំឃើញសមមមិត្តកាន ព្រមទាំងឈ្លបចាស់-ក្មេងប្រហែលដប់នាក់មុខប្លែកៗ មានស្ពាយកាំភ្លើងវែងគ្រប់គ្នាដែលខ្ញុំមិនដែលឃើញពីមុនមកសោះ ។ ពួកគេដើរមកក្នុងបន្ទប់ខ្ញុំ ហើយ មិត្តកាន និយាយមកខ្ញុំថា÷

- មិត្តណាឯងបើចង់ឲ្យគ្រួសាររួចខ្លួនត្រឡប់មកវិញ មានស្អីប្រគល់ឲ្យអង្គការទាំងអស់មក ។ ខ្ញុំលស់ព្រលឹងភាំងស្មារតី រកនឹកមិនឃើញថាប្ដីខ្ញុំដូចជាគេហៅទៅជួយភ្ជួរទេ ហេតុអីក៏មានកំហុសវិញ? មិត្តកាន បន្តថា÷

- កុំឆ្ងល់អី មិត្តណាង ឯងប្ដីធ្វើការអីក៏អង្គការដឹងដែរ អង្គការភ្នែកម្នាស់ណាំ ។

ក្នុងពេល មិត្តកាន កំពុងនិយាយឈ្លបប៉ុន្មាននាក់ទៀតក៏ រើកកាយជជុះអីវ៉ាន់បន្តិចបន្តួចក្នុងបន្ទប់ខ្ញុំ ។ ពួកគេរើកកាយចាប់តាំងពីក្រឡអំបិល ប្រដាប់ញក់ញីខ្ទើយកើយ ចាក់ដេះក្នុង បង្ក្រានគ្មានឃើញអ្វីសោះ ។ ខ្ញុំនឹកក្នុងចិត្តថា ប្ដីសម្លាញ់ខ្ញុំពិតជាមានគ្រោះថ្នាក់អ្វីហើយ ។ ខ្ញុំមិនគិតយូរឡើយ ខ្ញុំរើក្នុងចង្កើរសំបុក មាន់ដែលមានមេមាន់មួយកំពុងក្រាបពងនៅពីក្រោយខ្នងឈ្លបម្នាក់ ហើយដែលគេពុំបានចាប់អារម្មណ៍ ។ នៅក្នុងចំបើងមាន កថាមាសសល់ប្រហែល៤-៥ ។ ខ្ញុំយកហុចឲ្យសមមិត្តកានដោយដៃពីរ រកនិយាយអ្វីក៏ពុំចេញដែរ ។ ឈ្លបក្មេងៗដើរចេញ អស់ហើយ ខ្ញុំនឹកឃើញនៅសល់លុយ២០០ដុល្លារនៅក្នុងខ្នារអំបោះសូត្រដែលខ្ញុំទុកជាយូរមកហើយ ។ ខ្ញុំក៏ទៅស្រាយអំបោះ យកលុយនោះដែលខ្ញុំរុំក្រណាត់កៅស៊ូជាច្រើនជាន់ពីក្រោយកមកហុចឲ្យ មិត្តកាន ជាសំណូកចុងក្រោយ ។ មិត្តកាន មិនស្គាល់ លុយអ្វីទេ សួរខ្ញុំទាំងលូកដៃយកថា÷

- លុយស្អីហ្នឹងមិត្តណាង?

ខ្ញុំមិនហ៊ានថាដុល្លារទេ ព្រោះខ្លាចថាខ្ញុំជាចក្រពត្តិអាមេរិក ឬជាខ្មែរសេ.អ៊ី.អា កាហ្សេបេ ស្អីគេនោះ ។

- ចា៎ស! លុយនេះទៅប្រទេសណាក៏ចាយបានដែរមិត្ត សូម មិត្តយកទុកចុះ ខ្ញុំមិនដឹងទុកធ្វើអីទេ ហើយសូមមិត្តបងជួយប្ដីខ្ញុំផង ។

មិត្តកាន មិនឆ្លើយ ដៃក្ដាប់លុយដើរចេញទៅយ៉ាងលឿន ។ ខ្ញុំរង់ចាំមើលប្ដីខ្ញុំមួយថ្ងៃហើយមួយថ្ងៃទៀត ចាំបាត់ៗមិនឃើញប្រុសថ្លៃត្រឡប់មកវិញសោះ ។ ព្រឹកនេះ ខ្ញុំគេតម្រូវឲ្យទៅស្ទូង នៅជិតផ្លូវជាតិ (ក្រោយមកខ្ញុំដឹងថាកន្លែងនោះគឺជិតស្ពានតាប៉ុន ជាប់ព្រំប្រទល់ខេត្តសៀមរាប) ។ ដើរតាមផ្លូវ ពួកយើងអ្នក ស្ទូងទាំងអស់គ្នាត្រូវសមមិត្តកាន មកពិនិត្យផ្ទាល់ មើលទៅដូចជាម៉ឺងម៉ាត់ណាស់ ហាក់មានសភាពការណ៍អ្វីប្លែក ។

មិត្តកាន បានប្រាប់ពួកយើងថា «ថ្ងៃនេះមានពួកបារាំង និងភ្ញៀវបរទេសច្រើនណាស់ មកលេងឆ្លងកាត់ផ្លូវស្រុកយើងនេះ ហេតុនេះបងប្អូនអ្នកស្ទូងទាំងអស់បើឃើញមានឡានបើកកាត់ តាមនេះត្រូវឱនស្ទូងទាំងអស់គ្នា ហាមមិនឲ្យងើបឈរដាច់ខាត ។»

ពួកយើងស្ទូងប្រហែលជិតថ្ងៃត្រង់ទៅហើយ ទើបឃើញ មានឡានមែរសីដែសស្ទើរចាស់ពណ៌សបីគ្រឿងបើកកាត់តាមផ្លូវនោះ ។ ពួកគេឈប់ឡានចម្ងាយប្រហែល៥០ម៉ែត្រពីពួកយើង ហើយមានពួកបរទេសបួន-ប្រាំនាក់ចុះពីឡាន ដៃកាន់ម៉ាស៊ីនថតតម្រង់មកពួកយើងដែលកំពុងឱនស្ទូង ។ ខ្ញុំនិងបងស្រីម្នាក់ ដែលស្ទូងជិតគ្នា ក្រោកឈរដោយស្វ័យប្រវត្តិភ្លេចគិតបំរាម ដែលមិត្តកាន ទើបនឹងហាម ។ ពួកយើងហាក់ចង់ស្រែកប្រាប់ បរទេសអស់នោះឲ្យជួយពួកយើងផង យើងវេទនាណាស់ ស្រាប់តែមិត្តកាន ស្រែកភ្ញាត់សំឡេងពីខាងក្រោយមកថា÷

- មិត្តឯងទាំងពីរចង់ស្លាប់អ្ហេស?

ពួកយើងឱនចុះវិញភ្លាម ។ ខ្លួនខ្ញុំឡើងញ័រចំប្រប់ ព្រោះ ហ៊ានល្មើសនឹងបញ្ជា ។ ក្រោយមកទើបខ្ញុំដឹងថា ហេតុដែលពួកគេមិនឲ្យយើងឈរ ព្រោះកុំឲ្យភ្ញៀវបរទេសឃើញរូបរាងស្គម កំព្រឹងរបស់ពួកយើង ។ ល្ងាចនេះខ្ញុំមកផ្ទះវិញ ឃើញកូនប្រុសខ្ញុំគេងស្ដូកស្ដឹងនៅលើគ្រែរលៀទាំងគ្មានកម្លាំងកំហែងក្នុងខ្លួន បន្តិចសោះ ។ ខ្ញុំគ្មានលទ្ធភាពអាចរកដូរអង្ករឬត្រីសាច់អ្វីបានទេ ព្រោះអស់មានរបស់សំខាន់អ្វីមានតម្លៃនឹងដូរបានឡើយ ។ អឺសាឡេះ ឲ្យខ្ញុំយកស្លឹកទឹកដោះគោមកដាំឲ្យកូនប្រុសខ្ញុំញុាំដើម្បីឲ្យវានោមបានច្រើនឲ្យវាស្រកហើម ប៉ុន្តែវាគ្រវីក្បាលមិនព្រម ញុាំសោះ ។ បបរក៏មិនញុាំ ទឹកក៏មិនញុាំ ។ ៣ថ្ងៃក្រោយមកកូនសម្លាញ់ខ្ញុំក៏ស្លាប់ចោលខ្ញុំទៅ ។

ខ្ញុំយំមិនចេញ ធ្វើអ្វីក៏មិនកើត គិតតែពីអង្គុយឱបសព កូន ។ កូនប្រុសសម្លាញ់ម្ដាយ កូនតស៊ូជាមួយម្ដាយយូរណាស់មកហើយ ឥឡូវអ្នកឃ្លាតចោលម្ដាយទៅទៀត ។ ចំណែកឯ ឪពុកកូនក៏មិនដឹងនៅឯណា ។ ខ្ញុំរផាងឯកាម្នាក់ឯងកណ្ដាលទន្លេដី

ធំធេង ។ អ៊ំសាឡេះ និងពួៗជិតពីរ-បីនាក់ទៀតមកជួយរុំសព កូនប្រុសភ័ក្ត្រខ្ញុំ ។ រីឯ អ៊ំសាឡេះ សួរខ្ញុំថា៖ មានខោអាវណាល្អជាងនេះបន្តិចទេ ផ្លាស់ឲ្យកូន?

ខ្ញុំឆ្លើយថា៖ គ្មានទេអ៊ំ ។

សាកសពកូនប្រុសសម្លាញ់ចិត្តខ្ញុំត្រូវរុំដោយកន្ទេល រហែកស្មៀកសម្លៀកបំពាក់កញ្ចាស់ គ្មានធូប គ្មានទៀន គ្មានព្រះសង្ឃឲ្យធម៌ គ្មានញាតិមិត្តចូលរួម គ្មានឪពុកនៅក្បែរ គ្មានអ្វីៗ ទាំងអស់ ក្រៅពីអ្នកជិតខាងពីរ-បីនាក់ ។

កូនខ្ញុំស្លាប់ទៅហើយ គេបានសុខហើយ គេទុកឲ្យខ្ញុំរស់នៅវេទនាកណ្ដាលលានមរណៈ ។

យប់នេះ ខ្ញុំអង្គុយស្រងេះស្រងោចម្នាក់ឯងនៅមាត់ទ្វារ បន្ទប់ខ្ញុំ ។ ខ្ញុំយល់ថាពិភពលោកនេះហាក់ដូចជាទូលាយណាស់សម្រាប់ខ្ញុំ រស់នៅគ្មានញាតិ គ្មានមិត្តអ្វីទាំងអស់ ។ នៅពេលដែលខ្ញុំកំពុងសរសេររឿងនេះ ទឹកភ្នែកខ្ញុំក៏ហូរហៀរមកដោយមិនដឹងខ្លួន គឺទឹកភ្នែកដែលរីងស្ងួតហួតហែងអស់រយៈពេលជាង ២៣ឆ្នាំទៅហើយ គឺទឹកភ្នែកឈឺចាប់ព្រាត់ប្រាស រន្ធត់ ញាប់ញ័រដែលមនុស្សលោកសម័យនេះមិនធ្លាប់ជួបប្រទះ ។

ចាប់ពីពេលនោះមកខ្ញុំលែងនឹកនាបាយទឹក ។ ខ្ញុំទៅធ្វើការដោយគ្មានកម្លាំងកំហែងក្នុងខ្លួនបន្តិចសោះ មិនខ្វីនិយាយរកអ្នកណាទាំងអស់ ។ អ៊ំសាឡេះនិងប្រពន្ធគាត់តែងនិយាយលួងលោមខ្ញុំដោយលើកឧទាហរណ៍ថា មានគេរាប់លាននាក់វេទនាដូចយើងអ៊ីចឹងដែរ យើងត្រូវតែតស៊ូរស់នៅដើម្បីនៅចាំជួបប្ដីប្រពន្ធ ឪពុកម្ដាយ បងប្អូនដែលបែកគ្នាជាង៣ឆ្នាំមកហើយ ។

ឥឡូវដល់ខែច្រូតហើយ ខ្ញុំពុំចាំថាជាខែអីឆ្នាំអីទេ ។ ខ្ញុំចាំថាក្រោយមរណភាពកូនប្រុសខ្ញុំ ៨-៩ថ្ងៃ គឺដល់ថ្ងៃភ្ជុំបិណ្ឌល្មមព្រោះមានប្រធានក្រុមពីរនាក់ដើរចែកអង្ករដំណើបតាមផ្ទះពួកខ្ញុំ ដែលទើបនឹងមកថ្មីនេះដែរ ។ គេដើរចែកឲ្យពួកខ្ញុំនៅពេលកណ្ដាលយប់ស្ងាត់ដើម្បីកុំឲ្យប្រជាជនចាស់ច្រណែន ។ ក្នុងម្នាក់ៗ គេចែកអង្ករដំណើបឲ្យពីរកំប៉ុងទុកវេចនំអន្សម ។ ខ្ញុំទុកក្នុងបន្ទប់ត្រូវគេចូលលួចបាត់ថែមទៀត ។ ខ្ញុំវិលវល់ឈរមើលតែទឹកស្អីងចោរចូលលួចយកខោអាវ យកឆ្នាំង យកចាន មួយថ្ងៃបន្តិចៗទីបំផុតគឺនៅសល់តែខោអាវមួយចង្កេះជាប់នឹងខ្លួន ។

ព្រឹកៗ ឡើងប្រពន្ធ អ៊ំសាឡេះ តែទាញដៃខ្ញុំទៅច្រូត ព្រោះកុំឲ្យគេស្ដីឲ្យខ្ញុំ ។ ខ្ញុំដើរទាំងគ្មានព្រលឹងទៅធ្វើការ ។ ខ្យល់ខែកត្តិកខ្ញុំដើរឆ្លងស្ពានដើមត្នោត ព្រឹកណាក៏ខ្ញុំធ្លាក់ទឹកប្រឡាយដែរ ។ ខ្ញុំត្រូវគេជួយទាញដៃឡើងពីទឹករងាររញ៉ែរញ៉ាក់ដូចកូនសត្វ ។ ចាននិងស្លាបព្រាដែលខ្ញុំកាន់យកទៅទុកហូបបាយក៏អណ្ដែតតាមទឹករាល់ថ្ងៃ ។ ទីបំផុតខ្ញុំអត់មានអ្វីទាំងអស់ គឺនៅសល់តែជីវិតមួយប៉ុណ្ណោះដែលពុំដឹងរបូតទៅថ្ងៃណាទៀត ។

ថ្ងៃខ្លះខ្ញុំមិនទៅធ្វើការ មិនហូបបាយ មិនខ្វីខ្លាចប្រធានភូមិ មិនខ្លាចឈ្លប មិនដឹងថាខ្លួនជាអ្នកណា ហើយឈ្មោះពិតប្រាកដក៏មិនដឹង គឺក្លាយជាឡឹកឺ វង្វេងវង្វាន់កណ្ដាលសង្គមឃាតករគួរឲ្យសង្វេគជាទីបំផុត ។

ប៉ុន្មានថ្ងៃនេះប្រពន្ធ អ៊ំសាឡេះ តែងមកដុះត្រចៀកខ្ញុំឲ្យខ្ញុំ មានព្រលឹងព្រលះឡើងវិញ ។ គាត់លួចខ្សឹបប្រាប់ខ្ញុំថា៖ នែ៎ក្មួយណាង! ប៉ុន្មានថ្ងៃនេះពួសូរកាំភ្លើងមាំណាស់ ហើយអ៊ំមើលទៅពួកឈ្លបដូចជាស្លូតណាស់ មិនសូវស្ដីឲ្យពួកយើងទេ តាំងស្មារតីឡើងក្មួយ ។

ខ្ញុំញឹមៗមិនបានយកចិត្តទុកដាក់ស្ដាប់ប៉ុន្មានទេ ។ ព្រឹកនេះពិតដូចយើងទាំងអស់គ្នាស្មានមែន ពេលដែលពួកយើងកំពុងតែខិនច្រូតស្រូវយើងឃើញប្រពន្ធប្រធានក្រុមប្រពន្ធឈ្លបរត់ត្របាញ់ជើងសំដៅទៅស្រែ លាត់សំពត់ចង់ដល់ក្រលៀនមានទឹកមុខភិតភ័យជាខ្លាំង ខ្លះដូចជាពេបចង់យំផង រត់ទៅដល់ខ្សឹបប្រាប់ប្ដីគេឲ្យទៅភូមិជាបន្ទាន់ ។ ពួកយើងមានសេរីភាពបានសម្រាកកម្លាំងបន្តិចឈរដៃដែកលេងសើច គ្មានដឹងថាមានហេតុការណ៍អ្វីកើតឡើងទេ ។ ថ្ងៃជិតត្រង់មានកូនចៅអ្នក១៧មេសារត់ប្រសេចប្រសាចតម្រង់មកកន្លែងពួកយើងច្រូតដោយទឹកមុខរីករាយខុសពីពួកមូលដ្ឋាន ។ ពួកកូនចៅអស់នោះស្រែកដោយអំណរថា៖

- ម៉ែអើយ ស្រុកយើងបានរំដោះហើយ!

តើមានពាក្យអ្វីសប្បាយជាងពាក្យមួយម៉ាត់នេះ ។ ពួកយើងរត់ត្របាញ់ជើងត្រឡប់មកភូមិវិញ ដើម្បីរៀបចំអីវ៉ាន់ត្រឡប់ទៅស្រុកកំណើត ។ ខ្ញុំដើរយឺតតាមក្រោយគេ គ្មានសប្បាយគ្មានរំភើបញាប់ញ័រអ្វីនឹងគេបន្តិចសោះ ។ តើមានន័យអ្វីទៅបើជីវិតឯកោយ៉ាងនេះ ។ ម្នាក់ៗរៀបចំខោអាវ ខ្វះរត់ទៅ រោងបាយដើម្បីកើបអង្ករអំបិលប្រហុកយកទៅទុកហូបតាមផ្លូវ ។ ខ្ញុំគ្មានអ្វីរៀបចំនឹងគេសោះ ខ្ញុំឈរដូចទឹងមោងនៅមាត់ស្ទឹងជិតបន្ទប់ ហាក់គ្មានវិញ្ញាណអ្វីបន្តិចនៅក្នុងខ្លួន ។

ស្ទឹងអើយ! អ្នកដឹងដំណើរប្ដីសម្លាញ់ខ្ញុំទេ ជួយប្រាប់គាត់ផង ខ្ញុំកំពុងតែរង់ចាំរងាខ្លាំងណាស់ ស្រុកគេបានសាន្តត្រាណហើយ យើងនាំគ្នាទៅស្រុកយើងវិញ ។ ត្រឡប់មកបងសម្លាញ់! យើងរៀបចំជីវិតយើងជាថ្មី (ឬមួយក៏បង...អូយទេវតាអើយសូមកុំឲ្យដូចការគិតរបស់ខ្ញុំឲ្យសោះ) មកជួយប្រពន្ធផង ដូចដែលបងធ្លាប់ជួយខ្ញុំបីឆ្នាំថ្វាយកន្ទងមកហើយ ។ ឱជីវិតអើយ! គ្មានអ្វីលំបាកជាងការព្រាត់ប្រាសគ្នាទេ ហើយក៏គ្មានអ្វីសប្បាយជាងការជួបជុំគ្នាដែរ ។

ខ្ញុំកំពុងតែភាន់ទាំងស្មារតីប្រពន្ធ អ៊ំសាឡេះ មកអូសដៃខ្ញុំចេញដំណើរទៅជាមួយគាត់ ។ ខ្ញុំមានតែកញ្ជើមួយ អង្ករពីរកំប៉ុង អាវដៃវែងនិងសំពត់ខ្មៅជ្រលក់មួយរយបំណះប៉ុណ្ណោះ តែខ្ញុំទូលពុំចង់រួចសោះ ពីព្រោះជើងខ្ញុំហើមធំពេក ។ ខ្ញុំងាកមើលទឹកស្ទឹងជាលើកចុងក្រោយ មើលបន្ទប់ក្រង់ស្រូវ មើលដើមអំពិលដែលខ្ញុំធ្លាប់ឈោងបេះបានតែស្លឹកចាស់ៗ ។ លាហើយទឹកន្លែងដែលផ្ទុំក្លិនឆ្អេះឆ្អាបដោយសមុទ្រឈាម លាហើយកែវភ្នែកដ៏កាចសាហាវគ្មានមនុស្សធម៌របស់ពួកឈ្លបក្មេងៗ លាហើយទឹកបបររាវកខ្វក់ លាហើយអ្វីៗគ្រប់យ៉ាងដែលគ្រួសារខ្ញុំសាងជាមួយគ្នា លាហើយកូនសម្លាញ់ម្ដាយទាំងបី លាហើយស្ទឹងទឹកដោរដែលអ្នកនាំយកជីវិតប្ដីនិងកូនខ្ញុំទៅអស់រលីងគ្មានដំណឹងអ្វីបន្តិច សោះ ។

ខ្ញុំដើរពុំចង់រួច មានអារម្មណ៍ថាដូចជាឮសំឡេងប្ដី និងកូនខ្ញុំស្រែកហៅពីក្រោយ ។ ខ្ញុំងាកក្រោយជាញឹកញាប់ក្រែងប្ដីសម្លាញ់ខ្ញុំត្រឡប់មករកខ្ញុំវិញ ។ លោកអ្នកអានទាំងអស់ ដល់វគ្គនេះខ្ញុំពុំអាចទប់ទឹកភ្នែក ព្រោះនឹកឃើញរឿងដូចនៅថ្មីៗ បែកគ្នាស្រស់ៗពេក ។ យើងពុំនឹកស្មានថា បែកគ្នាតែបីថ្ងៃសោះ ប្ដីអើយ! យើងបែរជាបែកគ្នារហូតយ៉ាងនេះទៅវិញ ទាំងពុំឃើញស្រមោលអ្វីបន្តិចសោះ ។

ខ្ញុំដើរដោយលំបាកក្នុងចំណោមគ្រួសាររាប់រយនាក់ពេញណែនតាមផ្លូវ ។ គ្រួសារគេធ្វើដំណើរដោយទឹកមុខរីករាយព្រោះគេមិនបែកបាក់គ្នា ។ ខ្វះមុខស្លុតព្រោះបាត់បង់កូនចៅ តែទោះយ៉ាងណាក៏គេនៅគ្រាន់បើជាងខ្ញុំច្រើន ព្រោះគេនៅមានគ្នីគ្នាគ្រាន់កំដរដែរ ។ ចំណែកខ្ញុំដើរតែម្នាក់ឯងដូចបដាចា គឺបដាចា ទីពីរគ្មានខុសបន្តិចសោះ ។

ខ្ញុំហាក់ដើរក្នុងវាលខ្សាច់សាហារ៉ាដ៏ធំធេងតែម្នាក់ឯងទាំងដំណើរធេងធោងកណ្ដាលកណ្ដែងពេកក្រៃ ។

បងអើយ! ហេតុអ្វីយើងមកត្រូវបែកគ្នានៅពេលហៀបជិតដល់កោះត្រើយទៅហើយ ។

ខ្ញុំឆ្លងស្ពានតាប៉ុន ចូលដល់ស្រុកក្រឡាញ់ (ក្នុងខេត្តសៀមរាប) ។ ជាមួយរលកមនុស្សជាច្រើននាក់ដែលខ្ញុំពុំស្គាល់ម្នាក់សោះ ។ ពេញមួយព្រឹកខ្ញុំដើរបានតែប្រហែលពីរគីឡូម៉ែត្រប៉ុណ្ណោះ ហើយរកម្លប់អង្គុយសម្រាក ។ ប្រជាជននៅស្រុកក្រឡាញ់ មានទឹកមុខរីករាយ សាច់ឈាមស្រស់បស់ សម្លៀកបំពាក់ស្អាតបាត ពុំដូចពួកយើងជនភៀសខ្លួនមកពីខាងបាត់ដំបងទេ ព្រោះពួកគេពុំចេញទៅណាចោលស្រុកភូមិដូចពួកយើង ។ ពួកគេទាំងក្មេងទាំងចាស់ចេញមករោមមើលពួកយើងដូចសត្វចម្លែកដូច្នេះ ។ គេអាណិតអាសូរយើង ព្រោះឃើញក្បាលជង្គង់ធំជាងក្បាល មុខស្លេកស្លាំងគ្មានឈាម ខ្លួនស្គមកំព្រឹង សម្លៀកបំពាក់រហែករយ៉ៃ ។ ខ្ញុំអង្គុយចោងហោងយកក្រមាររហែកទ្រាប់គូថ ។ អ្នកភូមិនិងក្មេងៗប្រុសស្រីពីរ-បីនាក់ដើរតម្រង់មកខ្ញុំ ព្រោះពុំឃើញខ្ញុំរវៀសរវៃដាំបាយដូចគេឯងឯងទៀតឡើយ ។ គាត់សួរខ្ញុំថា÷

- នាង! នាងឈ្មោះអី? ស្រុកកំណើតនៅឯណា? ម៉េចឃើញតែម្នាក់ឯងដូច្នេះ?

- ខ្ញុំឬ? (ខ្ញុំសួរគាត់វិញពុទ្ធោតើខ្ញុំឈ្មោះអ្វីទៅ? ស្រុក ខ្ញុំនៅឯណាក៏មិនដឹង) ។

ខ្ញុំគ្មានការចងចាំអ្វីបន្តិចសោះ តើឲ្យខ្ញុំឆ្លើយថាម៉េចទៅ? ខ្ញុំឈ្មោះអ្វី? ខ្ញុំនឹកមិនឃើញទេ ទេវតាអើយសូមលោកជួយប្រាប់ខ្ញុំផង ។

ខ្ញុំឆ្លើយមិនរួចក្រៅពីគ្រវីក្បាល នឹកអ្វីក៏មិនឃើញ ។ អ៊ំប្រុសគាត់អាណិតខ្ញុំក៏និយាយថា÷

-នៅក្នុងភូមិនេះជាមួយនឹងខ្ញុំហើយ ចាំខ្ញុំជួយមើលឲ្យមានព្រលឹងព្រលះនឹងគេ មានសាច់មានឈាមឡើងវិញ ចាំទៅមុខទៀត!

ខ្ញុំមិនឆ្លើយថាម៉េចផង កូនៗគាត់ពីរ-បីនាក់ក៏ទាញដៃខ្ញុំឡើង ខ្លះជួយយកកញ្ចើខ្ញុំទៅមុន ។ ផ្ទះអ៊ំប្រុសនៅជិតនេះដែរ ចម្ងាយប្រហែល៥០ម៉ែត្រពីផ្លូវធំ ។ ប្រពន្ធគាត់ឈ្មោះ យឿន អាយុប្រហែល៥០ឆ្នាំហើយ គាត់ចិត្តល្អ ហើយអាណិតអាសូរខ្ញុំណាស់ ។ គាត់ថាឲ្យខ្ញុំនៅជាមួយគាត់ ធ្វើជាកូនចៅគាត់តែម្តងទៅ ព្រោះកូនគាត់ស្លាប់អស់បីនាក់ ហើយសល់តែម្នាក់ប៉ុណ្ណោះ ។ ចំណែកអ៊ំប្រុសឈ្មោះ សុខ គាត់ធ្លាប់បួសជាសង្ឃ កាលពីសង្គមចាស់ ទើបក្នុងផ្ទះគាត់យកស្បង់លោកធ្វើជាវាំងននទិនស្រោមខ្នើយ ។ អ៊ំសុខ អាយុ៦០ឆ្នាំហើយ គាត់យកអំបោះឆៅពណ៌សមកចងដៃសងខាងរបស់ខ្ញុំ យកទឹកមួយផ្តិលមកប្រោះព្រំលើក្បាលខ្ញុំហៅព្រលឹងបួន-ដប់ចូលមកខ្លួនខ្ញុំវិញ ។

បីថ្ងៃក្រោយខ្ញុំបានស្រឡះក្នុងខួរក្បាលបន្តិចដឹងខ្លួនថាឈ្មោះ អី តែនៅរកនឹកឈ្មោះពិត ក្នុងសំបុត្រកំណើត ហើយធ្វើការអីផ្ទះនៅឯណារកនឹកមិនឃើញសោះ ។ ខ្ញុំរស់នៅបានប្រហែលកន្លះខែហើយ នៅផ្ទះអ៊ំប្រុស សុខ និងអ៊ំស្រី យឿន ខ្ញុំនឹករឭក បងប្អូនឪពុកម្តាយខ្ញុំ ដឹងនូវខ្ញុំពុំដឹងរស់ឬស្លាប់យ៉ាងណា... ។

## ភ្លេចការប្រហារចិត្តខ្ញុំ

ខ្ញុំបានលាគ្រួសារអ៊ំសុខ និងអ៊ំស្រីយឿន និងញាតិមិត្តជិតខាងផ្ទះដែលតែអាណិតស្រឡាញ់ខ្ញុំ តែងហុចនំហុចនែកឲ្យហូបមិនដែលដាច់ ។ អ្នកស្រុកអ្នកភូមិអស់នោះគាត់អាឡោះអាល័យខ្ញុំណាស់ ពួកគាត់ជូនពរឲ្យខ្ញុំជួបនឹងឪពុកម្តាយបងប្អូនទាំងអស់ដែលបែកគ្នា៣ឆ្នាំប្លាយមកហើយ ។

ខ្ញុំចាប់ផ្តើមធ្វើដំណើរផ្សងព្រេងទៀតហើយ នៅតាមផ្លូវ នៅតែមានអ្នក១៧មេសាយើងមិនចេះដាច់ ។ ខ្ញុំចេះតែដើរតាមគេពីភូមិមួយដល់ភូមិមួយ ប៉ុន្តែខ្ញុំភ្លេចឈ្មោះភូមិអស់នោះទៅហើយ ។ នៅតាមផ្លូវខ្ញុំបានជួបអ្នកដែលរស់នៅក្នុងភូមិជាមួយខ្ញុំខ្លះដែរ ។ មានថ្ងៃនោះ ខ្ញុំបានជួបនឹងបងស្រីម្នាក់ដែលគាត់ឆ្លងទន្លេនៅកណ្តាលផ្លូវ គាត់បានសុំជ្រកក្រោមផ្ទះគេសម្រាកសិន កូនគាត់គឺកូនប្រុស ប៉ុន្តែវាមិនសូវថ្ងាសទេ ។ ម្ចាស់ផ្ទះក៏មានមេត្តាធម៌ឲ្យបាយទឹកគាត់ហូបរាល់ថ្ងៃ ។ ជាតិជាស្ត្រីគ្មានអ្វីវេទនាក្នុងពេលឆ្លងទន្លេ ហើយរឹតតែលំបាកទៀតនោះ គឺគ្មានប្តីនៅជួយថែទាំ ។ ខ្ញុំបានសួរថា ប្តីគាត់ទៅណាហើយ ។ បងស្រីយំ ហ៊ូភ្លាមហើយនិយាយមិនចង់ចេញថា÷ បាត់គាត់តាំងពីនៅក្នុងភូមិម៉្លេះ គេថាស្នើទៅជួយធ្វើរោងបាយមួយភ្លែត តាំងពីល្ងាចនោះមកក
[៨] បាត់គាត់រហូត ។

បងស្រីយំអណ្តឺតអណ្តក ឱបកូនប្រុសដែលហាក់តំណាងឲ្យរូបប្តីគាត់ ។ ខ្ញុំធ្វើដំណើរទៅមុខទៀតជាមួយកូនបង្កើតដែលមានខោអាវចំណាស់ពីរកំប្លេ កូនឆ្នាំងបាយមួយ មុងមួយ និងភួយមួយ ។

ខ្ញុំធ្វើដំណើរពីភូមិមួយដល់ភូមិមួយដូចជាអ្នកទេសចរ (អ្នកទេសចរសក់ក្បាលកន្ទ្រើង) ។ ទីកន្លែងណាដែលឮសូរភ្លេង ការ ភ្លេងបុណ្យ ចម្រៀងលោក ស៊ិន ស៊ីសាមុត, អ្នកស្រី រស់ សេរីសុទ្ធា, អ្នកស្រី ហ៊ុយ មាស គឺមានវត្តមានខ្ញុំនៅទីនោះ ហើយ ។ តែខ្ញុំពុំមែនជាភ្ញៀវកិត្តិយសក្នុងពិធីអស់នោះទេ ខ្ញុំនៅកៀនកន្លៀតជិតរោងបុណ្យក្រោមដើមឈើ ។ ជួនកាលខ្ញុំកំពុងតែលន្លង់លន្លោចនឹងចម្រៀងអស់នោះ ភ្លេចខ្លួន ភ្លេចបាយភ្លេចទឹក មានដៃមួយមកកេះស្មាខ្ញុំ ហើយហុចបាយមួយចានក្តៅហុយៗ ហើយនិងសម្លម្ជូរយួនមួយចានឲ្យខ្ញុំហូប ។ គេដាក់ទានហើយត្រូវតែហូប ខ្ញុំសូមជូនកុសលផលបុណ្យដល់បងប្អូនទាំងអស់ដែលបានជួយស្រោចស្រង់ជីវិតខ្ញុំ (នៅក្នុងគ្រាដ៏សែនកម្សត់នោះ) ។ រយៈពេលប្រហែលមួយខែជាង ខ្ញុំចូលដល់ខេត្តសៀមរាប គេឲ្យពួកយើងនៅម្តុំ នៅជាយខេត្ត ខ្ញុំពុំដឹងថាជាភូមិអី សង្កាត់អីទេ ។ នៅម្តុំនោះធុំក្លិនស្អុយលាមកជាខ្លាំង អ្នកណាដើរកាត់ទីនោះត្រូវតែយកដៃខ្ទប់ច្រមុះ ។ រាល់ព្រឹកមានរថយន្តកងទ័ពវៀតណាម (ឡាន**G.M.C**) បួន-ដប់ រាល់ថ្ងៃមកដឹកយកពួកជនភៀសខ្លួន

យកទៅដាក់តាមភូមិស្រុករបស់គេវិញ ។ ឡានកងទ័ពនោះខ្ពស់ណាស់ ខ្ញុំគោងឡើងមិនរួចនឹងគេទេ ហើយក៏គ្មានអ្នកណាគេគិតគូរពីខ្ញុំ ជួយទាញខ្ញុំឡើងដែរ ។ ព្រោះគេរវល់គិតតែបងប្អូនគេប៉ុណ្ណោះ ។ ហេតុនេះខ្ញុំត្រូវនៅខេត្តសៀមរាបនេះមួយថ្ងៃហើយមួយថ្ងៃទៀត ជិតកន្លះខែខ្ញុំត្រូវដើរសុំបាយអង្ករអ្នកស្រុកអ្នកភូមិជារៀងរាល់ថ្ងៃ ។ ព្រឹកនេះខ្ញុំតាំងចិត្តថាត្រូវតែឡើងឡានឲ្យរួចទោះឡើងតែខ្លួនទទេក៏ដោយ ។ ខ្ញុំបានឲ្យកូនឆ្នាំង មុងភួយ ទៅស្ត្រីម្នាក់ដែលនៅសំណាក់ជិតខ្ញុំអស់រលីង ។ ខ្ញុំខំប្រវាគោងឡើងឡានយោធាវៀតណាមនោះជាមួយគេឯងដែរ តែទោះជាខំយ៉ាងណាក៏គ្មានកម្លាំងកំហែងឡើងរួចឡើយ ។ ឡានជិតចេញហើយ ខ្ញុំបែកញើសរហាម គ្មានសង្ឃឹមថាបានទៅនឹងគេទេ ។ ស្រាប់តែចៃដន្យមានអ៊ំប្រុសម្នាក់ ដែលបម្រុងយកកង់ឡើងលើឡាន ក្រឡេកឃើញខ្ញុំឈរអេះអុញក្បែរនោះក៏សួរខ្ញុំថា÷

-ក្មួយចង់ឡើងឡានឬ? ម៉េចមិនឡើងឲ្យលឿនទៅឡានជិតចេញហើយ ។

ខ្ញុំឆ្លើយថា÷

-ខ្ញុំឡើងមិនរួចទេអ៊ំ ។

អ៊ំប្រុសក៏ឲ្យខ្ញុំឡើងជាន់លើកែបកង់របស់គាត់ ។ ខ្ញុំត្រេកអរណាស់ ហើយអ៊ំប្រុសក៏ឡើងតាមពីក្រោយដែរ ។ ប្រហែលថ្ងៃត្រង់ឡានក៏ឈប់នៅស្ពានដើម្បីឲ្យពួកយើងអ្នកជិះចុះដាំបាយទឹកហូប ។ ខ្ញុំចុះមកអង្គុយសំកុកព្រោះគ្មានឆ្នាំង គ្មានអង្ករដាំនឹងគេ ។ ពេលនោះមានបងស្រីម្នាក់ផ្ទះនៅជិតនោះ ស្លៀកសារុងសូត្រ ពាក់អាវម៉ុងតាហ្គុយ ហើយមានកូនស្រីម្នាក់អាយុប្រហែល១០ឆ្នាំ សាច់ឈាមស្រស់ថ្លា បានដើរមកសួរខ្ញុំថា÷

-ប្អូនស្រីហេតុអ្វីមិនដាំបាយហូបនឹងគេ?

ខ្ញុំឆ្លើយថា÷

-ខ្ញុំគ្មានចានឆ្នាំងអង្ករអីនឹងគេទេបងស្រី ។

បងស្រីដើរសំដៅទៅផ្ទះនៅក្បែរនោះហើយដួសបាយ មួយចានស្រួបសម្លម្ជូរខ្មែរយកមកឲ្យខ្ញុំហូប ។ ខ្ញុំបានថ្លែងអំណរគុណដល់បងស្រីក្រោយពេលហូបបាយហើយ ។ បងស្រីសួរខ្ញុំថា គ្មានគ្រួសារទេឬ? បើនៅម្នាក់ឯង កុំទៅភ្នំពេញអីនៅជាមួយគាត់ហ្នឹងហើយ ។

ខ្ញុំសឹៗដូចត្រូវថ្នាំសណ្តំមិនដឹងឆ្លើយថាម៉េច ។ ពេលឡានស៊ីផ្លេ ខ្ញុំក៏លាគាត់ឡើងឡានទៅដោយមានបងប្អូននៅលើឡានជួយទាញដៃឡើង ។

ល្ងាចហើយ ឡានបានយកពួកយើងទៅទម្លាក់ចោលនៅស្គន់ ។ ខ្ញុំចុះពីលើឡានស្មុគស្មាញថ្ងូរហែករយៃ ព្រោះពុំដឹងអង្គុយលើរបស់អ្វីខ្លះ ។ ខ្ញុំនិងបងប្អូនជម្លៀសឯទៀតសម្រាកនៅក្រោមដើមអំពិលបារាំងធំមួយ ។ ព្រឹកឡើងអ្នកខ្លះក៏រៀបចំតវ៉ាន់ចេញដំណើរទៅមុខទៀតជាបន្តបន្ទាប់ ។ មានតែអ្នកដែលមានឪពុកម្តាយចាស់ទៅមិនទាន់រួច ត្រូវនៅសម្រាកយកកម្លាំងសិន ។ ខ្ញុំនៅសម្រាកទីនោះមួយថ្ងៃហើយមួយថ្ងៃទៀត ព្រោះគ្មានកម្លាំងទៅមុខនឹងគេ មានអ្នកជម្លៀសខ្លះគេឲ្យអង្ករ ឲ្យឆ្នាំង ខ្លះឲ្យមុងភួយខ្ញុំដណ្តប់ ដូច្នេះខ្ញុំក៏មានទ្រព្យសម្បត្តិខ្លួនឯងឡើងវិញហើយ ។ ខ្ញុំនៅសម្រាកនៅទីនោះបានមួយអាទិត្យ មានបងប្រុសម្នាក់អាយុប្រហាក់ប្រហែលខ្ញុំ ហើយមានកូនស្រីមួយប្រហែល ៤-៥ឆ្នាំ បានមកស្នើខ្ញុំធ្វើជាគូគាប់ដោយគាត់បង្ហាញរបស់មួយដុំនៅចង្កេះខោចែវរបស់គាត់ ។ គាត់ថាអាណិតខ្ញុំណាស់ឃើញនៅម្នាក់ឯង គាត់ធានាចិញ្ចឹមខ្ញុំឲ្យរស់សុខសប្បាយដូចគេឯង ។ ខ្ញុំនៅធ្មឹងគ្មានរំភើបគ្មានញាប់ញ័រ បេះដូងខ្ញុំស្លាប់បាត់ទៅហើយរឿងអីខ្ញុំមានអារម្មណ៍ស្រឡាញ់ប្រុសដទៃទៀត នៅពេលដែលមនុស្សជាទីស្រឡាញ់របស់ខ្ញុំទាំងអស់ ទើបនឹងឃ្លាតចោលខ្ញុំនៅថ្មីៗនៅឡើយ ។ ខ្ញុំឆ្លើយយ៉ាងខ្លីជាមួយគាត់ថា÷

-ខ្ញុំមិនទាន់នឹកនារឿងប្តីសីអីទេ ។

ព្រឹកឡើងបុរសនោះក៏នាំកូនចេញដំណើរទៅភ្នំពេញបាត់ទៅ ។ បួន-ប្រាំថ្ងៃក្រោយ ខ្ញុំក៏ចេញដំណើរសំដៅទីក្រុងភ្នំពេញដែរ ។ ទម្រាំមកដល់ត្រើយខាងកើតអរិយក្សត្រជិតកន្លះខែ ។ ខ្ញុំត្រូវជិះទូកឆ្លងទន្លេ នៅពេលដែលជិះទូកឆ្លងទន្លេ ខ្ញុំចោលភ្នែក

*មកកើតហើយឃើញដងស្ពានជ្រោយចង្វារដាច់ខ្ទួន ដែលនៅឈរជ្រងោកាត់ទទឹងទន្លេគួរឲ្យស្រណោះបំផុត ។ ខ្ញុំមកដល់ត្រើយគីឡូម៉ែត្រលេខ៧ ។ ទីនោះគឺជាផ្សារមួយយ៉ាងធំមានមនុស្សអ៊ូអរ លក់ដូរនំចំណីគ្រប់បែបយ៉ាង ធ្វើឲ្យខ្ញុំឃ្លានជាខ្លាំង ។ ខ្ញុំកំពុងតែឈរភ្លេចខ្លួននឹងនំចំណី ស្រាប់តែមានដៃមួយមកកេះស្មាខ្ញុំគឺមិត្តសម្លាញ់ស្រីខ្ញុំដែលធ្លាប់ធ្វើការជាមួយគ្នាតាំងពីសង្គមចាស់គឺអារុណា ។ យើងពីរនាក់ឱបរឹតគ្នាយ៉ាងយូរដោយក្ដីនឹករព្ញក ។ អារុណា គេនៅជុំគ្នាប្ដីប្រពន្ធគេមិនសូវកម្សត់ដូចខ្ញុំទេ ។ ខ្ញុំបានទៅមើលផ្ទះខ្ញុំនៅមុំផ្សារស៊ីឡឹប គ្មានសល់អ្វីទាំងអស់ ហើយបង្ហួសទៅមើលកន្លែងប្ដីខ្ញុំកប់របស់១០ជំហានពីរបងផ្ទះក៏រកពុំឃើញកន្លែងកប់របស់ ព្រោះគេរើរបងនោះចោល ហើយដាំដើមចេកជំនួសវិញទៅហើយ ។ គ្មានសល់អ្វីទេ លោកឪពុកអ្នកម្ដាយ ជីដូនជីតា ប្អូនប្រុស៤នាក់ ។ ក្រោយមក ខ្ញុំបានជួបប្អូនប្រុសទី៤ឈ្មោះ ហេង សុខម៉ាឡា ដែលវានៅរស់និងជាអ្នកជួយកត់ត្រាប្រលោមលោកសោកនាដកម្មនេះ ។*

*កន្លះខែក្រោយមក ពួកយើងក៏នាំគ្នាដាក់ពាក្យចូលធ្វើការនៅក្រសួងសុខាភិបាល ។ យើងក៏ត្រូវគេចាត់តាំងឲ្យមកធ្វើការនៅពេទ្យលោកសង្ឃដែលឥឡូវដូរដាក់ជាមន្ទីរពេទ្យព្រះកុសុមៈវិញ ។ ខ្ញុំបានជួបមិត្តភ័ក្ដជាច្រើនទៀត មានស្រី មានប្រុស ។ ហើយក៏មានមិត្តប្រុសខ្លះដែលពោះម៉ាយបានសុំរៀបការជាមួយខ្ញុំ តែខ្ញុំគ្មានចិត្តនឹកនារឿងអស់នេះសោះ ។*

*នៅឆ្នាំ១៩៨០ ខ្ញុំដាច់ចិត្តរៀបការនឹងបុរសម្នាក់ដែលគាមស្រឡាញ់ខ្ញុំយ៉ាងស្វិតស្វាញបំផុត ។ ២៣ឆ្នាំកន្លងហើយខ្ញុំមានកូនអាយុ១៦ឆ្នាំ ។ ចិត្តបំណងថានឹងរួមរស់ជាមួយគ្នា តស៊ូនឹងគ្នារហូតដល់ចាស់ស្លាប់ ប៉ុន្តែបែរជាពុំដូចចិត្តប្រាថ្នាទៅវិញ ។ ទីបំផុតខ្ញុំក៏សម្រេចចិត្តបែកពីគាត់ ព្រោះតែយើងរស់នៅពុំសូវចុះសម្រុងនឹងគ្នា ។ មកដល់គ្រង់វគ្គបញ្ចប់នេះ ដោយសារតែជីវិតហាក់ដូចជារកន័យមិនឃើញ ខ្ញុំសម្រេចចិត្តសន្មែបបញ្ចប់យ៉ាងសោះកក្រោះបំផុត ។ ជីវិតដូចឆាកល្ខោន ។ ឥឡូវខ្ញុំអាយុ៥២ឆ្នាំហើយ ផែនដីពិតជាមូលមែន វិលចុះវិលឡើងខ្ញុំនៅតែជា ស្ត្រីមេម៉ាយដដែល គួរឲ្យចង់សើចណាស់ ។*

*កំពុងតែស្ទុងអារម្មណ៍ កូនប្រុសពៅខ្ញុំឈ្មោះ សម្បត្តិ បានមកអង្គុយជិតខ្ញុំ ហើយវាហុចការ៉េមគីឲ្យខ្ញុំមួយដុំដែលជាទម្លាប់របស់វាពេលត្រឡប់មកពីរៀនរាល់ថ្ងៃ ។ វាលូកដៃជូតទឹកភ្នែកលើផែនថ្ពាល់ដ៏ជ្រីវជ្រួញរបស់ខ្ញុំ ។*

*“ស្រមោលបង” សូមលំឱនកាយគោរពលាអស់លោកអ្នកអានទាំងអស់ដោយចិត្តសោកស្ដាយ ហើយរង់ចាំការទិតៀនពីអស់លោកទាំងអស់ដោយចិត្តរីករាយ និងសូមអភ័យទោសផងដែរ ចំពោះមិត្តកម្សត់ទាំងអស់ក្នុងរបបពួកឃាតករអាវខ្មៅនេះបើមានការខុសឆ្គងអ្វី ។ សូមផ្ញើការនឹករព្ញកចំពោះមិត្តកម្សត់ទាំងអស់ ដែលឥឡូវមិនដឹងទៅដល់ទីណាខ្លះ សូមមិត្តទាំងអស់ បានប្រកបតែនឹងសេចក្ដីសុខគ្រប់ប្រការ ។*

*សូមថ្លែងអំណរគុណចំពោះគ្រួសារក្មួយប្រុស ឡាច សំរេង ដែលបានជួយជាកម្លាំងចិត្តដល់ខ្ញុំទើបរឿងស្រមោលបងនេះអាចកើតជារូបរាងឡើង ។*

**ហេង សុខផាន់ណា**